# កម្ពុជសុរិយា

RÉGIE DU DÉPÔT LÉGAL

COMMISSION DES MOEURS & COUTUMES

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ ចេញពុម្ពផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ

---

វណ្ណាធិការ ផ្នែកអក្សរសាស្ត្រ: ហ្លួងឧត្ដមមន្ត្រី ញ៉ុក-ថែម. បណ្ណារក្ស នៅ
ពុទ្ធសាសនបណ្ឌិត្យ

វណ្ណាធិការ ផ្នែកដំណឹងសាសនា: ព្រះគ្រូសុវណ្ណញាណ សូរ ប៉ា.យ
ក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ

---

## បញ្ជីរឿង

ទំព័រ

*ផ្នែកអក្សរសាស្ត្រ*

លោក ឌឹម-ប៊ុក សមុហបញ្ជី
នៅពុទ្ធសាសនបណ្ឌិត្យ — សុភាសិតបារាំងសែស ............ ២៤៣
" " — រឿង ស៊ុន-យ៉ាត់-សេន (តមក) .......... ២៥០
ហ្លួងឧត្ដមមន្ត្រី ញ៉ុក-ថែម — ប្រវត្តិសាស្ត្រសង្ខេបប្រទេសបិន (តមក) ...... ២៦៨
អ្នកឧកញ៉ាវិបុលរាជសេនា (នូ-កន)
អ៊ំណាងភក្ត្រ — រឿងសាមកុក (តមក) ............ ២៧៣
ឧសុក្ខមេធី ញ៉ុង-សៀង — ឆកសហស្សរាត្រី ភាគទី ១៩ (តមក) ........ ២៨៧

*ផ្នែកសាសនា*

ព្រះគ្រូកោវិទវង្សាចារ្យហ៊ែម ការ៉ង់
គ្រូបង្រៀនសាលាបាលីជាន់ខ្ពស់ — ប្រវត្តិនិងពិធីបូជាព្រះសពសម្ដេចព្រះសុមេធាធិបតី សង្ឃនាយកគណៈមហានិកាយ ...... ២៩២
ព្រះគ្រូបញ្ញាសីលខិត កៅ-ស៊ឹម
គ្រូបង្រៀនសាលាបាលីជាន់ខ្ពស់ — យុវវរិយាកថា (តទកនិងកប់) ......... ៣០៦

---

FRA... ÉGIE DU ...PÔT LÉGAL ...AISE

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ បោះពុម្ពផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រៈ ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម, បណ្ណិត នៅ
ពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកដំណឹងសាសនាៈ ព្រះគ្រូសុវណ្ណញាណ ស្វរ-ម៉ុយ
ក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ

## បញ្ជីរឿង

*ផ្នែកអក្សរសាស្ត្រ* ទំព័រ

លោក វ៉ៃ-ប៊ុក លេខាធិការ បញ្ជីធំ

នៅពុទ្ធសាសនបណ្ឌិត្យ សុភាសិតបារាំងសែស ........................ ២៤៩

" " រឿង ស៊ុន-យ៉ាត់-សេន (តមក) ............ ២៥០

ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម ប្រវត្តិសាស្ត្រសង្ខេបប្រទេសបិន (តមក) ...... ២៦៨

អ្នកឧកញ៉ាវិបុលរាជសេនា (នូ-កន)

ចំណោងកស្ត្រ រឿងសាមកុក (តមក) ................ ២៧៣

ឧសុទ្ធមេធី ញ៉ុក-សឿង ឯកសារហស្សរាត្រី ភាគទី ១៩ (តមក) ......... ២៨៤

*ផ្នែកសាសនា*

ព្រះគ្រូពោធិវង្សាចារ្យពុទ្ធ ភង-កង

គ្រូបង្រៀនសាលាបាលីជាន់ខ្ពស់ ប្រវត្តិនៃគតិធម៌បូជាព្រះសពសម្ដេចព្រះសុមេធាធិ-
បតី សង្ឃនាយកគណៈមហានិកាយ ........ ២៩២

ព្រះគ្រូបញ្ញាលំចិត កៅ-ស៊ុម

គ្រូបង្រៀនសាលាបាលីជាន់ខ្ពស់ យុវចរិយាកថា (តទៅទៀត) .......... ៣០៦

ឆ្នាំទី ២០ — លេខ ៤ ខែ មេសា ឆ្នាំ ១៩៤៨ — ដំឡៃជាវ ១ ឆ្នាំ ៦៧ រៀល ។

# KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

Rédacteur en chef de la partie littéraire : Luong Nibandhamantri NHOK-THÈM, Pandit à l'Institut Bouddhique.

Rédacteur en chef de la partie religieuse : Vénérable Brah grū Suvaddhannana SŌ-HAY membre de la Commission du Tripitaka

## TABLE DES MATIÈRES

**Partie littéraire**


| | | page |
|---|---|---|
| Monsieur RAY - Buc Chef Comptable (I.B.) | Proverbe Français........... .... | 243 |
| -id- | Un épisode de la vie de Sun-Yat-Sen, homme politique chinois ( suite et fin ) ....... ........ | 250 |
| Luong Nibandhamantri NHOK-THÈM (I.B.) | Histoire de Chine (suite) .......... | 265 |
| Neak Okuña Vipularājasenā (NOU-KAN) Député | Histoire de Sam Kok ( suite)...... | 273 |
| Khun Sundaramedhi NHOUNG - SŒUNG (I.B.) | Mille et une nuits fasc. 15 (suite) .... | 283 |


**Partie religieuse**


| | | |
|---|---|---|
| Vén. Brah grū Bodhivamsa REACH-KŒUNG fesseur à L. E. S. P. | Biographie et cérémonie d'incinération de S. E. Samdach Brah Mahāsumedhādhipati Prak - Hin......... | 292 |
| Vén Brah grū ... Ekbit KAO-S... | Yuvacariyakathā (suite et fin)...... | 306 |


20e Année n° 4 Avril 1948 — Prix d'abonnement 68$00 par an.

# ពាក្យប្រារព្ធ

ធម្មតាជាសុភាសិត ច្រើនមានអត្ថរសពិរោះពិសារ សម្រាប់ជាតិ វៀតគេនាំគ្នាចាំទុក ប្រកាន់យកជាគតិតៗគ្នារៀងមក ។ សុភាសិតទាំង-ឡាយនោះទោះបីជាពាក្យខ្លីៗ ក៏ច្រើនតែមានសេចក្តីជ្រៅទូលំទូលាយ ជាងពាក្យធម្មតា ហើយជាសំដីនិយាយត្រង់ៗក៏មាន ជាសំដីនិយាយ ប្រៀបក៏មាន ។ សុភាសិតខ្មែរក្តី សុភាសិតបរទេសក្តី ទោះបីមាន អត្ថរសប្រហែលគ្នាក្តី ខុសប្លែកពីគ្នាក្តី ក៏សឹងជាពាក្យមានខ្លឹមសារ សម្រាប់ជាតិនៃគេរៀងខ្លួន ហេតុនេះហើយ បានជាសុភាសិតទាំងឡាយ មិនវិនាសសាបសូន្យទៅ នៅមានគេនិយមរាប់អានចាំទុកតៗគ្នាមក រាប់រយរាប់ពាន់ឆ្នាំ ។

ការណ៍ដែលយើងនាំយកសុភាសិតបារាំងសែស មកបោះពុម្ព ផ្សាយក្នុងសៀវភៅថ្មីនេះ ដើម្បីជាគ្រឿងប្រដាប់សតិបញ្ញារបស់ញាតិ មេជាតិ ដែលមិនបានចេះដឹងភាសានេះប៉ុណ្ណោះ ។ មួយវិញទៀត បើយើងពិចារណាឲ្យហ្មត់ចត់ តាមប្រាជ្ញាបរទេសជាតិរបស់សុភាសិតបរទេស តើ មានចំណងប្លែកខុសពីសុភាសិតខ្មែរយើងដូចម្តេចខ្លះ ?

២. សេចក្តីប្រែពីភាសាបារាំងមកជាខេមរភាសាក្តី សេចក្តីអធិប្បាយ ជាពាក្យកាព្យក្តី នឹងមានល្អៀងឃ្លៀងឃ្លាតខ្លះ ។ ត្រង់នេះយើងសូម

អភ័យទោស ហើយសូមអស់លោកវិញ្ញូជនកែតម្រូវឲ្យមានផងចុះ យើងសូមអរគុណអស់លោកទុកជាមុន ។

ឯសុភាសិតរបស់នានាជាតិ ក្រៅអំពីនេះ យើងពុំនឹងនាំយកមកចុះផ្សាយក្នុងទស្សនាវដ្ដីនេះដែរ កាលបើមានឧកាស ។ ចំពោះសុភាសិតខ្មែរយើង ១ បានបោះពុម្ពផ្សាយរួចមកហើយកាលពីឆ្នាំមុន ៗ នេះ ។

អ្នកអានសុភាសិត ត្រូវប្រែគំនិតបន្តិច ទើបគាប់ប្រាប់រសជាតិរបស់សុភាសិតបាន ព្រោះពាក្យសុភាសិត ដែលអ្នកប្រាជ្ញបុរាណបានបង្កើតទុកមក ច្រើនតែជាពាក្យប្រៀបប្រដូចមិននិយាយចំៗទេ ត្រូវប្រែគំនិតគិតពិនិត្យបន្តិចទើបស្គាល់សេចក្ដីបាន ។

បណ្ណាធិការ

ញុក-ថែម

## សុភាសិតបារាំងសែស

# លោកប៉ាយ-ប៊ុក ប្រែ អធិប្បាយជាពាក្យកាព្យ

ហ្មឺនវិចិត្រមន្ត្រី ញ៉ុក-ថែម ពិនិត្យកែ

---

1— Qui rit Vendredi pleurera Dimanche.

១- អ្នកដែលសើចក្នុងថ្ងៃសុក្រ, មុខជានឹងយំក្នុងថ្ងៃអាទិត្យ ។

"អ្នកសប្បាយប្រែនៗ មានទុក្ខ អ្នកប្រឹងលុយកក់ទើបរុកក៏យ

សង្ខារគាត់តែងតាមវិស័យ សុខទុក្ខចក្រ័យផ្លាស់វេនគ្នា" ។

2— Pauvreté n'est pas vice.

២- សេចក្ដីខ្សត់ក្រ មិនមែនជាអំពើបាបកាចទេ ។

"ក្រទ្រព្យសម្បត្តិមាសកែវកង មារយាទល្អហ្មត់ហ្មង់មិនទាបថោក

បើក្រពាលាលួចប្លន់លោក ហៅក្រឥតជាតខូចកេរ្ដិ៍ឈ្មោះ" ។

3— La fortune sourit aux audacieux.

៣- ជោគវាសនាញញឹមទទួល ចំពោះជនក្លាហាន ។

"វាសនាសព្វសព្ទ ជនណាគប់គាត់ មានមនោក្លាហាន ចិត្តមុត

មាំ: ហ៊ានលះខ្លួនប្រាណ សាងជាតិថ្កើងថ្កាន ដល់បានឥស្សរ" ។

4— Bien mal acquis ne profite jamais.

៤- ទ្រព្យដែលបានមកដោយអំពើទុច្ចរិតមិនដែលចំរើនសោះឡើយ

"ទ្រព្យលួចប្លន់បាន ធ្វើដើមធនធាន រកស៊ីកែខៃ មិនដែលចំរើន

បាត់សូន្យ មុខជាហិនហៃ វិនាសហិនហោច" ។

5— Rien ne sert de courir, il faut partir à point.

៥- សន្សឹមកុំបំពោល ក្រែងពុំដល់ដូចប្រាថ្នា ។

"ការក្រកុំគិតឆ្ងាយ ការសម្លាយជាកំពេល ការប្រញាប់កុំប្រយោល គ្រប់ហ្ថាលមើលឲ្យសព្វគ្រប់" ។

6 — Ne croyez pas aux apparences.

៦- កុំគ្គុតជឿតាមការស្មាន ឬដែលមើលឃើញមិនជាក់ច្បាស់

"យល់ឈើថាខ្មោច ស្មានស្វាថាខ្មោច យល់ក្តោងនារី, ពីឆ្ងាយ លន់លើម សន្សឹមឃ្លាតខ្ចី ចូលចតជិតជី ទើបគួរស្មានយក" ។

7.— Qui trop embrasse mal étreint.

៧- អ្នកដែលស្រវាចបហួសមាឌ ចបមិនជាប់ ។

ពាក្យនេះត្រូវនឹងសុភាសិតខ្មែរថា "ខ្លួនទាបកុំកោះ ដៃខ្លីកុំឈោង [illegible]" ។

8— La force prime le droit.

៨- កំឡាំងខ្លាំងលើសច្បាប់ -

«សម័យបច្ចុប្បន្ន កំឡាំងជាគំនិត ព្រមទាំងអាវុធ យុទ្ធ-គណ្ឌាភា ជាគតយុទ្ធ គម្រប់ចំហក រំលំច្បាប់ម្ចាស់ :

9— La raison du plus fort est toujours la meilleure.

៩- សភាពដែលមានកំឡាំងជាង តែងតែគាប់ប្រសើរជានិច្ច

"អ្នកមានអំណាច អ្នកខ្សោយតែងខ្លាច អំណាចវេស្តា អ្នកឥតតាំង រីទ្វារ ពុំហ៊ានតុះតា ដោយពលវិស័យ ។ មហាប្រទេស

មានវិជ្ជាវិសេស វិសាលខ្លាំងក្រៃ ដោយសារគេជះ តបះថ្វាថ្ងៃ ឮល្បី គេដដែរ ព្រោះមានកំឡាំង ។

10— Le travail est la loi de la nature.

១០ - ការងារជាបញ្ញត្តិ របស់ធម្មជាតិ ។

« កំពិលកាំងផែះ មិនរៀនចំណេះ បេះច្បាប់ធម្មជាតិ ការងារជាច្បាប់ សម្រាប់លោកធាតុ ត្រូវប្រឹងព្យាយាម ទើបជាតិថ្កើងថ្កាន ។

11— Petit ver de terre amoureux d'une étoile.

១១ - ដង្កូវដីតូច ជាប់ចិត្តស្នេហាផ្កាយ - ពាក្យនេះត្រូវនឹងសុភាសិតខ្មែរថា « ខ្លួនទាបកុំគោង ដៃខ្លីកុំឈោង ប្រាថ្នាឧត្តុង្គ », ។ មួយវិញទៀតមានគតិច្បាយថា « ខ្លួនតូចចង់ធ្វើធ្វកជាធំ ជាតិមនុស្សមិនសមចង់ត្រាប់យក្ស ខ្លួនទាលត្រូវកសេដ្ឋីជាក់ ពូជក្អែកប្រែលក្ខណ៍ហៅជាមេហង្ស » ។

12— L'Union fait la force.

១២ - សាមគ្គី ជាកំឡាំង -

« កំឡាំងធំផុត សាមគ្គីមោះមុត ព្រមព្រៀងមូលមួយ កាយវាចាចិត្ត ស្រុះស្រួលជំនួយ ចូលចរជួយ ស្ទួយជាតិដល់ត្រើយ » ។

13 — La jeunesse vit d'espérance, la vieillesse de souvenir

១៣ — ក្មេងរស់នៅដោយសង្ឃឹម ចាស់រស់នៅដោយការនឹកគិត ។

« ពួកយុវជន រស់នៅបច្ចុប្បន្ន ដោយសារសង្ឃឹម អនាគតច្បាស់ ពួកចាស់ញញឹម ព្រឹកព្រានព្រលឹម រស់ដោយនឹកគិត » ។

14— Qui aime bien châtie bien.

១៤ — អ្នកដែលស្រឡាញ់ណាស់ ត្រូវទុក្ខទោសណាស់ ។

“ បើស្រឡាញ់ណាស់ ដល់ពេលព្រាត់ប្រាស កើតទុក្ខជូរចត់ក្រៃ

ក្រៃគិតអនិច្ចំ ទុក្ខកល់ថ្ងៃ ទើបឃើញធម៌ថ្ងៃ ទុក្ខទោសស្នេហា ” ។

15 — Il ne faut jamais vendre la peau de l'ours avant qu'on ne l'ait mis par terre.

១៥ — កុំឲ្យលក់ស្បែកខ្លាឃ្មុំ មុនគេសម្លាប់បានឡើយសោះ ។

“ មិនទាន់ចូលច្បាំងថាមានជ័យ មិនទាន់អាស្រ័យថាឆ្ងាញ់ណាស់

មិនទាន់ត្រូវឆ្នោតគិតសង់ផ្ទះ មេឃស្រឡះធ្លាក់ទឹកបំពង់ពោល ” ។

16— La pierre ni le mot une fois lancés ne reviennent plus.

១៦ — ដុំថ្មសំដីគេបញ្ចេញផុតទៅហើយ មិនដែលវិលត្រឡប់

មកវិញឡើយ ។

“ កុំព្រហាមពាក្យពោលជាឥតផល តែកិច្ចប្រែកល់មិនបានស៊ាយ

ជ័រឃកក្នុងជាទីហ្វាយ និយាយត្រង់ទើបមិនបង់ប្រាក់ ” ។

17— La paresse est la mère de tous les vices.

១៧— កំជិលជាមេបាបធម៌គ្រប់យ៉ាង ។

“ ខ្ជិលបង្អិនលោក ខ្ជិលបានទុក្ខសោក ខ្ជិលអប្បប្រាជ្ញា ខ្ជិលធ្លាក់

នរក ខ្ជិលឥតវិជ្ជា ខ្ជិលចោរសាសនា ខ្ជិលជាតិលិចលង់ ” ។

18-- Diviser puis règner.

១៨ — បំបែកមុនសឹមសោយរាជ្យ

«បើចង់គ្រងរាជ្យ ត្រូវប្រើកលប្រាជ្ញ បំបែកសាមគ្គី កុំឲ្យជនជាតិ
ព្រមព្រៀងគ្នា បង់បាត់សាមគ្គី សឹមឡើងសោយរាជ្យ» ។

19. — Qui n'entend qu'une cloche n'entend qu'un son.

១៩.— អ្នកដែលបានឮគណ្ដឹងតែមួយតែងបានឮសូរសព្ទតែមួយ ។

«កុំជឿពាក្យពោលមកម្ខាងៗ ហេតុផលរឿងនាមគិតឲ្យសព្វ ពិនិត្យ
កើតផ្សេងទើបប្រៀបធៀប ខុសត្រូវសព្វគ្រប់ឃើញទោសគុណ» ។

20.— On a toujours besoin d'un plus petit que soi.

២០.— គេច្រើនត្រូវការនឹងអ្នកតូចជាងខ្លួនគេ

«អ្នកធំត្រូវការពឹងពលអ្នកតូច ពួកជនខ្ពស់ក៏ពឹងពាក់អ្នកទាប
អ្នកមានពឹងអ្នកក្រដោយសភាព ជាទំនៀមរៀងរបតាំងព្រេងនាយ» ។

21. — Bonté vaut mieux que beauté.

២១.— ចិត្តល្អគាប់ប្រសើរជាងរូបល្អ ។

«រូបកាយសម្ផស្ស ណាក៏មិនសំខាន់ យកជាប្រមាណ ប៉ុន្តែឯចិត្ត
ជាដួងវិញ្ញាណ ល្អត្រកបាន ទើបគាប់ប្រសើរ» ។

22. Plus fait douceur que violence.

២២.— សុភាពទន់ភ្លន់ប្រសើរជាងរឹងរូសកាចកាប ។

"កំហែងកំហល់ទល់កំហឹង ប្រកាន់ធម៌គឹងវិនាសប្រាណ កិរិយា ទន់ភ្លន់តាមបុណ្យ ប្រសើរកល្យាណជាងកំហែង" ។

23.— L'œil du maître engraisse le cheval.

២៣.— ភ្នែកចៅហ្វាយធ្វើឲ្យសេះធាត់

"ការយើងពឹងគេ មិនប្រសើរទេ មិនដូចពិត្តា បើយើងពឹងខ្លួន តាមក្បួនលោកថា ប្រសើរថ្លៃថ្លា ជាងការពឹងគេ" ។

24.— Coudre la peau du renard avec celle du lion.

២៤.— ដេរស្បែកចចក ជាមួយនឹងស្បែកសិង្ហ ។

"កំភ្លូកលលាំងឡាយ ខាងនយោបាយ រិះកល្យាណ ពរយោគ ប្រាជ្ញ មួយគិតការ ក្លៀវក្លាបំណាន មួយទៀតកំឡាំង" ។

25.— Ne parlez pas de corde dans la maison d'un pendu.

២៥.— កុំនិយាយពីខ្សែ នៅផ្ទះអ្នកចងក ។

"ប្រយ័ត្នពោលពាក្យ ក្រែងព្រួយលំបាក ដោយសារសំដី ពិត ព្រួសមិនថ្លៃ សំដៃនវប៉ ឥតរឿងអប្រិយ ពីការលំដល់ប្រាណ" ។

26.— Il ne faut jamais jeter des perles aux pourceaux.

២៦ - មិនត្រូវបោះទ្រព្យត្បូងមុក្តាឲ្យសុករឡើយ ។

"ពួជខ្ជិលមិនរៀន គំនិតអៀនប្រៀន មិនចង់សង្វាត ដូចសត្វពាន មិនស្គាល់មណីជាតិ រំលងបួចដល់ខ្នាត បោះលេងជាល្បែង" ។

27 – Le temps perdu ne se retrouve jamais.

២៧ - ពេលដែលខូចទៅ មិនដែលត្រឡប់បានមកវិញឡើយ ។

«យប់ថ្ងៃកន្លង ឥតឈប់ឈរម្តង កងពេលណាមួយ ដូច្នេះត្រូវគិត គំនិតប្រឹងជួយ ទោះប្រាណបានព្រួយ លំបាកម្តេចខ្លា ។

ត្រូវខំប្រឹងធ្វើ កិច្ចការសារពើ សព្វទិនទិវា មាសប្រាក់កែវកង ដែលប៉ងប្រាថ្នា ដោយស្គាល់កាលា ដំឡៃថ្ងៃយប់» ។

28 – Petit à petit l'oiseau fait son nid.

២៨ - សត្វស្វាបសាងសំបុកតាមគ្នាបន្តិចម្តងៗ ។

«ត្រូវសន្សំទ្រព្យ តិចៗ ត្រឡប់ ចំរើនជាគំនរ តក់ៗគង់ពេញ បំពង់រងផង សម្បត្តិស្តុកស្តម្ភ ធ្វើសេដ្ឋីបាន» ។

29 – Si on ne peut avoir ce que l'on aime il faut aimer ce que l'on a.

២៩ - បើគេមិនបានរបស់ដែលស្រឡាញ់ពេញចិត្តទេ គេត្រូវស្រឡាញ់របស់ដែលគេមាន ។

«របស់ដែលមានគាយមិនចង់បាន នៅចង់ប្តូរប្រាណស្វែងលោក ប្រទេសឆ្ងាយជិតប្រើរឹងស្រាក់ ស្រាក់ខុបក្លំមិនដែលថ្មី» ។

30 – A l'œuvre, on connaît l'artisan.

៣០ - គេស្គាល់ជាងដោយសារស្នាដៃ ។

«អ្នកល្បីចង់ត្រាប់ត្បូងបណ្ឌិត អ្នកចេះក្រមក្រិត្យប្រាជ្ញគង់ស្គាល់ អ្នកខ្សោយចង់ត្រាប់អ្នកខ្លាំងដាល់ ជាងទងគង់ពាល់ច្បាប់មាត្រា» ។

(មាឌក)

# រឿងស៊ិន-យ៉ាត់-សេន

# អ្នកនយោបាយឯកជាតិចិន

លោក ក៏យេ-ឌុក ប្រែពីភាសាបារាំង

(តមក)

---

ហេតុខ្ញុំបានជាអ្នកប្រាប់រឿងនេះ ។ តាំងពីនោះឃើញថា គេ ថ្ងៃមុន ពេលយប់មានចោរចូលគាស់ផ្ទាំងទ្វារផ្ទះល្វែងគ្រឿងឈើ ។ ហើយ កាលការគិតពិនិត្យសួររឿងនេះចំពោះអ្នកជាប់ខ្លួន ។ ការនេះទើបបានទៅ ដល់ស្ថានក្រុមតាហានទនគរបាល ផ្សេងៗក៏ឮដូចហើយគេបង្ហាញរឿង ការរបស់ខ្ញុំជម្រាបលោកអ្នកត្រួតត្រាក្រុមព្រៃនគរបាល (Inspecteur dé service) រួចលោកបានអញ្ជើញទៅដល់ទីកន្លែង ស្កុតឡេនយ៉ាដ (Scotland yard) ហើយបានសួរដូចទិន្នន័យពីទីនគរបាល លោកអគ្គត្រួតក្រុម បានទទួលលោកគង់ពន្យល់ស្របតាមនេះហើយ ក៏ស្តាប់សេចក្តីពន្យល់ រឿងការប្លែកអស្ចារ្យ តែលោកនោះគេចង់ដឹងថា រឿងនេះមិនត្រឹមត្រូវ ក្រសួងលោកទេ ។ ហើយលោកនេះក៏ចុះទៅតាមផ្លូវ ពេលនោះមាន មួយព្រឹកគ្នាបានការអ្វីទៀតទេ តាំងពីដើមដល់ចុង ។

ដល់ថ្ងៃស្អែកព្រឹកព្រលឹមលោក ... បានចេញដំណើរទៅកិនស៊ីងតុង (Kansington) ដើម្បីនឹងប្រាប់មិត្តភក្តិរបស់លោក តើគួររឿងនេះត្រូវ សូមឲ្យក្រុមក្រសួងរដ្ឋាភិបាលនៅក្រុងឡុងដ៍ឲ្យជួយនិយាយនឹងពួកមន្ត្រី

ក្រសួងឧត្តមជនូតចិនឬទេ ? - តែរឿងនោះមិនបានសម្រេច លោកកង់ឌី បានត្រឡប់មកកាន់ផ្ទះលេខ ៧ ដំបន់ហង់ល័យសង្វៀមថា ក្រែងបានជួបនឹង ទាហានត្រាន់ស្បូ តើលោកសៀវហាក្ស៊ីដេម៉ាតាន់ទៅទីណា ហើយល្ហម ទីនផ្ញើទូរលេខទៅដល់ឬទេ ។ ក្រៅអំពីរឿងដែលទាហាននោះពណ៌- នាអំពីពោរបួលល្បួមានពាដ្ឋានដរឿងមួយដ៏ជាក់ស្តែងស្រាប់នោះ គ្មានហេតុកេងអ៊ីថ្មក ដើម្បី [illegible] គេហដ្ឋានដែល លោ [illegible] សៀវហាក្ស៊ី- ដេម៉ាតាន់ទៅនៅឡើយ ។

លោកកង់ឌី បានទៅដល់គេហដ្ឋានលោក ព្រះពន្យ៉ុងស៊ុន ហើយ បានជួបប្រទះឈ្មោះគូលនេះទាបួល ។ ឈ្មោះនេះបានប្រឹងប្រមូល ចម្ងាំងកាហាន ដើម្បីនឹងមកជួបនឹងលោកកង់ឌី កង្វល់ហេរឿងជាប់ប៉ុ យ៉ាងនេះ ឈ្មោះ "គូល" បានពន្យល់ថា លោកកង់ឌីមានដំណើរមក កាន់ផ្ទះលោកម៉ុងស៊ុន គាត់ក៏ដេចមកការទទឹកខ្លួននេះ កន្ទុណៈនោះ ឈ្មោះ "គូល" បានបង្ហាញនាមប័ត្រ ២ ដែលខ្ញុំបានសរសេរមកលោក កង់ឌី សេចក្តីក្នុងនាមប័ត្រនោះថា :

"ពីរ ២ នាក់បានតាប់ពីថ្ងៃអាទិត្យមុន ហើយបាននាំខ្លួនមកកាន់ ស្ថានឧត្តមជនូតចិន ខ្ញុំជាប់គុក ប្រហែលជាមួយថ្ងៃពីរថ្ងៃទៀត គេនាំខ្ញុំ ទៅតាមកប៉ាល់ដែលគេដួលកំណត់ថ្ងៃជាស្រេច ហើយខ្ញុំក៏ត្រូវកាត់ សិរសាក្នុងពេលនោះ ទុខ្ញុំលំបាកចិត្តពន់ពេក" ។

លោកគ្រូពេទ្យម៉ង់សុនក៏បានស្រុះចិត្តគំនិតក្នុងការដែលនឹងជួយខ្ញុំឲ្យបានរួចរស់ជីវិតដែរ លោកបានសួរឈ្មោះ «គួល» ក្នុងពេលនោះ លោកគង់ទូំពោលថា "បើលោកសៀវហាល់ដេនៅក្នុងក្រុងស្រួល គួរឲ្យស្តាយណាស់ លោកគួរធ្វើដំណើរទៅបាត់ ឥឡូវមិនដឹងយើងទៅរកឯណាឃើញ" ។

ឈ្មោះ «គួល» ថា: "លោកសៀវហាល់ដេនៅក្រៅក្រុង មួយថ្ងៃ លោកដែលអញ្ជើញមកស្ថានអគ្គរដ្ឋទូត គឺលោកសៀវហាល់ដេនោះ ហើយដែលបានឃុំឃាំងលោកស៊ុនក្នុងបន្ទប់ចាក់សោ ហើយលោកបានឲ្យខ្ញុំយាមនៅមុខទ្វារកុំឲ្យរត់ចេញទៅកើត" ។

ដំណឹងនោះនាំឲ្យងឿងឆ្ងល់ពួកមិត្តភក្តិខ្ញុំដែលយល់ឃើញថារឿងនេះលំបាកពេក ក្រៅពីកន្លែងនេះដោយប្រែប្រួលគ្នាណាស់ — តើយើងត្រូវទៅពឹងពាក់ការមុខ ស្រួចស្តែង ។

ឈ្មោះគួលថា គេបានពោលដោយស្មាន ថាលោកស៊ុនជាមនុស្សឆ្កួត ហើយថាគេនឹងគិតបញ្ជូនទៅប្រទេសចិនថ្ងៃអង្គារក្រោយដែលជាពីរថ្ងៃទៀត — លោកម៉ាក់ក្រេគូរ (Mc Grégor) ដែលនៅក្នុងក្រុងនេះបានជំនួយការរៀបចំការនេះដោយសព្វគ្រប់ — ឈ្មោះ "គួល បាននិយាយមកទៀតថា: " មនុស្សពីរបីនាក់បានស្លៀកពាក់ជាអ្នកដំណើរជិះតាមសមុទ្រ (Marins Chinois) គាត់បានឃើញនៅ

ស្ថានអគ្គរាជទូតពីសប្តាហ៍មុន ប្រហែលជាពួកនេះមានហេតុទាក់ទងនឹង រឿងរបស់ខ្ញុំ ដោយគាត់មិនដែលឃើញមនុស្សប្លែកបែបនេះមកនៅក្នុង ទីនេះទេ" ។

គេបានឲ្យឈ្មោះ "កូល" ជាកសិបុត្រចុះហត្ថលេខាលោកគ្រូ ពេទ្យទាំងពីរនាក់មកឲ្យខ្ញុំ ដើម្បីនឹងឲ្យខ្ញុំមានសង្ឃឹមហើយនឹងជឿជាក់ ថាបម្រើនេះធ្វើការប្រយោជន៍ឲ្យខ្ញុំដោយពិត ។ លោកគ្រូពេទ្យទាំងពីរ នាក់បានធ្វើដំណើរទៅស្កតឡែនយ៉ាងដូច្នេះទៀត ដើម្បីនឹងកែយោបល់ការ ផ្ទះនោះ ។ អ្នកត្រួតត្រាក្រមប្រឹក្សាប្រាប់ថា:

"ផ្ទះបានអញ្ជើញមកទីនេះពីម៉ោងទី ១២ កន្លះមុនខ្ញុំយល់ឃើញថា គ្មានប្រយោជន៍អ្វីនឹងមកកាន់ទីនេះម្តងទៀតឡើយ ការដែលលំបាកនោះគឺ ត្រូវគោរពក្រសួងណាដែលមានមុខការសម្រេចពីស្ថានការណ៍មនុស្ស បែបនេះ ដើម្បីនឹងកំចាត់ពួកដែរ ពួកទាំងនេះ ជាពួកទទឹងនឹងច្បាប់ សម្រាប់ប្រទេស ហើយជីវិតមនុស្សម្នាក់នឹងអស់ហាដាក់ការនៅក្នុង "ចក្រភពព្រិតានិក" (Empire britannique) ។

មិត្តរបស់ខ្ញុំទាំងពីរនាក់បានអញ្ជើញទៅកាន់ក្រសួងការបរទេស ។ នៅទីនោះគេចេញដំណឹងប្រាប់លោកថា ម៉ោង ៤ មានមន្ត្រីម្នាក់មកសុំជួបនឹង លោក ដល់ពេលម៉ោងដែលកំណត់ មានមន្ត្រីម្នាក់ចូលមករកលោក ក៏អធិប្បាយរឿងការសព្វគ្រប់ តែក្នុងវេលានោះជាថ្ងៃអាទិត្យមន្ត្រីនោះថា

ឲ្យលោកគេញ៉ែញមកស្អែកជម្រាបថា ហ្វាយខ្ញុំឲ្យលោកបានប្រាប់ផង ។ តែពេលវេលានេះតែរត់ហួសទៅមិនឈប់ តើទីងគិតធ្វើយ៉ាងណាទៀត? មិត្តខ្ញុំគិតបុងក្រោយបន្តិសថា បើគេនាំខ្ញុំទៅតាមតាក់មុន លោកចាំងពីរក៏បានប្តឹងរកផកាមុខក្រសួងផល់ព្រែកជីកស៊ុយអេ គេអាចបញ្ឈប់កប៉ាល់ ហើយត្រួតត្រាមើលខាងក្នុងកប៉ាល់នោះបាន បើគេនាំខ្ញុំមកជាមួយកប៉ាល់ជាការដែល សេចក្តីសង្ស័យនោះ ទៅជាឥតប្រយោជន៍ ។

ដោយខ្លាចក្រែងការនោះពុំបានសម្រេច ពួកម្ហូតក៏គិតបានសម្រេចជាដាច់ខាតថា ទីងទៅកេស្តានអគ្គកុងស៊ុលចិន ហើយនិយាយទៅទីងពួកចិនថា លោកបានប្រាប់ថាឈ្មោះ ស៊ុន នៅជាប់ឃុំឃាំងនៅទីនេះ ហើយថា រដ្ឋាភិបាលអង់គ្លេស ទីងក្រុមគ្រួសារបានដឹងដំណឹងអ្នកឯង ដែលបម្រុងនឹងបញ្ជូនឈ្មោះនេះទៅប្រទេសចិនដើម្បីនឹងប្រហារជីវិតបង់ ។ លោកគ្រូពេទ្យម៉ងសុងចេញទៅថ្លែងការណ៍តែម្នាក់ឯងអំពីរឿងនេះដោយហុចលំឃើញថា នៅស្ថានអគ្គកុងស៊ុលចិន គេស្គាល់លោកគ្រូ [illegible] ប្រាកដ —

លោកគ្រូពេទ្យ ម៉ង់ស៊ុង [illegible] ទៅដល់គេហដ្ឋានលេខ ៤៩ ចិចខ៍ប៉ាត្តិដ [illegible] មុខទ្វារ លោកក៏បានប្រាប់ទៅ [illegible] ម្នាក់ដែលជាអង់គ្លេស - បន្តិច

ទៀតគ្មានអ្នកបកប្រែជាតិចិនម្នាក់ចេញមក ពីចិនតាំងដែលបានចាប់ធ្វើបាបខ្ញុំ ។

លោក ម៉ង់ស៊ុន ប្រាប់ទៅចិនតាំងថាលោកឈប់ជួលផ្ទះទឹងលោកស៊ិន-យ៉ាត់-សេន ។ នៅមុខចិនតាំងមានភាពថា ធ្ងឹងធ្ងល់ហើយធ្វើដូចជាគិតរឿងដែលគន្លងទៅហើយ ។ ស៊ិន! ស៊ិន! គ្មានអ្នកណានៅទីនេះឈ្មោះយ៉ាំងជួបនេះទេ ។ លោកត្រូវពន្យល់ចិនតាំងថា គេបានឲ្យដំណឹងលោកដោយច្បាស់លាស់ថា ឈ្មោះស៊ិននៅទីនេះ ហើយលោកបានមកដល់ដោយលោកបង្រៀនគេផងនេះ លោករដ្ឋមន្ត្រីក្រសួងការប្រទេសគង់តែសុខប្រាប់ជាថារឿងនេះ ត្រូវ តែឲ្យឈ្មោះយោបាយចិនប៉ុនប្រសប់ខាងក្លែងក្លាយ ហើយក្នុងការសម្ភាសពេលនោះ ដាច់ខាតសម្ដីដែលត្រូវចិនតាំងយោគពាក្យក្លែងក្លាយ ។ ចិនតាំងបានទទួលការឲ្យលោកម៉ង់ស៊ុនជឿជាក់ថា នៅទីនេះ មិនដែលមានឈ្មោះ ស៊ិនទេ ចិនតាំងបានបញ្ចេញភាព[illegible]នោះ ទាល់តែធ្វើឲ្យលោកត្រូវម៉ង់ស៊ុន ជឿជាក់សំដីដែលនិយាយ ។ ដល់លោក ម៉ង់ស៊ុន ត្រឡប់មកដល់ផ្ទះលោកចន្ទ្រី ក៏គិតថារឿងក៏ដែលគេចាប់ខ្ញុំទៅឃុំឃាំងនៅស្ថាន[illegible]ចិនជាយោបាយដែលខ្ញុំពោលដើម្បីមិនសម្រេចកិច្ចក្រសួងប៉ាំងដែលនោះមិនប្រាប ។ នេះហើយជាស្នាដៃចិនតាំង ដែលចេះប្រសប់ខាងក្លែងក្លាយទាល់តែធ្វើឲ្យលោកត្រូវម៉ង់ស៊ុន ដែលចេះភាសាចិន

អាម៉យ (Amoy) ហើយស្គាល់ចំនៀមទម្លាប់ចិនភាពកិរិយាចរិតជាងពួកអង់គ្លេសដែលបានមកឃើញ បូព៌ាប្រទេសក្នុង ១០ មាន ៩ ភាគ ។ រួចលោកក៏បានបោះបង់ពោលគំនិតនោះភ្លាម ។

## ព្យាយាមរកពួកចារបុរស (DÉTECTIVE)

លោកកង់ឌី បានចេញពីគេហដ្ឋានម្ដងទៀត ហើយគិតរកឧបាយ ទីឃាមឃ្លាំមើលស្ថានអគ្គរាជទូតចិន ។ លោកបានទៅរកមិត្តលោកមួយនាក់ ហើយក៏បានជ្រាបថាមន្ទីរចារបុរសក្រៅរាជការហៅថា ស្លាតែរ (Slater) លោកបានអញ្ជើញទៅដល់ទីនោះ បានឃើញទ្វារមន្ទីរបិទ ។

ដោយឃើញស្ថានភាពយ៉ាងនេះប្រហែលជាគេមិនត្រូវការពួកចារ-បុរសថ្ងៃអាទិត្យទេ - ប្រហែលជាក្នុងថ្ងៃនោះគ្មានបណ្ដាលអ្វីឡើយ នៅប្រទេសអង់គ្លេសគេ ត្រូវដឹងថាការបែកនៃភាពអំពើពិក្ខមនុស្ស ហើយពួកប្រព្រឹត្តបទឧក្រិដ្ឋមិនបានកើតថ្មីទេ ។ តែត្រូវឲ្យយល់ថាក្នុងពេលនោះមន្ទីរស្លាតែរ បិទទ្វារ-ហៅក៏មិនឆ្លើយ ចុចកណ្ដឹងក៏មិនឮ គោះទ្វារផ្ទះដែលនៅផ្លូវ បាស៊ីងហាល្ល (Rue Basinghall) ក៏ឥតប្រយោជន៍ ។

មានពាក្យបុច្ឆាវិសជ្ជនាដោយតាមផ្លូវពួកក្រុមក្រមនគរបាល ទីឯនាយសារថីមួយ ដែលបានឮរឿងដែលចាប់ខ្លួនមកឃុំឃាំងនៅស្ថានអគ្គរាជទូត ។

(នៅមានតទៅទៀត)

លោកគង់ឌី បានសួរទៅតម្រួតថា : "បុគ្គលនោះគេឃុំឯណា? តម្រួតក៏ឆ្លើយតបវិញថា ជំពង់បារត្រូវជិតខាងលិច លោកអញ្ជើញមកទីនេះ មិនបានការទេ - លោកត្រូវតែអញ្ជើញទៅខាងលិចក្រុង - ចំណែកយើងគឺធ្វើការខាងក្រុមតម្រួតនគរបាលក្រុងធំ ។

ដូចជាលោកគង់ឌីគិតមែន ក្រុមតម្រួតនគរបាលខាងកើតឬខាងលិចមិនចង់ធ្វើការអ្វីឡើយ?

តែលោកគង់ឌីតបទៅវិញថា តើល្មមរកពួកតារបុរសម្នាក់ដើម្បីនឹងត្រួតឃ្លាំមើលស្ថានអគ្គរាជទូតចិននេះបានឬទេ?

ទេ - ពួកតម្រួតនគរបាលក្រុងមិនមានសិទ្ធិចាត់ការ ខាងរឿងរ៉ាវដែលមានក្នុងខាងលិច ។

អ្នកឯងមិនមានពួកតម្រួតចាស់ ឬ មនុស្សទំនេរដែលចង់បានប្រាក់ ដោយជួលធ្វើការបែបនេះឬទេ?

ប្រហែលជាមាន ក្នុងខណៈនោះមានមនុស្សជាច្រើនចូលមកជជែករឿងនេះខ្ញុំប្រាប់ឈ្មោះតារបុរសម្នាក់ដែលល្មមធ្វើការនេះបាន ។

តើមនុស្សនោះនៅទីណា?

មនុស្សនោះនៅ លីយតុនស្តូន (Leytonstone) អ្នកឯងចង់ជួបយប់នេះមិនបានទេ ពីព្រោះថ្ងៃនេះជាថ្ងៃអាទិត្យ ដល់ជជែកគ្នាយូរ

ទៅគេគិតយកមនុស្សម្នាក់ផ្សេងដែលនៅស្គួនស៊ុបតុនក្នុងភូមិអិសលាំងតុន (Square Gibbton à Islington) ។

តែមុននឹងទៅជួបនឹងចារបុរសនោះ លោកកង់ទ្ទីបានសម្រេចថា ត្រូវផ្សាយពត៌មានក្នុងកាសែតសិន ។ ទើបលោកទៅជួបបណ្ណាធិការកាសែតតៃម៍ (Times) គេបានឲ្យនាមប័ណ្ណមួយឲ្យលោកសរសេរ លោកក៏សរសេរថា "រឿងគេចាប់មនុស្សទៅឃុំឃាំងនៅស្ពានអគ្គាជន្ទុតចិន" ពេលនោះ គឺម៉ោង ៩ ល្ងាច ហើយគេដំកប់លោកថាប្រហែលជា ម៉ោង ១០ បានមានមនុស្សមក ។

លោកក៏អញ្ជើញទៅឯអិស្លីងតុនដើម្បីនឹងរកមនុស្សនោះ ដល់បន្តិចទៅលោកបានឃើញស្គួននោះជាធម្មតាក្លឹងក្លីត្រឹមៗ ហើយបានរកមើលលេខផ្ទះ ក៏ចូលទៅរកឈ្មោះនោះៗ ថាមិនមែនមុខក្រសួងខ្ញុំទេតែខ្ញុំស្គាល់គ្រូគម្រែមម្នាក់ដែលគាប់ទទួលការៈនោះបាន ។

ដល់ស៊ើបរកបន្តិចគេបានឃើញផ្ទះ តែគម្រែមនោះមិននៅក្រៅទៅយាមផ្ទះ នៅក្នុងក្រុង ។

បន្តិចទៀតលោកត្រូវទៅដល់ឈប់ជិតផ្ទះនោះ ហៅភូមិបារប៊ីកង់ (Barbican) ហើយគេក៏ត្រែកត្រាទីកន្លែងមើលថា មិនឃើញមានគម្រែមយាម ។ គេហៅនោះត្រូវបិទទ្វារ ម៉ោង ១១ ប្រហែលជាគម្រែមនោះចេញទៅហើយ ។ ក្នុងពេលនោះលោកកង់ទ្ទីបានអញ្ជើញ

ទៅកាន់កងកាសែត "តៃម៍" គេបានទទួលសេចក្ដីរាយការរឿងនេះពីលោកហើយ ចុះព័ត៌មានត្រឡប់មកវិញម៉ោង ១១ កន្លះ ថ្ងៃអាទិត្យល្ងាច លោកគ្រូពេទ្យត្រឡប់ទៅផ្ទះវិញ លោកមានចិត្តព្រួយបារម្ភថាពាក់កណ្ដាលអធ្រាត្រហើយកម្មករក៏មិនឃើញត្រឡប់មកវិញ - តែលោកមិនលះបង់ការដែលលោកបម្រុងនឹងយាមល្បាតដោយខ្លួនលោកនៅស្ពានអគ្គកជទ្ចតបិននោះ ។

ដល់លោកកំពុងដើរតាមផ្លូវ, លោកគ្រូពេទ្យបានប្រទះកម្មករដែលរតពីថ្ងៃមុន លោកក៏ចាត់កម្មករនោះឲ្យយាមល្បាតនៅទីនោះ ។ បន្ទប់ស្ពានអគ្គកជទ្ចតបិន ពិតមែនតែយប់ជ្រៅ តែនៅភ្លឺនៅឡើយគេមើលទៅឃើញក្នុងមន្ទីរ មានមនុស្សបុះឡើងដោយប្រហែលជាព្រួយបារម្ភ នឹងសំដីលោកគ្រូពេទ្យ "ម៉ងស៊ុង" ថាពពួកការអង់គ្លេសបានជ្រាបសេចក្ដីអយុត្តិធម៌ នៃមន្ត្រីក្រសួងអគ្គពជទួត កម្មករនោះគេឲ្យជិះទេះសេះខាងត្បូងផ្លូវដឺសៃមុត (de Xeymouth) កន្លប់គេហដ្ឋាន, រត់ងជំបន់ប៉ាត្ងដ៏ទីងផ្លូវប៉ាត្ងង់ ដោយព្រះចន្ទពេញបូណ៌មី កម្មករអាចមើលឃើញទ្វារទាំងអស់ត្រីហាអគ្គពជទួតបាន ព្រោះទេះសេះនោះអាចមានប្រយោជន៍ក្នុងការជួយសង្គ្រោះខ្ញុំឲ្យរត់ផុតពីជើងមនុស្សដែលត្រូវការដេញតាមខ្ញុំ ។

ដល់ម៉ោងពីរព្រឹក លោកគ្រូពេទ្យបានត្រឡប់ទៅទទួលទានដំណេកឯគេហដ្ឋានវិញ លោកបានជំពបរជ្ជកិច្ចការនឹងក្រុមកម្មករ·

បាល ចុះពត៌មានកាសែត អំពីរឿងនេះ លោកគិតថាការលោកអស់ ហើយ ខ្ញុំមុខជារស់រួចជីវិត ពិតមែនតែខ្ញុំមិនអាចដឹងអ្វីសោះ ។

## ការប្រស្រ័យនឹងរដ្ឋាភិបាលអង់គ្លេស

លុះដល់ថ្ងៃច័ន្ទ ១៩ ខែឧក្តូប្រ៍ សម្លាញ់ខ្ញុំភ្នាក់ទៅសួរគេតាប៉ុស នៅមន្ទីរ "ស្កាតែរ" បានជួបនឹងតាប៉ុសនោះ លោកក៏បានចាត់ឲ្យឃ្លាំមើលស្ថានអគ្គរាជទូតចិន ។

ថ្ងៃក្រោយទៅ ហ្វរេញអុហ្វិស (Foreign Office) លោកផងខ្ញុំបានធ្វើរបាយការជូនក្រសួងការបរទេស មានប្រាថ្នាចង់ឲ្យការដែលជួយសង្គ្រោះលោកស៊ុន-យ៉ាត់-សេន កុំឲ្យមានបញ្ហាពាក់ព័ន្ធនឹងក្រសួងនេះ ដើម្បីនឹងការពារខ្លួនពីឧប្បត្តិហេតុដែលកើតមានរវាងប្រទេស ។

ដោយការជាប់ឃុំ ខ្ញុំឮតាមពាក្យចចាមអារាម ក្រសួងនោះមិនអាចនឹងធ្វើឲ្យមានរឿងនយោបាយផ្ទុះផ្ទុលឡើងដោយគ្មានភស្តុតាងសោះ ដើម្បីនឹងឲ្យមានសំអាងគេបានស៊ើបសួរនាវាដែលបានដើរតាមផ្លូវសមុទ្រគ្លែន (ligne de navigation Glen) ហើយគេបានដឹងច្បាស់ថាមានកប៉ាល់មួយមានគេជួលទុក ព្រោះហេតុដូច្នេះ រដ្ឋាភិបាលមានភស្តុតាងនាំឲ្យយល់ច្បាស់ថា សេចក្តីរបាយការ (rapport) លោកគ្រូពេទ្យនេះពិត ហើយគេអាចសំគាល់ថា ជាបឋមកិច្ចក្នុងការបញ្ជូនខ្ញុំទៅប្រទេសចិន

វិញ តាំងពីនោះមក រឿងនេះធ្លាក់ទៅលើរដ្ឋាភិបាលសម្រេចសេចក្ដី ទទួលខុសត្រូវទាំងអស់ ។

រាជការមុខក្រសួងបានចាត់ឲ្យមានចារបុរស (détective) ៦ នាក់ ដើម្បីនឹងឃ្លាំមើលជុំវិញគេហដ្ឋានអគ្គរាជទូតចិន ហើយបានបង្គាប់ទៅក្រុមតម្រួតនគរបាលនៅជិតខាងឲ្យជួយខ្នះខ្នែងក្នុងការនេះ ។

ថ្ងៃព្រហស្បតិ៍ ២២ ខែ១កតូប្រ៍ ពេលរសៀលមានអ្នកផ្សាយតំណាងខាងកាសែត គ្លុប (Globe) បានមកជួបលោកកង់ទ្ទីនៅគេហដ្ឋាន ហើយក៏បានសួរលោកពីរឿងដែលគេចាប់ឃុំឃាំងមនុស្សម្នាក់ នៅស្ថានអគ្គរាជ-ទូតចិន ។ លោកគ្រាន់តែពោលតបវិញថា លោកបានជួបពត៌មានរឿងនេះទៅកាសែត "តៃម៍" ពីថ្ងៃ ១៨ ១កតូប្រ៍ ហើយបានបន្ថែមសេចក្ដីថា: កាសែតនេះពីថ្ងៃចន្ទ ១៩ លោកក៏ត្រូវឲ្យកាសែត "តៃម៍" ចុះផ្សាយជាបឋម តែលោកកង់ទ្ទីបានពោលទៅកាន់អ្នកផ្សាយកាសែត "គ្លុប" ថា: សូមលោកមើលសេចក្ដីដែលលោកបានសរសេររឿងនេះ ហើយខ្ញុំនឹងជំរាបកើតជាពិតឬទេ ? លោកបានស្ដាប់សេចក្ដីពណ៌នាក៏យល់ថាជាការណ៍ពិត លោកអនុញ្ញាតឲ្យចុះ តែហាមកុំឲ្យដាក់ឈ្មោះលោក ។

ដល់កាសែត "គ្លុប" ផ្សាយរឿងនេះប្រហែលជាពីរម៉ោង ក្រោយមកមានពួកកាសែតពីនាក់ទៀត គឺកាសែតសង់ត្រាល់នៃវស៍ (Central

Neus) និងដេលីមេល៍ ( Daily Mail ) បានបបួលមកជួបនឹងលោកកង់ទូ១ក៏បានពណ៌នារឿងជាទុកល់សព្វគ្រប់ ។

មនុស្សទាំងពីរនាក់បង់កេសេបក្ដិត បានចូលទៅសួរខាងមន្ទីរអគ្គរដ្ឋទូតចិន សូមជួបនឹងឈ្មោះ ស៊ុន ។ អ្នកទាំងពីរស្រាប់តែប្រទះនឹងចិនគាំង១ បានបដិសេធថាមិនស្គាល់ឈ្មោះស៊ុន ។ មានខ្លះបានយកកាយការកាសែត "គួប" ទៅបង្ហាញចិនគាំង១ក៏សើចហើយពោលថា រឿងនេះករកួតកុហកទេ តែបណ្ណាធិការកាសែត "សង់ត្រាល់នៃវស៍" គបថាកុំឯងកុហក បើពុំលែងឈ្មោះ ស៊ុនទេ ស្ថានអគ្គរដ្ឋទូតមុខជាមានមនុស្សទាំងពាន់ចូលមកតវ៉ារឿងនេះមិនខាន ពាក្យទាំងប៉ុន្មានឥតមានធ្វើបិត្តចិនគាំងឲ្យតក់ស្លុតរន្ធត់អ្វីឡើយ ឈ្មោះនេះរឹតតែកុហកថែមទៀត ។

គេបានរកលោកសៀវហ្ស៊ីដេម៉ាការទិនៅការិយដ្ឋានមីដល័ងដ៍ ហើយគេបានសន្ទនាជាមួយនឹងលោក ។ ពាក្យឆ្លើយលោកសៀវហ្ស៊ីដេម៉ាការទ៍បានចុះផ្សាយកាសែតជាដូចនេះ

## ការសន្ទនាជាមួយនឹងលោកសៀវហ្ស៊ីដេម៉ាការទី

"លោកសៀវហ្ស៊ីដេ មន្ត្រីប្រឹក្សាស្ថានអគ្គរដ្ឋទូតចិន ពីម្សិលមិញ នៅឯបីកនូវៈរសៀល, បានអញ្ជើញទៅកាន់ក្រសួងការបរទេសកងការសន្ទនាជាមួយនឹងពួកតំណាងកាសែត លោកសៀវហ្ស៊ីដេថា-ខ្ញុំមិនអាចជំរាបលោកអ្នកអំពីកិច្ចការស្នាក់ស្នាមរូបកាយមនុស្ស ដែល

ជាប់ឃុំឃាំងនោះ ក្រៅពីពតិមានការសែតទេ គេបានតបមកវិញថា ក្រសួងនានា ប្រទេសបានបង្គាប់ទៅលោកឡត សាលីស្បេរី (Lord Salisbury) ឲ្យបង្គាប់ស្ថានអគ្គរាជទូតចិនឲ្យដោះលែងអ្នកដែលជាប់ឃុំឃាំងជាតិចិនជាប្រញាប់ ៗ សៀវហាល្វីវេមិនដឹងជានិយាយយ៉ាងណា ក៏ឆ្លើយទៅវិញថា មនុស្សនោះត្រូវដោះលែង តែកិច្ចការដែលធ្វើ ត្រូវស្ថានអគ្គរាជទូតនេះមានសិទ្ធិសម្រេចបានតាមសេចក្ដីយល់ឃើញ" ៗ,

ក្នុងឱកាសដែលសន្ទនាជាតំរប់ពីរដង នឹងអ្នកតំណាងការសែត លោកសៀវហាល្វីវេមានការទីបញ្ជាក់ថា "ស៊ុន-យ៉ាត់-សេន មិនមែនឈ្មោះមនុស្សដែលជាប់ឃុំឃាំងទេ យើងបានយកការសព្វគ្រប់ ហើយយើងបានឃើញឈ្មោះនេះប្រព្រឹត្តបទទុច្ចរិត តាំងពីគាត់បានមកដល់ប្រទេសអង់គ្លេសគាត់បានមកដោយចិត្តឯងនឹងស្ថានអគ្គរាជទូតចិន គឺមិនមានអ្នកណាបង្ខំ ឲ្យគាត់មកទីនេះទេ គឺជាការធម្មតាចំពោះជាតិចិនដែលនៅម្នាក់ឯងក្នុងក្រុងឡុងដ្រ៍ តែងមកសួរដំណឹងសព្វគ្រប់នៅទីនេះ ឬជជែកលេងនឹងពួកពលរដ្ឋដែលនៅស្រុកជាមួយយើង មានហេតុល្មមឲ្យសង្ស័យឈ្មោះនេះបាន ដែលស្មានថាគ្មានអ្នកណាស្គាល់ខ្លួនចង់មកយកការពើត្រមពួកយើងនៅទីនេះ កាលដែលឈ្មោះនេះចូលមកដល់ស្ថានអគ្គរាជ-ទូតគ្មានអ្នកណាស្គាល់ទេ ហើយឈ្មោះនេះបានសន្ទនាជាមួយនឹងមនុស្សម្នាក់នៅទីនេះ គេក៏នាំមកបង្ហាញខ្ញុំ យើងបាននិយាយគ្នាទៅវិញទៅមក

ហើយមានពាក្យខ្លះដែលនាំឲ្យខ្ញុំមានសន្និសសង្ស័យថា ប្រហែលជាមនុស្សដែលគេប្រាប់ ឲ្យយើងត្រួតត្រាមើល សេចក្ដីសង្ស័យនោះនៅជាពិត ឈ្មោះនេះត្រូវគេចាប់ថ្ងៃក្រោយ ដល់គាត់ត្រឡប់មកពីនេះម្ដងទៀត សព្វថ្ងៃគាត់នៅជាប់ឃុំដោយមានបង្គាប់ពីរដ្ឋាភិបាលចិន សំដែងច្បាប់អន្តរប្រទេស (droit international) លោកសៀវហាល្វីដេថា: មនុស្សនោះមិនមែនជាតិអង់គ្លេសទេ គឺជាតិចិន ហើយមានតែរដ្ឋមន្ត្រីចិនមានសមត្ថភាពខាងផ្លូវតុលាការ បើជាតិចិនណាមកដល់វានេះ បើមានគេចោទប្រកាន់ ឬមានសង្ស័យពីប្រព្រឹត្តបទអ្វី យើងហាមឃាត់មិនឲ្យពួកអ្នកបរទេសចូលមកតវ៉ាពីរឿងឃុំឃាំងនេះឡើយ បើឈ្មោះនេះនៅក្រោមទីនេះ យើងនឹងចាប់ខ្លួនបានលុះត្រាតែមានអនុញ្ញាតពីរដ្ឋការប្រិតានិក (Britannique) ពីព្រោះនៅក្នុងភូមិភាគប្រិតានិក (អង់គ្លេស) -"

លោកសៀវហាល្វីដេ, ដោយមានមនុស្សខ្លះសួរទៀត, ក៏ឆ្លើយតបមកវិញថា: បុគ្គលនេះមិនមែនយើងទុកដូចជាមនុស្សជាប់គុកទេ គឺយើងបានថែទាំក្សេមដូចមនុស្សធម្មតា លោកសៀវហាល្វីដេមិនយកចិត្តទុកដាក់បន្តស្ដាប់ពត៌មានក្នុងកាសែត "អំពីរឿងដែលពួកខាងស្ថានអគ្គរាជទូតមិនបានធ្វើការណាកម្មចំពោះទៅលើមនុស្សដែលឃុំឃាំងនោះ លោកបានពោលតទៅទៀតថា មន្ទីរអគ្គរាជទូតមិនបានទទួលលិខិតមួយពីហូរេញណ៍ហ៊ុសអំពីរឿងនេះហើយ ។ (មានត)

# ប្រវត្តិសាស្ត្រប្រទេសចិន

ហ្វុងមិត្តនូមន្ត្រី ញ៉ុក-ថែម ប្រែរៀបរៀង

## អំពីប្រវត្តិសាស្ត្រសាកល

(តមក)

ហើយបានកំទេចកងទ័ពតួកមួយពួកខាងដែនអិលី ដែលព្យាយាមតាំងរាគអំណាចឡើងក្នុងតំបន់នោះ ប៉ុន្តែមានពួកតួកមួយពួកទៀតមានប្រមុខឈ្មោះមេបួអ៊ិជួបពោលរួចហើយត្រឡប់ជាសត្រូវដ៏ក្លៀវក្លាសាហាវនឹងប្រទេសចិន ក្នុងឆ្នាំពុទ្ធសករាជ ១២៣៩ និងក្នុងឆ្នាំពុទ្ធសករាជ ១២៤៩ មេបួអ៊ិលើកទ័ពលុកលុយចូលមកតាំងនៅក្នុងខេត្តបាន-ស៊ីនិងប៉េជិលី ហើយបានលើកទៅវាយទ័ពចិនបែកម្តងក្នុងខេត្តហូន-ហ្វូង ទើបលុកទន្ទ្រានចូលមកដល់ខេត្តកាន-ស៊ូ ។

នេះហើយគឺសភាពហេតុកើតដែលមាននៅក្នុងខណៈ ដែលព្រះបាទមិង-ភ៊ុំងឡើងគ្រងរាជសម្បត្តិ ប្រសាស នាបាយជ័យជូនរបស់ព្រះអង្គក៏គិតធ្វើបង្ក្រាំងនឹងមេបួអ៊ិឲ្យដាច់ស្រេច ។ ក្នុងឆ្នាំពុទ្ធសករាជ ១២៥៩ ពួកកងទ័ពចិនមានជ័យជំនះហើយបានកាត់យកក្បាលរបស់មេបួអ៊ិ ទៅថ្វាយដល់ព្រះបាទមិង-ភ៊ុំងផង ។ មេតិលៀមជាបុត្រប្រុសរបស់មេបួអ៊ិ ក៏ព្រមនៅក្រោមចំណុះក្រុងចិនដោយស្មោះត្រង់តមក ។ ក្នុងឆ្នាំពុទ្ធសករាជ ១២៨៨ ពួកតួកខាងអាគេនក៏ត្រូវប្រាប់ព្រមឲ្យនៅក្រោមអំណាចចិន

យ៉ាងកបតាប ការដែលចិនបានប្រាប់ប្រាមសម្រេចទៅបាននោះនាំឲ្យមានភ័យដល់ប្រទេសទីបេ ហើយក្នុងវេលានេះ ពួកអារ៉ុបនឹងពួកសាសនាឥស្លាមបានវាយទន្ទ្រានចូលប្រទេសឥណ្ឌា បានចូលមកតាំងនៅខាងត្រង់ស្រុកសៀន ទើបពួកទីបេតបរទៅរួមកម្លាំងគ្នានឹងអារ៉ុបសម្រាប់ច្បាំងតស៊ូនឹងក្រុងចិន ទុកជាចំផ្ដើដូច្នេះ ក៏នៅតែបរាជ័យក្រុងចិន ទើបអំណាចចិននៅទួរគីស្ដង់ទិសខាងកើតក៏ត្រឡប់មានឡើងវិញម្ដងទៀត ។

កាលបើបានប្រាប់ប្រាមទួរគីស្ដង់នៅទិសខាងកើតបានហើយ ប្រសាសនោបាយរបស់ព្រះបាទ មិង-ហ៊ុង ក៏មានទំនងដូចជាក្សត្រចិនមុន ៗ នេះដែរ គឺនឹកមកផ្សាយអំណាចក្នុងដែនដីកណ្ដាលទ្វីបអាស៊ី ជិតចូលមកប្រទេសឥណ្ឌា ក្នុងវេលានេះពួកឥស្លាមកំពុងលុកលុយទន្ទ្រានយកដែនដីឥណ្ឌា ហើយពួកក្សត្រឥណ្ឌាមិនមាននរណារឹងប៉ឹងខ្លាំងពូកែល្មមនឹងតស៊ូបាន ហេតុនេះ អាណាចក្រតូចៗនៅតំបន់នោះមានសង្ឃឹមតែពឹងបុណ្យរបស់កូនវង្សថាំងប៉ុណ្ណោះ ។ មួយវិញទៀត ដែនដីជាច្រើនអន្ទេកនៃអាស៊ីកណ្ដាលធ្លាប់នៅក្នុងអំណាចចិន ស្របក្នុងពេលដែលពួកឥស្លាមលុកលុយចូលមកនេះ ចិនក៏នៅមានអំណាចត្រួតត្រាស្រុកទេសអស់នោះជាច្រើនអន្ទើ ដោយហេតុនេះហើយបានជាចិនមិនព្រមឲ្យជាតិឥស្លាមចូលមកមានអំណាចក្នុងដែនដីចំណែកនេះ ទើបចាប់ផ្ដើមត្រៀម

នឹងជាតិឥស្លាមយ៉ាងខ្លាំង តែពួកឥស្លាមមានកំឡាំងរឹងប៉ឹងដោយអំណាច មានទឹកចិត្តជឿជាក់ក្នុងព្រះមាហាម៉ុត បានច្បាំងតស៊ូបំផ្លាញកងទ័ពចិនក្នុងតំបន់អស់នោះបាក់បែកអស់ទៅ ក្នុងរវាងពុទ្ធសករាជ ១២៩៤ អំណាចចិនក៏ផុតរបូតអស់ទៅនៅក្នុងអាស៊ីកណ្ដាល ។

ការដែលចិនអស់អំណាចក្នុងអាស៊ីកណ្ដាលនេះ ជាថ្នាក់ដំបូងដែលនាំឲ្យព្រះរាជវង្សថាំង ដល់នូវសេចក្ដីវិនាសសាបសូន្យក្នុងកាលជាលំដាប់តទៅ ។

វគ្គទី ៦

## អវសាននៃព្រះរាជវង្សថាំង

តាមធម្មតា គ្រប់ប្រទេស គ្រប់យ៉ាង គ្រប់ប្រការ តែមានសេចក្ដីចំរើនដល់ខ្ពង់ខ្ពស់បំផុតហើយ តែងតែមានសេចក្ដីទ្រុឌទ្រោមសាបសូន្យទៅវិញ រាជវង្សថាំងក៏មានទំនងដូចគ្នាដែរ ប៉ុន្តែរាជវង្សនេះបានធ្វើសេចក្ដីចំរើនរុងរឿងដល់ប្រទេសចិនយ៉ាងធំក្រៃលែង ទាំងបានឲ្យអំណាចនិងអារ្យធម៌ដល់ប្រទេសជាតិចិនយ៉ាងខ្ពង់ខ្ពស់ ទើបគួរតែថ្លែងរឿងរ៉ាវអំពីហេតុនៃសេចក្ដីសាបសូន្យរបស់រាជវង្សនេះដោយពិស្ដារតាមសមគួរ ។

ក្នុងឆ្នាំពុទ្ធសករាជ ១២៩៤ ជាឆ្នាំដែលអំណាចចិននៅអាស៊ីកណ្ដាលផុតរបូតអស់ទៅ ក្រុងចិនក៏កើតចលាចលវឹកវរឡើង ។ ក្នុង

ដែនបញ្ជូកៅកាន់ត្បូងនោះ ពួកតឺ-តៃ ជាតិក្ទិកនៅខាងស្រុកលៀវ-តុង បានចាប់ផ្ដើមលុកចូលមកខាងឈូងសមុទ្រប៉ោហៃ ហើយបានវាយកំ-ទេចកងទ័ពចិនមួយកងទៅ ៗ ចំណែកយ៉ុន-ណាន ពួកណាន-ចៅ គឺជាតិថៃ តាំងនៅក្នុងដែនតាលី ក៏បានបណ្ដេញកងទ័ពចិនមួយកង ដែលតាំងនៅក្នុងតំបន់នោះ ឲ្យថយចេញពីខេត្តដែនរបស់ខ្លួនទៅ ក្រុងចិនបានចាត់បញ្ជូនកងទ័ពធំទៅប្រាបប្រាម តែកងទ័ពណាន-ចៅ បានវាយទ័ពចិនបែកខ្ចាត់ខ្ចាយនៅមាត់ទន្លេសាបតាលី ក្នុងឆ្នាំពុទ្ធសករាជ ១២៩៤ នោះឯង ដែនដីខាងយ៉ុន-ណាន ក៏ផុតរបូតអំពីអំណាចចិនទៅ ៗ

បើទុកជាកដវង្សថាំងបានធ្វើឲ្យចិនមានយសសក្តិខ្ពង់ខ្ពស់ឡើងយ៉ាងណាក៏ដោយ ប៉ុន្តែ ប្រជាជនចិននៅតែមានចិត្តរកាំដុញទ្រាន់ទឹងហេតុ គេទេរបស់ក្រុងចិន រហូតវេលាជារយៈ ១៥០ ឆ្នាំនោះ ព្រោះក្មេងកំលោះៗ ជាតិចិន ត្រូវចាត់បញ្ជូនទៅទ័ពខ្ទប់បង់ជីវិតក្នុងតំបន់ខ្សាច់នៅក្នុងសមុទ្រខ្សាច់ គូ-ប៉េ, ក្នុងតំបន់ទឹកកកនៅដែនម៉ុល-តៃ នៅលើទីវាលខ្ពស់ដ៏ត្រជាក់ស្រួតនៃដែនទីបេត៍, នៅក្នុងព្រៃក្រាស់ដ៏លំបាកវេទនានៃដែនយ៉ុន-ណាន ដោយហេតុមានចម្បាំងសង្គ្រាមមិនដាច់ស្រាកស្រាន្ត នាំឲ្យបន្ថយចំនួនស្រុកអស់ទៅជាច្រើនកាលៗឆ្នាំ នាំឲ្យមានសេចក្ដីព្រួយដល់ពួកដែលនៅក្នុងស្រុក ដោយបាត់បង់ជីវិតកូនចៅរបស់ខ្លួនទៅកាលៗឆ្នាំ ៗ ចិត្តកវីសំខាន់របស់ចិន គឺ លី-តៃ ប៉ែ និងទូ-ហ្វូ បានតែងសៀ-

ទៅពណ៌នាអំពីសេចក្ដីលំបាកវេទនារបស់ពួកទាហាន និងអំពីផលអាក្រក់នៃចម្បាំង តាមដោយពិតនោះ ខឹងថាជាកំហុសរបស់ក្សត្រ ឬរបស់អ្នក-ណាមិនបានតាំងអស់ ព្រោះបើមានសឹកសង្គ្រាមលុកលុយចូលមកក្នុងស្រុកទេសហើយ មនុស្សក្នុងស្រុកគ្រប់គ្នាត្រូវតែចាប់អាវុធច្បាំងតស៊ូ ប៉ុន្តែ ក្នុងសម័យកផផ្សែងប៉ាំងនេះ ចិនមានសឹកសង្គ្រាមច្រើនឡើងៗ ហើយកាលតែឆ្នាំណាដែលមានចម្បាំងមិនស្រាកៗ ក្នុងគ្រាព្រះបាទថៃ-សុងមហាកជ ចិនឈ្នះចម្បាំងស្ទើរតែមិនបាច់ចេញទៅច្បាំង ឬច្បាំងមិនបាច់ប្រើកំឡាំងទាហាន ទើបធ្វើឲ្យជីវិតជាតិចិនមិនខូចបង់ទៅប៉ុន្មានឡើយ ប៉ុន្តែមនុស្សថែបថៃ-សុងនោះគេបានដោយកម្រណាស់ ក្នុងរយៈពេលមួយពាន់ឆ្នាំទើបបានមនុស្សថែបនោះម្នាក់ៗ កាលបើប្រជាជនចិនគោរពបន់ទាគសាបឈាមជាចំនួនច្រើនដូច្នេះ ពួកទាហានក៏ចុះខ្សោយទៅជាក្បត់ឡើង ជាហេតុនាំឲ្យកផផ្សែងប៉ាំងវិនាសសាបសូន្យទៅទៅទីបំផុតៗ

មានមេទ័ពចិនម្នាក់ឈ្មោះ អាំង-លោឆាន បានទទួលជំនែណងពីព្រះបាទមិង-ហ្គុង ជាអ្នកបញ្ជាការទ័ពក្នុងខេត្តបើជិលិបានតាំងខ្លួនជាមេក្បត់ឡើងទីងព្រះរាជាធិរាជបានលើកទ័ពចូលមកទន្ទ្រានយកបានស្រុកលោ-យ៉ុង ក្នុងពុទ្ធសករាជ ១២៩៨ ហើយតមកមួយឆ្នាំទៀតយកបានស្រុកស៊ី-អាន ដែលជាទីក្រុងធំធ្វើឲ្យរាជសំណាក់របស់ព្រះបាទមិង-ហ្គុងគោង

ផ្លាស់ទៅតាំងនៅឯស្រុកសេ-ធួន ។ ត្រឹមប៉ុណ្ណោះមិនទាន់អស់គ្រោះនៅឡើយ ពួកក្បត់វៀតបង្គាប់ឲ្យព្រះបាទម៉ង-ពុំងប្រហារជីវិតព្រះនាងយ៉ុង-ហៃដែលជាអគ្គមហេសីសំណប់ស្មើនឹងជីវិតរបស់ព្រះអង្គ ដោយពួកក្បត់ចោទថា ព្រះនាងជាដើមហេតុនាំឲ្យកើតចលាចលវឹកវរឡើងក្នុងអាណាចក្រ ព្រោះធ្វើកផ្សំណាក់យ៉ាងស្ទុកស្ទួមហ៊ីហាចាយរាយព្រះរាជទ្រព្យខ្ជះខ្ជាយហួសពេក គិតតែសប្បាយមួយមុខមិននឹកដល់សុខទុក្ខរបស់បណ្ដារាស្ត្រ ។ ចំណែកខាងព្រះបាទម៉ង-ពុំងជាអ្នកដ៏គ្រោះមិនអាចទាត់ការដូចម្ដេចបាន គោងចណ្ដាយឲ្យពេជ្ឈឃាតនាំព្រះអគ្គ-មហេសីទៅប្រហារជីវិតតាមបង្គាប់របស់ពួកក្បត់ ។ ព្រះនាងយ៉ុង-ហៃជំនួនអ្នកប្រាជ្ញប្រវត្តិសាស្ត្រនាំទៅប្រៀបធៀបនឹងម៉ាដាមប៉ុមប៉ាឌួររបស់បារាំងសែស តែមកដល់ខានបុនជីវិតគោងប្រៀបធៀបនឹងព្រះនាងម៉ារី-អង់ទូនេតរបស់បារាំងសែសដោយខ្សែកថែមទៀតផង ។

មកដល់ចំណែកនេះ យើងបែរទៅទីៗរលឹកដល់សេចក្ដីដែលពោលមកហើយក្នុងវគ្គទី ៥ នោះក៏នឹងចូលចិត្តច្បាស់ថា អ្វីជាហេតុឲ្យពងវង្សថាំងរសាំរសាយរៀវកយ? អ្វីជាហេតុឲ្យប្រជារាស្ត្រចិនដែលស្រឡាញ់ពេញចិត្តនឹងពងវង្សនេះបែរចិត្តទៅជាក្បត់ ហើយបះបោរចលាចលឡើង? ការពិត ការដែលទាហានគោងទៅច្បាំងនឹងខ្មាំងសត្រូវរាល់ ១ ឆ្នាំ ខូចបង់ជីវិតក្នុងមួយឆ្នាំៗ ជាចំនួនច្រើននោះ មិនមែនជាកំហុសរបស់ព្រះមហា-

ក្សត្រឡើយ ព្រោះមិនមែនតែត្រឹមរាជវង្សថាំង ឬរាជវង្សណាទេ បើមានសឹកសត្រូវចូលមកលុកលុយដល់ស្រុកទេសហើយត្រូវតែលើកទ័ពចេញទៅតតាំង ហើយប្រជាជនត្រូវតែលះបង់ជីវិតសាច់ឈាមជួយស្រុកកំណើតរបស់ខ្លួន ។ នៅគ្រានោះប្រជាកស្រ្តុបិនក៏យល់រឿងនេះច្បាស់ដែរ ប៉ុន្តែបើមានតែត្រឹមសង្គ្រាមមួយមុខមិនជាការអ្វីទេ មិននាំឲ្យស្រុកចិនកើតចលាចលវឹកវរឡើងឡើយ ប៉ុន្តែកំហុសនេះធ្លាក់ទៅលើព្រះមហាក្សត្រចិនក្នុងសម័យនោះ គឺថាព្រះបាទមិង-ហ៊ុង ទ្រង់កសាងប្រាសាទរាជវាំងយ៉ាងសំបើមរុងរឿងថ្លៃថ្លា ចាយវ៉ាយខ្ជះខ្ជាយ ទ្រង់រីករាយសប្បាយឥតព្រួយអ្វីក្នុងខណៈដែលស្រុកទេសកំពុងមានសង្គ្រាម ។ ឯភាពនៃសង្គ្រាមពាសពេញដោយសេចក្ដីលំបាកតោកយ៉ាកវេទនារបស់ពួកទាហាន និងភាពនៃសេចក្ដីថ្កុំថ្កើងរុងរឿងរបស់រាជសំណាក់ ភាពទាំងពីរនេះបើមកមានប្រាកដឡើងក្នុងខណៈជាមួយគ្នា ប្រជាជនតែងតែកើតសេចក្ដីក្ដៅក្រហាយនិងទុក្ខទោមនស្សឡើងជាធម្មតា ព្រោះខាងណោះពួកទាហានគោរពយកជីវិតទៅប្ដូរជួយស្រុកទេសរបស់ខ្លួន ចំណែកខាងណោះ គឺខាងរាជសំណាក់គិតតែសប្បាយរីករាយក្រេមក្សាន្ត ។ ប្រសិនបើព្រះបាទ មិង-ហ៊ុង ទ្រង់ប្រតិបត្តិរាជកិច្ច ក្នុងខណៈនោះឲ្យត្រឹមត្រូវនិងកាលសម័យបង្អង់ការសប្បាយរីករាយក្នុងរាជសំណាក់ ជាបណ្ដោះ

កាសខ្ទស៊ិន ចាំឲ្យហើយស៊ិនស្ត្រីមស៊ិនសឹមសប្បាយតាមសព្វព្រះទ័យ ចុះ ធ្វើដូច្នេះពួកទាហានគង់តែមិនចេះបោរទៅជាក្បត់ឡើងទេ ។

ចំណែកឯព្រះបាទម៉េង-ភ៉ុង តាំងពីខួបបង់ជីវិតព្រះអគ្គមហេសីទៅ ព្រះអង្គមានតែសោកក្តីក្រៀមក្រំជាំព្រៅព្រះទ័យជាទុក្ខលើសលប់ គយកម៉េន យូរប៉ុន្មានក៏ស្តេចលាចាកពជសម្បត្តិ ទ្រង់ប្រគល់មកុដពជ្យឲ្យទៅស៊ូ-ស៊ុង ជាព្រះរាជទុរស ចំណែកព្រះអង្គស្តេចទៅរកទីវិវេក ទ្រង់សោកស្តាស ទ្រង់ព្យាយាមធ្វើឲ្យភ្លេចភ្លាំងសេចក្តីទុក្ខសោកក្រៀមក្រំទាំងអម្បាលណោះចេញ ។

ទូ-ហូ ជាចៅក្រឹងករបស់ចិន មានចិត្តស្មោះត្រង់ស្វាមីភក្តិនឹងព្រះបាទម៉េង-ភ៉ុង បានតាមស្តេចទៅផង ។ នៅវេលាដែលព្រះបាទម៉េង-ភ៉ុង គង់គន់ទីវិវេកនោះ ទូ-ហូបានតែងពណ៌នាសេចក្តីមួយអត្ថថា : -

«អនិច្ចា! ក្រទាំងមូលពាន់នៃព្រះរាជវាំងបានចំពជិតណែនហើយ ក្រុងស៊ី-អានក៏ពាសពេញទៅដោយល្អិតធូលី ដែលហុយឡើងដោយជើងសេះរបស់ពួកខ្មាំង ពួកមច្ឆាហែលក្នុងស្រះទឹងចុះឡើងមកឲ្យអ្នកណាមើល ពួកស្រីព្រះស្នំធ្លាប់នៅតាមមុខព្រះរាជដំណាក់ ចុះកូវលែងបាត់មុខទៅណាអស់ទៅ ព្រះនាងយ៉ុង-ហ្វៃមិនទ្រង់ញញឹមព្រះទស្សនៈឲ្យបានឃើញព្រះទន្តដ៏ស្អាតដូចកាលមុនទៀតហើយ» ។

(មានត)

# រឿងសាមកុក

## វគ្គទី ១

## អ្នកឧកញ៉ាវិបុលរាជសេនា (នូ កន) ប្រែ

(តមក)

---

ឯបួយនោះ ទ្រូកផការទ៉ឹងម៉ាត់រតែមានអំណាចឡើងរាល់ថ្ងៃ មនុស្សទាំងពួងសឹងកោតក្រែងអែងខ្លាចជាច្រើនណាស់ ព្រះចៅឡេនតេទ្រង់ជ្រាបស្គាល់ក៏តាំងឲ្យឡើងយសជា "ខុន ចិឡេង" ។ លុះពួកចោរផ្គួកក្បាលលឿងកំរើបចលាចលនេះពេញក្នុងស្រុកអែងជួន ព្រះចៅឡេនតេទ្រង់តាំងឲ្យបួយឡើងវិជាតុះអ៊ុយ ឲ្យឃុំនាំទាហាន ៥០០០ លើកទៅជួយស្រុកអែងជួន លុះទៅដល់ហើយក៏ប្រទះនឹងតៀវប៉ោ តៀវលៀងនឹងពួកចោរដែលសល់ពីស្លាប់កាលថែកបន្ទាយរត់ទៅនោះ បួយក៏លើកពលស្ទាក់កាត់មុខខុក ហើយខ្ទប់សម្លាប់ពួកចោរអស់ប្រហែលមួយម៉ឺនប្លាយ ទាហានបួយចាប់បាននេះសេះនឹងគ្រឿងសស្ត្រាវុធជាច្រើនណាស់ តែខ្លួនតៀវប៉ោ តៀវលៀងគេចរត់រួចទៅ ។

ឯបួយបួលទៅរកហាងហ៊ូស៊ុងនឹងជូហ៊ុ ហើយជំណាលពីកបួកផការទាំងពួង ទើបបួយសុំយកទាហាននៅតាមតៀវប៉ោ តៀវលៀងទៀត វាងទៀតពីខ្លួនអ៊ូតៀវហ៊ុយ លើកពលមកដល់ស្រុកអែងជួនបានព្រួសរំឡេងគេ

គគាំងបាំងគ្នា ឃើញមានពន្លឺភ្លើងភ្លឺស្វាងណាស់ ក៏លះរណាំងចេញ
តាហេនឲ្យស្រែកប្លន់ទៅជួយ លួមច្បូលទៅដល់ពួកចោរក៏បែកបាក់ខ្ចាត់
ខ្ចាយទៅ ទៀតពីក៏នាំគ្នាទម្លុះគៀរហ៊ុយ ចូលទៅរកហាងហ៊ុស្ងនទិនដួហ៊ី
ដួបគ្នា ហើយក៏និយាយថា លោកតឲ្យខ្ញុំបាទមកជួយធ្វើការ ហោក ៗ
ហាងហ៊ុស្ងនទិនដួហ៊ុទទួលថា ខ្ញុំអរគុណណាស់បងនិយាយថា ឥឡូវនេះ
គៀរហ៊ៅគៀរលៀងទិនពួកចោរបែកអស់ហើយ ខ្ញុំឃើញថា គៀរហ៊ៅ
គៀរលៀងទីងរត់ទៅរកគៀរកុកជាបងនៅស្រុកប៊ិកប៊ិ ប៉ើដូច្នេះបូរអែក
លើកទាហានស្រែករួតតាមស្ទាក់ស្កាត់ចាប់ឲ្យបានខ្លួនបុះ ៗ ទៀតពីគួនអ៊ី
គៀរហ៊ុយ ក៏លាត្រឡប់លើកទាហានតាមទៅ លុះដល់ពាក់កណ្ដាលផ្លូវ
ទទួលជួបប្រទះនឹងព្រះកបបម្រើ យ៉ុមនុស្សទោសកងត្រូវជាក់ណើរនេះ
បាមេកក្រឡេកតាមមើលទៅស្គាល់ ឃើញច្បាស់ជាលោកតទៅគង់ត្រូវ
នោះ ទៀតពីស្ទុតចិត្តហោតចុះពីលើខ្នងសេះស្ទុះចូលទៅសួរលោកតថា
ហេតុម្ដេចអ្នកទើបមកត្រូវទោសដូច្នេះ លោកតឆ្លើយថា ខ្ញុំបាទតាំងទៀម
គៀរកុកកុំឲ្យទៅកងបន្ទាយ ទៀបទន់ចាប់ខ្លួនបាន ហើយ គៀរកុក
ដឹងខ្លួនបេះតែប្រនិប្រយ័ត្ន ខ្ញុំទិនគិតថាបឲ្យចាប់តាមចិត្តពុំបាន ព្រះពៅ
ទៀនគេត្រូវបានប្រាប ទើបត្រាស់ប្រើដួហ៊ុកិត្រមកំណិះចេញមកស៊ើប
ការពដការ ដួហ៊ុងប្រាប់ថាទិនចង់បានសំណូកត្រែព្យពេសតិខ្ញុំ បានប៉ុន
ដំរាបថា គងកងចិតនេះ កិច្ចជាប់ស្បៀងភាហារណាស់ ខ្ញុំគ្មានរបស់អ្វី

ត្រូវសមជូនជាជំនួន ។ ដូច្នេះទើបខ្ញុំត្រឡប់ទៅក្រាបទូលព្រះចៅ ឡេនគេថា ខ្ញុំមិនយកចិត្តទុកដាក់ធ្វើការសឹកសង្គ្រាម ហេតុនោះបាន ជាយឺតយូរពុំសម្រេចការ ព្រះចៅឡេនគេទ្រង់ជឿពាក្យនោះ ទើបត្រាស់ ប្រើតាំងគុះឲ្យចេញមកជាមេទ័ពជំនួសខ្ញុំ ហើយត្រាស់ឲ្យចាប់ខ្ញុំធ្វើទោស ដាក់ទ្រុងនាំទៅស្រុកក្រុង ។ តៀរហ៊ុយបានឮដូច្នោះក៏ទឹកខ្ទឹងណាស់ កន្ត្រាក់យកដាវលើកឡើង នឹងសម្លាប់ឃុំដណ្ដើមដោះយកលោទិតចេញ ពីទ្រុង ឡៅពីឃើញអាការដូច្នោះក៏ស្ទុះទៅកាន់ពកថា កុំអាលធ្វើលើព្រះ រាជអាជ្ញាសិទ្ធិនឹងធ្វើតាមអំពើចិត្តពុំបានទេ ។ គួនអ៊ូឆ្លើយថាអំបាលលោទិត ហើយគង់មានសេចក្ដីខុសដូច្នេះ ក្រៅពីនេះនរណានឹងអាចធ្វើជាមេទ័ព តទៅទៀតបាន ឃើញជានឹងទាំងអ្នកទីពឹងពាក់អាស្រ័យគ្មានឡើយ សូម្បីធ្វើការមានគុណគាប់ជាបំណាច់យ៉ាងណា ក៏គង់ត្រឡប់ខុសទៅបាន ដូចលោទិតជាតួយ៉ាង បើដូច្នេះយើងត្រូវត្រឡប់ទៅស្រុកទុនគួនវិញជា ជាង ។ ឡៅពីស្ដាប់ឃើញត្រូវ ក៏លើកទាហានត្រឡប់ទៅស្រុកទុនគួន លុះលើកទៅបានពីរបីថ្ងៃ ដល់ពាក់កណ្ដាលផ្លូវ ឮសំឡេងស្រែកហ៊ោ កញ្ជ្រៀវអានស្រោយក្ដី ឡៅពីក៏នាំគួនអ៊ូ តៀរហ៊ុយបរសេះឡើងទៅមើល ពីលើកំពូលភ្នំក្រឡេកទៅឃើញទ័ពហ៊ុនបែក ឃើញទ័ពចោរដូតក្បាល ឡឿនលើកចេញសន្ធឹងមក ឡៅពីឃើញទង់ជ័យ ស្គាល់ថាទ័ពតៀវកុក លើកចេញទ័ពតាំងគុះ ទើបឡៅពី គួនអ៊ូ តៀរហ៊ុយ ត្រឡប់ញាក់សេះ

ចុះទៅជួយខានទ័ពហ្វូង ទ័ពតៀវក្រុកក៏ក្រឡប់ចាក់បែកខ្ចាត់ខ្ចាយរត់តាមផ្លូវទៅប្រមាណ ៤០០ ។ ឯគាំងគុះក៏លើកពលចូលបន្ទាយ ហើយឲ្យរកឡៀវពី គួនអ៊ូ តៀវហ៊ុយ ទៅសួរថា អ្នកឯងជាមន្ត្រីដំណែងអ្វី ? ឡៀវពីឆ្លើយថា ខ្ញុំបាទមិនបានជាមន្ត្រីមានដំណែងអ្វីទេ គាំងគុះបានស្ដាប់ដូច្នោះក៏ធ្វើកិរិយាថែបមើលងាយមិនមានសេចក្ដីគួរសមរាប់អាន ឡៀវពី គួនអ៊ូ តៀវហ៊ុយក៏លាត្រឡប់ទៅវិញ តៀវហ៊ុយក៏និយាយថា យើងបងប្អូន ៣ នាក់ជួយយកអាយុជីវិតឲ្យរួចពីសេចក្ដីស្លាប់គ្រានេះ វាមិនស្គាល់គុណយើងសោះត្រឡប់ធ្វើឫកពាមើលងាយយើងវិញ គួរតែសម្លាប់វាចេញទើបអស់សេចក្ដីក្ដៅចិត្ត ថាហើយក៏ក្រទាក់ដាវស្ទុះរៀលទៅនឹងសម្លាប់គាំងគុះ ឡៀវពី គួនអ៊ូកាំងឃាត់ថា កុំធ្វើគេជាព្រះរាជបំរើ ។ តៀវហ៊ុយតបថា បើមិនសម្លាប់វាចេញ ត្រូវការអ្វីយើងនឹងចង់នៅធ្វើការជាមួយនឹងវា ។ នឹងមានសេចក្ដីមើលងាយប្រមាថយើងច្រើនទៅទៀត ព្រោះវាមានអាជ្ញាសិទ្ធិ បងទាំងពីរនឹងចង់នៅក៏នៅចុះ ខ្ញុំសូមលាទៅរកទីដទៃទៀតហើយ ។ ឡៀវពីគួនអ៊ូឆ្លើយថា យើងជាបងប្អូនទាំង ៣ នាក់ ទោះយ៉ាងម្ដេចក៏ត្រូវតែស្លាប់រស់ជាមួយគ្នា ដែលនឹងព្រាត់ប្រាសចាកគ្នានោះមិនគួរទេ នឹងទៅណាត្រូវទៅជាមួយគ្នា តៀវហ៊ុយតបថា បើដូច្នោះត្រូវចាំឲ្យរសាយសេចក្ដីខឹង ថាហើយឡៀវពី គួនអ៊ូ តៀវហ៊ុយ ក៏លើកពលទាហានត្រឡប់ទៅរកជូហ៊ី ៦ ស្រុកអេងជួនឲ្យទាហានស្រុកដើរទាំង

យប់ទាំងថ្ងៃ  ដល់ហើយក៏នាំគ្នាចូលទៅរកជូហ៊ុ  ហើយពណ៌នាពីឈារ
ពងការទាំងពួងឲ្យជូហ៊ុស្ដាប់សព្វគ្រប់ ។ ជូហ៊ុក៏ពេញចិត្តអាណិត
ស្រឡាញ់រាប់អានឡៅពី គួន អ៊ូ តៀវហ៊ុយ ពន់ពេកណាស់  សន្មត
ទុកជាពួកគេជាមួយគ្នា  ជូហ៊ុ និយាយថា  តាំងគុះនោះ ស្រុកកំណើត
នៅគង់ក្រុងឡាយលិមយោ  ជានាហ្មឺនឈ្មោះហាងគុងថាយស៊ុំ ឯតាំង-
គុះនោះមិនជាអ្នកស្គាល់ការធ្ងន់ស្រាល  មិនស្គាល់មនុស្សល្អឬអាក្រក់
ឡើយ  បើជាអ្នកទៅនៅជាមួយផង  ក៏នឹងរកផលប្រយោជន៍មិនបាន
ឡើយ ។

ឯទ័ពចុន្ទ  ដែលទៅតាមតៀវប៉ូ  តៀវលៀងនោះលុះមិនជួបប្រទះ
ហើយ  ក៏លើកត្រឡប់មករកហាងហ៊ូស៊ុងទៅស្រុកកេងជួន  ចូលរួម
រួមធ្វើការជាមួយនឹងហាងហ៊ូស៊ុង ។ និងចុន្ទ លុះដឹងដំណឹងថា  តៀវ-
លៀងទៅស្រុកជូហ៊ីងជួបគ្នា  ក៏លើកទាហានទៅច្បាំងនឹងតៀវលៀង
ឯតៀវប៉ូទៅតាំងបន្ទាយនៅជិតទន់ក្រោយភ្នំ ១  មានពួកចោរជាបរិវារប្រ-
មាណ ៨ ម៉ឺន ៩ ម៉ឺន ។

ជូហ៊ីលុះដឹងដំណឹងថា  តៀវប៉ូទៅៗ ទ័ពនោះ  ក៏ចាត់ឲ្យឡៅពី
គួនអ៊ូ តៀវហ៊ុយជាទ័ពមុខ  គូជូហ៊ីជាទ័ពហ្លួង  លើកពលទាហានទៅ
គតាំងច្បាំងនឹងតៀវប៉ូ  ខាងតៀវប៉ូ ចាត់ប្រើក្វូសេង ឃុំនាំពួកចោរចេញ
មកតយុទ្ធនឹងកងទ័ពមុខ នោះឡៅពីប្រើតៀវហ៊ុយឲ្យចេញទៅតទល់នឹង

ក្បូសេង ប្រយុទ្ធគ្នាមិនទាន់បាន ៣ ភ្លេង ទៀវហ៊ុយចាក់នឹងលំពែងត្រូវក្បូសេងធ្លាក់ពីលើសេះស្លាប់ ពួកទាហានទាំងឡាយក៏បែកខ្ចាត់ខ្ចាយអស់ទៅ ៗ ហ្លៅពីដេញទាហាន ឲ្យចូលកាយកាប់ចាក់ពួកចោរជាចលាចល ទៀវប៉ូចាល់គំនិតគិតរកច្រករត់ទៅណាមិនរួច ក៏សេកមន្តគាថា ហើយឲ្យមេឃងងឹតបិទសប់មណ្ឌលព្រះសុរិយា បណ្តាលជាអស្ចារ្យផ្គររន្ទះបាញ់ខ្ទរខ្ទារ ធ្លាក់ភ្លៀងខ្យល់ព្យុះបោកបក់គប់ទិសានុទិស មានទាំងមនុស្សជិះសេះកាន់គ្រឿងអាវុធអណ្តែតចុះមកពីលើអាកាសវេហាសប្រឋពី ពលទាហានទាំងហ្លៅពីឃើញដូច្នោះក៏ស្ទះរត់ជ្រួលច្របល់វឹកវរណាស់ ហ្លៅពីក៏ឲ្យថយទ័ពត្រឡប់មកហើយប្រឹក្សានឹងជូហ៊ុយ ក៏និយាយថា អាគេទអស្ចារ្យដូច្នេះ គឺគេធ្វើដោយវិជ្ជាការមន្តអាគមទេ យើងត្រូវឲ្យទាហាននាំយករបស់ស្មោកគ្រោក ឡើងទៅលាក់បង្កប់ទុកលើកំពូលភ្នំបើគេធ្វើដូច្នេះទៀតឲ្យទាហានបាចសាចរបស់ស្មោកគ្រោកនោះចុះមកមន្តអាគមនោះក៏នឹងសាបរលាបទៅឯង ៗ ហ្លៅពីក៏ប្រើគួនអ៊ូ ទៀវហ៊ុយឲ្យយុំនាំពលយោធាម្នាក់ ៣ ពាន់ យករបស់ស្មោកគ្រោកឡើងទៅទុកលើកំពូលភ្នំទាំងសងខាង ត្រង់ទ័ពដែលបង្កប់ទាហានកយុទ្ធគ្នានោះ លុះព្រឹកឡើងទៀវប៉ូលើកពួកទាហានចេញមក ហ្លៅពីក៏លើកពលទាហានចេញទៅតទល់ច្បាំងគ្នា នោះទៀវប៉ូតាំងតែសេកមន្តគាថាធ្វើឲ្យមេឃងងឹត កើតផ្គររន្ទះព្យុះខ្យល់នឹងមនុស្សជិះសេះកាន់អាវុធដូចកាលជាន់មុន

ឡៀវពីឃើញដូច្នោះក៏ធ្វើជាកថយទ័ពមកខាងក្រោយ   គៀវប៉ូក៏ដេញដិត
ប្រកិតតាមមកដល់ទីប្រហប់ច្រកភ្នំទាំងសងខាង ។ គួនស៊ូ គៀវហ៊ុយក៏
ឲ្យទាហានបាចសាចអសុចិលាមកគក់ច្រាំនឹងឈាមជ្រូកឈាមឆ្កែពីលើ
កំពូលភ្នំទៅត្រូវពួកបោរ   រីឯមនុស្សជិះសេះកាន់អាវុធចុះពីអាកាស ក៏
ក្លាយទៅជាក្រដាសនឹងផ្ទុំស្មៅទាំងអស់   មេឃដែលងងឹតនឹងគ្រៀងខ្យល់
ផ្គរនេះក៏ស្រឡះភ្លឺស្វាងដូចធម្មតា ។ គៀវប៉ូឃើញដល់តល់កំបាំងផងខ្លួន
ក៏ថយទ័ពត្រឡប់ទៅខាងក្រោយ ដូហ៊ីឡៀវពីក៏លើកពលទាហានទទ្រាន
តាមប្រកិតដិតដោយថេះទៅទាល់តែដល់ច្រកប្រហាកភ្នំ   គួនស៊ូគៀវហ៊ុយ
ដែលនៅពីលើក៏បពលចុះមកខ្ទប់ប្រសព្វគ្នាទាំងសងខាង  គាបគៀវប៉ូឲ្យ
នៅជាកណ្ដាល មិនដឹងនឹងរត់ទល់ទៅខាងណា ក៏បែកខ្ចាត់ខ្ចាយអស់ទៅ
ឡៀវពីលើកពលទាហានតាមទៅទៀត   ក្រឡេកទៅឃើញអក្សរឈ្មោះ
គៀវប៉ូ ឯគៀវប៉ូនោះរត់ចូលទៅក្នុងព្រៃ ឡៀវពីលើកធ្នូបាញ់ទៅត្រូវស្មា
ឆ្វេង ព្រួញក៏ជាប់ស្មាទៅ គៀវប៉ូប្រឹងរត់ស្ទុះទៅដល់ស្រុកយៀងសាំ
ចូលក្នុងកំពែងបានហើយក៏ខ្ទប់បិទទ្វារស្រុកគុក ។ ដូហ៊ីឡៀវពីដេញ
ទាហានតាមទៅក៏កយទ័ពព័ទ្ធជុំវិញស្រុកនោះ    ហើយចាត់ទាហានឲ្យ
ចេញទៅស៊ើបស្ដាប់ដំណឹង   ហានហ៊ីស្តុនដែលទៅច្បាំងនឹងគៀវលៀង
ទទួលសេះចំរើនាំសំបុត្រមកប្រាប់ដូហ៊ីឡៀវពីថា   ឥឡូវនេះហានហ៊ីស្តុន
លើកពលទៅច្បាំងនឹងគៀវកុក ៗ ស្លាប់មុនទៅហើយ   ឯគៀវលៀងប្អូន

តៀវកុត ក៏លើកពលចេញច្បាំងនឹងហានហ៊ូស៊ុនៗច្បាំងនឹងតៀវលៀវ ។
វែកទ័ពផល់៧ដង ត្រាតែក្រោយមកហានហ៊ូស៊ុនកាប់តៀវលៀវស្លាប់ក្នុងស្រុក
ល្វយ៉ុងហើយ បណ្ដាបក្ខពួករបស់តៀវលៀវទាំងប៉ុន្មានសឹងមកចុះចូល
នៅជាច្រើន ហានហ៊ូស៊ុនបានឃុំនាំយកបក្ខពួករបស់តៀវកុត និងសព
តៀវកុតចូលទៅថ្វាយព្រះចៅឡេនតេ ទ្រង់ព្រះរាជទានឲ្យហានហ៊ូស៊ុន
ឡើងទីជាទីកុនគុន គឺជាទាហានសម្រាប់រក្សាព្រះអង្គឲ្យនៅស្រុកប៉ិយជីវ
ហើយហានហ៊ូស៊ុនក្រាបបង្គំទូលព្រះចៅឡេនតេថា លោហិតមានសេចក្ដី
គាប់ត្រូវគន់ការធ្វើសង្គ្រាម នឹងបានមានសេចក្ដីកំហុសដូចខ្ញុំក្រាបបង្គំ
ទូលដូច្នោះក៏ដោយ ព្រះចៅឡេនតេទ្រង់ជឿដូច្នោះ ក៏ត្រាស់ឲ្យដោះ
លោហិតចេញពីទោសហើយឲ្យគង់ទីដូចដើម ។ ឯបុត្តនោះមានសេចក្ដី
គាប់ប្រសើរក្នុងការទ្រង់ប្រាសប្រទានឲ្យទៅឈរស្រុកចេង្សាំ ។

ដូហ៊ុំ ឡៅពី ដែលឡើមពីស្រុកយៀនសារ នោះដឹងថា បណ្ដា
ទាហានខ្ញុំរាជការតូចធំ សឹងមានសេចក្ដីគាប់ប្រសើរក្នុងការៗពាក់ឲ្យ
ទៅឈរនៅត្រខណ្ឌជាច្រើនកំបន់ដូច្នោះ ក៏ខំស្វែងរកវេញទាហានឲ្យ
ចូលកាយទំពាយស្រុកយៀនសារ ជិតនឹងបានការហើយ ទទួលច្បាំងបេង
គាយទាហានពារតិកត្រូវគ្រាប់ពួកពោះទាំងពួង លបសម្លាប់តៀវហ៊ូជា
នាយទៅហ្មាយ ស្លាប់ហើយ កាត់យកក្បាលនាំទៅជូនដូហ៊ុំ ឡៅពីមាន
ក្រៅស្រុក ហើយសុំខ្ញុំចុះចូលធ្វើរាជការជាមួយគេទៅ ដូហ៊ុំមានចិត្ត

អំណរណាស់ ក៏តែងសំបុត្រកាយដំណើរតើផ្តើកដការមោខគុណបំណាច់ ទាំងប៉ុន្មានថកចូលទៅក្រាបបង្គំទូលថ្វាយព្រះចៅឡេងតេត្រង់ប្រការ ៗ

មានឈ្មោះតៀវហេង ហាន់គុង ស៊ិនគុង ជាសេនាតៀវកុក លុះតៀវកុកស្លាប់ហើយ ក៏បញ្ចុះបញ្ចូលពួកចោរបានច្រើនហ៊ឺន លើកទៅប្លន់ដណ្តើមយកទ្រព្យរបស់អស់បណ្ដាអ្នកស្រុក ហើយដុតបំផ្លាញផ្ទះសម្បែងជាច្រើន សេះបរើក៏នាំសំបុត្រមកចូលទៅក្រាបបង្គំទូលថ្វាយព្រះចៅឡេង-តេ ៗ ទ្រង់ត្រាស់ឲ្យមានសារត្រាទៅដល់ ជូហ៊ី ឲ្យជូហ៊ី ចាត់ទាហានដែលមានប្ញីដៃខ្លាំងពូកែលើកទៅបង្ក្រាបពួកចោរទាំងនោះឲ្យបាន ៗ ជូហ៊ីបានទទួលព្រះដម្រាស់ហើយក៏ចាត់សេនាទាហានលើកទៅឡោមព័ទ្ធស្រុកអ្នកសៀវផ្នែកខាងកើត ឡៅពី គួនអ៊ូ តៀវហ៊ុយឡោមព័ទ្ធផ្នែកខាងលិច ខណៈនោះតៀវហេង ចាត់ឲ្យ ហាន់គុង យុំនាំពលទាហានចេញទៅតទល់ខាងទិសឡៅពី ជូហ៊ីយុំនាំពលទាហានឯក ២០០០ ចូលខ្ទប់ប្រះបពួតឹម្ខាង ឯពួកចោរតទល់លើសកំលាំងទ្រាំពុំបាន ក៏ថយទ័ពត្រឡប់ចូលក្នុងកំផែងស្រុកវិញ ឡៅពីទឹងសេនាទាហានទាំងពួង ក៏លើកតាមចូលទៅវាយទំលាយទល់ដល់កំផែង ក៏ឡោមព័ទ្ធទុក ពួកចោរនៅក្នុងកំផែងស្រុកអត់ជាប់ស្បៀងអាហារខ្លាំងណាស់ ទើបហាន់គុងប្រើទាហានចេញមករកជូហ៊ីសុំចំណុះចុះចូល ជូហ៊ីៗមិនព្រមទទួល ឡៅពីក៏និយាយថា កាលគ្រាផែនដីព្រះចៅហាន់កូបូ នឹងបានរាជសម្បត្តិនោះ ពីព្រោះមានមនុស្សមក

សុំចំណុះចុះបូលជាច្រើន ហេតុម្តេចទើបលោកមិនព្រមទទួលគេជាចំណុះ
ដូច្នេះ ។ ដូហ៊ីតបថា កាលគ្រាព្រះចៅហានគូបូនោះស្រុកទេសមិនបាន
ប្រក្រតី កើតបំរូងចំរះជាច្រើនណាស់បានជាព្រះចៅហានគូបូទទួល
មនុស្សចំណុះចុះបូលច្រើន គ្រានេះមានកើតចលាចលតែក្រុមពួកចោរ
ដូតក្បាលលឿងមួយពួកទេ បើទឹងទទួលពួកចោរជាចំណុះចុះបូលទៅ
មនុស្សទាំងពួងនឹងយកគំរាប់តាមគ្នាជាច្រើនហើយ បើមានអ្នកមក
បង្ក្រាបសំរាលះបង់ពួកអាក្រក់ អង់ទឹងត្រឡប់ទៅជាមនុស្សល្អបាន យូរ
ទៅទឹងផ្ញើសាក្រវិញបានទៀត ។ ឡេក្យពីស្តាប់សព្វគ្រប់ ក៏ទទួល
ថាប្រិហាសពិតនោះត្រូវហើយតែជាការដែលលើងមកឡោមព័ទ្ធស្រុកកុកជុំ
ទាំង ៤ ទិសឲ្យនៅដូច្នេះ ពួកកាក៏ទាល់បញ្ញមិនរួចសោះ សូម្បីពួកនោះ
ក៏សឹងតែជាជាតិអាហារឧបមាដូចជាសុខដែលទាល់ត្រក ពេលណា
ឡើយក៏ទឹងទៅស្រៀមឲ្យអាហារហើយបាប់បង់ដោយងាយ តង់ទឹងគាំង
បញ្រាំងទាក់តែវិធាសង្ខ ។ អាហារលើក៏គិតទិវាអបនិងទោះជាធម្មតា
មានឧបមាដូចយកពុំសែនទៅដូរយកអំបិល បើដូច្នេះសូមឲ្យបន្ថយអាហារ
ដែលខាងកើតចេញចុះ ដើម្បីកុំឲ្យពួកកាក់ចេញទៅ សំបាមមាប់
យកដោយងាយត្រោបាញ់ឃើញបានដោយងាយ ។ ដូហ៊ីស្តាប់ទៅឃើញត្រូវ
ក៏ឲ្យបន្ថយអាហារដែលខាងកើតចេញអស់ហើយមកព្រួតទំលាយតែខាង
ទិសទាំង ៣ ។ (មានត)

ភាគទី ១៩

# យុគសុន្ទរមេធី ញង-សឿង ប្រែ

## លោក ហង់-គិមសេង ពិនិត្យ

(តមក)

---

"អស់លោក អ្នកទាំងឡាយ, សូមមេត្តាប្រាប់ខ្ញុំផង, ហេតុដូចម្តេចក៏ខ្ញុំមកនៅត្រង់កន្លែងនេះ?" ។ មនុស្សម្នាក់និយាយជំនួសគេទៀតថា "នែអ្នកកំឡោះ, គេទើបនឹងបើកទ្វារក្រុងនេះភ្លាម នាំគ្នាចេញមកស្រាប់តែឃើញអ្នកឯងដេកស្តុកស្តឹងនៅតែម្តង, ពួកយើងក៏នាំគ្នាឈប់សង្កេតមើលព្រោះមានសេចក្តីងឿងឆ្ងល់ដែរ; យើងសុំសួរអ្នកឯងវិញៈ ចុះយប់មិញ អ្នកដេកនៅកន្លែងនេះឬ? ម្យ៉ាងទៀត អ្នកដឹងទេ ក្រុងអ្នកឯងនៅក្បែរទ្វារណាមួយនៃក្រុងដាម៉ាស់នេះឬ?" ។ បេទ្រឌិនឆ្លើយថា "អើ៎នៅក្បែរទ្វារណាមួយនៃក្រុងដាម៉ាស់! អ្នកនិយាយយ៉ាងនេះ គឺចំអកឡកឡឺយឲ្យខ្ញុំតែម្តង, កាលពីយប់មិញនេះ ខ្ញុំដេកនៅឯក្រុងកៃរ៉ូទេតើ" ។ និមិត្តតែបានឮពាក្យនេះហើយ ជនពួកខ្លះមានសេចក្តីអាណិតអាសូរ នាំគ្នានិយាយថា "គួរស្តាយពេកគួរឲ្យអាណិតណាស់ហ្ន៎! មនុស្សកំពុងពេញកំឡោះរូបស្រស់ស្អាតបាតថែបនេះ មិនសមបើមចខូចសតិល្ងីល្ងើដូច្នេះសោះ" ថាហើយក៏ដើរហួសទៅ ។

គ្រានោះ មានតាព្រឹទ្ធាចារ្យម្នាក់និយាយឡើងថា "នែចៅតា, ម្ដេចក៏អ្នកមិនគិតពិចារណាមើល: បើព្រឹកនេះអ្នកនៅក្រុងដាម៉ាស៍, រួចល្ងាចម្ដងវិញថានៅឯក្រុងកែរ៍ដូចម្ដេចកើត? រឿងនេះមិនទំនងសោះ ព្រោះក្រុងទាំងពីរនេះនៅឆ្ងាយពីគ្នាណាស់" ។ ហេទ្រទិនតបតថា "បាទទេ ដំណើរនេះពិតប្រាកដហើយ, ខ្ញុំសូមជំរាបថែមទៀតថា ម្សិលមិញខ្ញុំនៅឯក្រុងបាល់ស្ដូកមួយថ្ងៃពេញល្ងាច" ។ និយាយពាក្យនេះស្មើរតែមិនទាន់ផុតមាត់ផង គេនាំគ្នាសើចលាន់ឡើងហើយគេស្រែកគ្រប់គ្នាថា "មនុស្សឆ្កួត! មើលមនុស្សឆ្កួតរ៉ូយ!" ។ មានម្នាក់ទៀតចាប់និយាយថា "នែអ្នកប្រុស, អ្នកឯងពិតជាវង្វេងខួបសតិហើយ, ម្ដេចក៏មិនគិតពិចារណាមើលដល់ពាក្យដែលខ្លួននិយាយ, ដែលមានដែរឬមនុស្សតែម្នាក់ ពេលថ្ងៃនៅឯក្រុងបាល់ស្ដូក, ពេលយប់នៅក្រុងកែរ៍ ហើយព្រឹកឡើងស្រាប់តែមកនៅឯក្រុងដាម៉ាស៍ឯណោះវិញ? អ្នកឯងប្រហែលជាមិនទាន់រលឹកដឹងខ្លួនស្រួលបួលទេដឹង, ចូរអ្នកគ្រវីផ្សាស់ស្មារតីរបស់ខ្លួនឲ្យច្បាស់លាស់ឡើងមើល" ។ ហេទ្រទិនហាស្បៀនឆ្លើយថា "ទេ, ខ្ញុំមិនដឹងជារំលឹកផាស់ស្មារតីយ៉ាងម៉េចទៀតទេ, បើមនុស្សភ្ញាក់ស្វាងថែសយ៉ាងនេះទៅហើយ មានទៅដេកលក់កាលណា, រឿងនេះគឺពិតប្រាកដដូច្នេះឯង, ពីយប់ម្សិលមិញខ្ញុំបានទាំងរៀបចំធ្វើមង្គលការខ្លួនឯងនៅឯក្រុងកែរ៍ឯណោះផង" ។ ពួកអ្នកដែល

ចំណូលទាន់សើច កាលបើឮពាក្យនេះហើយ ក៏រឹតតែនាំគ្នាសើចខ្លាំងឡើងជាងមុនទៅទៀត, មនុស្សដែលនោះនិយាយតទៅថា "ចូរអ្នករំពឹងគិតរឿងនេះឲ្យម៉ត់ចត់ ព្រោះអ្នកឯងប្រហែលជាយល់សប្តិទេយ៉ាងមើល ហើយការស្រមើស្រមៃនោះនៅជិតជាប់ក្នុងគំនិតនៅឡើយ បានជាចេះតែនិយាយដូច្នេះ" ។ មាណពតបឆ្លើយទៅវិញថា "ខ្ញុំដឹងច្បាស់ណាស់ដំណើរដែលខ្ញុំនិយាយទៅទាំងអម្បាលម៉ាន ឥតស្រមើស្រមៃឬកាន់ប្រឡំទេ, អ្នកជាមកចុះហ៎ា! ទំងជាខ្ញុំនឹកស្រមើស្រមៃទៅដល់ក្រុងតែដូចម្ដេចកើត, ខ្ញុំចាំជាក់ច្បាស់ណាស់ថា ខ្ញុំបាននៅក្នុងក្រុងនោះហើយគេបានទាំងនាំប្រពន្ធខ្ញុំមកឲ្យឈរនៅចំពោះមុខខ្ញុំដល់ទៅ ៧ លើក គឺពល់តែលើកដែលនាងផ្លាស់សំលៀកបំពាក់ថ្មីៗ, ហើយដល់ទៅទីបំផុត ខ្ញុំបានឃើញការមអប្រិយដែលគេយកមកចុះបក្ខបញ្ញត បំរុងឲ្យធ្វើជាប្ដីនាងនោះផង, បើយ៉ាងនេះតើ ទំងជាខ្ញុំស្រពិចស្រពិលស្រមើស្រមៃដូចម្ដេចកើត? សូមអ្នកមេត្តាប្រាប់ខ្ញុំទៀត ចុះអាវខ្ញុំ, ឈ្នួតក្បាលខ្ញុំព្រមទាំងថង់ដាក់ប្រាក់ដែលខ្ញុំមាននៅឯក្រុងកៃរនោះ តើបាត់ទៅឯណាអស់ទៅ" ។

បេទ្រេឌឌិនហស្សែន ឮកណាជានិយាយបញ្ចប់ហើយបញ្ជាក់ទៀតតាមសេចក្ដីពិតមែនយ៉ាងនេះ ក៏ជនទាំងឡាយដែលស្ដាប់សេចក្ដីនោះនៅតែសើចដដែល គឺគេពុំជឿដោយដាច់ខាត" ។ រឿងនេះនាំឲ្យ

បេទ្រូខិនហស្ស៊ែន វិលខ្លួនឆ្ពោះកាន់ស្ពានគេ សូម្បីតែខ្លួនឯងក៏គេ ពិចារណារឿងខ្លួនពុំយល់គេគល់តែនឹងមន្ទិលសង្ស័យ ខ្លួនឯងថែមទៀត ជាអញឬមិនមែនអញ ? ។

លុះបាននិយាយបញ្ចប់ គាត់ក៏វិញទៅមកដោយប្រកាន់មាំថារឿង ដែលខ្លួននិយាយតាំងអម្បាលម៉ាន ជារឿងពិតឥតក្លែងក្លាយយ៉ាងនេះ ហើយ ទើបមាណពក្រោកឡើងដើរចូលទៅក្នុងក្រុង, ចំណែកអ្នកតាំងអស់នោះក៏ដើរតាមក្រោយហើយស្រែកបណ្តើរថា "មនុស្សឆ្កួត! មនុស្សឆ្កួត!" ។ កាលបានឮសូរស័ព្ទនេះ អ្នកខ្លះរត់មើលតាមផ្លូវ, អ្នកខ្លះឈរមើលនៅបង្អួចមាត់ទ្វារ ហើយមានជនខ្លះទៀតរត់មកចូលក្នុងចំណោមមនុស្សដែលដើរតាមបេទ្រូខិនហស្ស៊ែន ហើយស្រែកតាមគ្នាថា «មនុស្សឆ្កួត» ដោយឥតដឹងដំណើរដើមទងអ្វីឡើយ ។ មាណព កំពុងតែគប់ប្រមល់គិតព្រួយយ៉ាងនេះ ចេះតែដើរទៅ ក៏បានដល់មុខផ្ទះខាងទ័យពាណិជ (អ្នកលក់គ្រឿងបន្ថែម) ម្នាក់ ដែលបើកទ្វារផ្ទះចំហ ទើបចូលទៅក្នុងផ្ទះនោះដើម្បីគេចរះអំពីបណ្តាជនដែលតាមពាមមើលប្រចៃពេក ។

ពាណិជនោះ កាលពីដើមធ្លាប់ជាមេនៃពួកអាក់ប់អ្នកលេងស៊ីផឹកប្រផ្លែប្រព្រោ តែងតែស្គាល់ប្រុនធក់ដំណើមពួកឈ្មួញនានាមានឈ្មួញនេះជាដើម, សូម្បីជើងម្នាលនៃជើងនេះមកតាំងផ្ទះសម្បែងរកស៊ីលក់

ជូនដំណើរទៅក្រុងដាម៉ាស់ គាត់គិតការយ៉ាងត្រឹមត្រូវមិនដែលឲ្យទុក្ខទោសដល់អ្នកណាមួយយ៉ាងនេះហើយ ក៏គង់អ្នកផងនៅតែខ្លាចគាត់ជាដរាប ព្រោះធ្លាប់បាត់ស្មារតីមកហើយ; ហេតុនោះ គាត់គ្រាន់តែហាលភ្នែកចំភ្លាមបណ្ដាជនដែលហោមរោមតាមមើលមេឃទទេ ទាំងអម្បាលម៉ានទាំគ្នា ត្រកតេបព្រឹះក្រៀសកក្ដាបាត់អស់លើង ។ កាលគេទៅបាត់ស្មារតីអស់ហើយ, ពាណិជតាំងសួរប្រុសជំទង់អំពីដំណើរដើមទងគ្រប់សព្វហើយសួរថា អ្នកឯងជាអ្វី, នរណានាំអ្នកឯងមកកាន់ក្រុងដាម៉ាស់នេះ ។ បេទ្រទុចិន ហស្សីន ឥតលាក់អ្វីទេ បានសារសព្វតាមហូរហែអំពីកំណើតរបស់ខ្លួន, មរណភាពនៃឥន្ទសេនាបតីជាបិតា, ដើមហេតុដែលចេញមកពីក្រុងប៉ាល់ស្ទីន, រឿងដែលជកពាយប់មុនលើផ្នូរខ្មោចឥតុក ហើយដល់ភ្ញាក់ឡើង ស្រាប់តែឃើញខ្លួនឯងនៅឯក្រុងកែរព្រមទាំងបាននៀបចំការប្រពន្ធនៅទីនោះផង; ក្នុងទីបំផុតនោះទាំងម្ចាស់ខ្លួនក៏គ្រាន់តែឆ្ងល់ណាស់ ដោយឃើញខ្លួនឯងមកនៅឯក្រុងដាម៉ាស់ឯណេះវិញព្រះង៉ើយ គឺមិនយល់រឿងចំឡែកអស្ចារ្យទាំងនោះសោះ ។

ពាណិជក៏និយាយថា "រឿងអ្នកឯងចំឡែកពេកណាស់; ប៉ុន្តែបើអ្នកយល់ព្រមធ្វើតាមពាក្យខ្ញុំ, អ្នកកុំនិយាយរឿងទាំងអស់របស់ខ្លួនដែលទើបនឹងសារស័ព្ទប្រាប់ខ្ញុំអម្បាញមិញនេះ ប្រាប់អ្នកដទៃឲ្យគេដឹងឮតទៅទៀត, អ្នកត្រូវស៊ូទ្រាំអត់ធ្មត់សិនទៅ បន្តិចទៀតគង់មានចេញទីង

ត្រាប្រណីជួយដោះអ្នកឲ្យរួចអំពីគ្រោះថ្នាក់ដែលអ្នកកំពុងតែទទួលនូវទុក្ខ សព្វថ្ងៃនេះពុំខាន; អ្នកត្រូវតែនៅជាមួយនឹងខ្ញុំដរាបដល់ពេលនោះ; ម្យ៉ាងទៀតខ្ញុំគ្មានកូនទេ, បើអ្នកយល់ព្រម ខ្ញុំយកអ្នកធ្វើជាកូនភ្លាម, កាលបើអ្នកបានធ្វើជាកូនចិញ្ចឹមខ្ញុំហើយ អ្នកនឹងដើរកាត់ទីក្រុងនេះបាន តាមចិត្តហើយក៏គ្មាននរណានឹងហ៊ានប្រមាថមើលងាយឡើយ ។

ទោះបីការទទួលខ្លួនជាកូនចិញ្ចឹមគេនេះមិនសមដល់កិត្តិយសកូន អគ្គមហាសេនាក៏ពិតមែន ប៉ុន្តែបេទ្រទឈិន អាចយល់ព្រមទទួលបាន តាមបំណងរបស់អ្នកលក់នំ ដោយពិចារណាយល់ឃើញថាគេជាមនុស្ស វិសេសល្មមធ្វើខ្លួនប្រាណបាន ដើម្បីនឹងលៀងជីវិតតទៅ ។ ពាណិជ ឲ្យមាណពស្មៀនតាក់តែងការស្អាតបាត យកសាក្សីជាច្រើនគ្នា ហើយ ចូលទៅបង្គំលោកចៅក្រមថាខ្លួនបានយកបេទ្រទឈិនធ្វើជាកូន, រួចហើយ បេទ្រទឈិន ក៏បានទៅរួមសុខរួមទុក្ខជាមួយនឹងពាណិជ, គេហៅឈ្មោះ ជ'ផលថាហាស្យែន, តមកបានចាប់ផ្ដើមរៀនធ្វើនំ ។

ក្នុងខណៈដែលរឿងនោះកំពុងកើតកើរនៅក្រុងដាម៉ាស់ឯណោះ, ធីតាលោកសេមសេទឈិន មូហាម្មេ ភ្ញាក់ឡើងស្រាប់តែឥតឃើញ បេទ្រទឈិនទៅក្បែរខ្លួននាងសោះ ទើបស្មានថាប្រហែលជាប្ដីចេញក្រោក ឡើងមុនចេញទៅក្រៅមិនឲ្យនាងដឹង ដោយខ្លាចរំខានដល់ការនិទ្រា របស់នាង ហើយបន្តិចទៀតគង់នឹងត្រឡប់ចូលមកវិញពុំខាន, ដោយ

ស្មានដូច្នេះ ទើបនាងនៅចាំមើលដំណើរប្ដីនឹងវិលត្រឡប់វិញ, គ្រានោះលោកឧត្តមមហាសេនាជាបិតា មានសេចក្ដីអាម៉ាស់មុខខ្លាំងណាស់ ដោយព្រោះជាប្រុសទេសអសុត្ថិ ទ្រង់ប្រើអំណាចយ៉ាងដាច់ខាតដូច្នេះ, លោកមមនោះក្ដាប់ខ្លួនកូនស្រី ប្រង់ទឹងចូលទៅយំសោកបៀតជាប់ជាមួយនឹងនាងគំពិតព្រេងសំណាងអាក្រក់, លោកបានហៅចំឈ្មោះនាងដើម្បីឲ្យបើកទ្វារ ។ ពីគាព្យហើយក៏ក្រោកឡើងស្ទុះទៅបើកទ្វារ, បានចាប់ដៃបិតាយកមកថើបហើយទូលពក់ទាក់ដោយការសំដែងទឹកមុខញញឹមញញែមស្រស់ស្រាយ ; លោកឧត្តមមហាសេនា ស្មានថាកូនស្រីមុខជាកើតទុក្ខមុខក្រៀមក្រំយំខ្សឹកខ្សួលជួបលោកដែរ ហើយបែរជាឃើញនាងញញឹមពព្រាយដូច្នោះទៅវិញ ទើបលោកងឿងឆ្ងល់ណាស់ ៗ លោកនិយាយគំរោះគំរើយទាំងទឹងសម្លក់ថា "ឱះអានិត្ម! ហ៊ានឯងសំដែងអាការៈបែបនេះចំពោះមុខអញឬ? ហ៊ានទើបរៀបការជាមួយនឹងអាមនុស្សគំរក់ចញ្ចុះគេហើយក្ដាម លោតតេះធ្វើទឹកមុខស្រស់ស្រាយមមតែអញកើត អាការបែបនេះបមណាស់ឬ? ត្រង់អញឯណោះ ស៊ីតែនឹងប្រះក្ដាយដើមទ្រូងស្លាប់ ហានឯងមិនគិត, កូននេះឆ្កួតបំផ្លាញពូជចៅតមែន!! ។

តែបើឃើញបិតាស្ដីបន្ទោសជៀលត្នះសេចក្ដីកក្រោយរបស់ខ្លួនដូច្នោះ ក៏ឆ្លើយថា "លោកឪពុក, សូមមេត្តាអត់ទោស, លោកពុំគួរនឹងស្ដីបន្ទោស

ខ្ញុំតាំងទទឹងទទែងខុសចំពោះផ្លូវនោះ ខ្ញុំមិនមែនរៀបការក្នុងជាមួយទីនីកាគមអប្រិយដែលខ្ញុំស្អប់ខ្ពើមជាងសេចក្ដីស្លាប់នោះទេ; អ្នកទាំងអស់គ្នា បានធ្វើឲ្យអាត្មាអៀនខ្មាសជាច្រើន ទាល់តែទ្រាំនៅពុំបាន រត់ទៅពួនបាត់ទៅ ហើយទុកកន្លែងឲ្យកំឡោះរូបស្រស់ម្នាក់ ដែលត្រូវជាស្វាមីខ្ញុំពិតប្រាកដ" ។ លោកសមសេទជិនមុំហាមេទ ឆ្លើយកាត់ឡើងហាំងហើសថា "ហើយ៉េ, ចុះកេនឯងនិយាយរឿងកន្លែងក្លាយប្រាប់អញដូចម្ដេចហ្នឹង? យ៉ាងម៉េច, នីងកេចមិញនេះអាគមមិនបានដេកជាមួយទីនឯងទេឬ?" ។ នាងឆ្លើយភ្លាមថា «ទេ លោកឪពុក, ខ្ញុំមិនបានទទួលតានជំណោកជាមួយទីនបុរសដទៃក្រៅពីកំឡោះនោះទេ, ស្វាមីខ្ញុំនោះមានកែកហ្វណៈ ហើយមានលក្ខណៈបំពេញស្រីល ។ គ្រាន់តែបានឮពាក្យនេះហើយ, លោកឥឡូវមហាសេមាទីនប្រទោកឡើងមួយរ:ពប់ស្រែកតំហាកឡើងក្នុងថា «មេៈបាលមៀត ហានបង់ធ្វើឲ្យអញអង្គែងការគំមិតពាក្យកែសងហ្នឹងឬ?» ។ ធីតាតបវិញថា ចាសទេលោកឪពុកទេ គឺដែលចំការស្មារតីខ្ញុំឲ្យវិលវល់ ព្រោះលោកមិនជឿសំ-ដីខ្ញុំសោះ» ។ លោកកក្តុមហាសេមានិយាយឡើងថា ពិតជាមិនមែនកាគមឬ?» ៖ ធីតានិយាយដោយ សេចក្ដីខ្ញាញ់ស្មើរតែទីនលោកទៅសង្កត់លើឪពុកថា «លោកឪពុកលែងឱ្យឈ្មោះកាគមនោះទៅ ខ្ញុំមិនត្រូវការឮឈ្មោះវាទេ ខ្ញុំបាតមអប្រិយចោលមៀត លោកឪពុក

ម្តេចក៏នៅតែយកឈ្មោះមកនិយាយឲ្យខ្ញុំឮទៀត ? ខ្ញុំសូមជំរាបបន្ថែមមួយទៀតថា ខ្ញុំគ្មានទំនួលទាក់ទងជាមួយវាទេ, គឺជាមួយខ្មោចស្វាមីរូបស្រស់ប្រិមប្រិយដូចខ្ញុំបានជំរាបគម្រាញ់មិញនេះ ហើយខ្មោចនេះគាត់មិនមែនជាឈ្មោះពីរនេះប៉ុន្មានទេ " ។

លោកសេមះសេទឌិន ម៉ូហាម្មេទ ចេញទៅក្រោម, ប៉ុន្តែមិនបានឃើញកំលោះរូបស្រស់បស់នោះទេ, ស្រាប់តែក្បាក់ត្រីតដោយដួចប្រទះអាតមទៅវិញ, ឃើញក្បាលជាំក្រោម ជើងឡើងលើត្រង់កន្ទួងដែលបិសាចបានដាក់វាយ៉ាងណាតាំងពីយប់; លោកក៏សួរដោយសេចក្តីងឿងឆ្ងល់ថា "ចុះហេតុយ៉ាងម៉េចហ្នឹង? នរណាធ្វើកម្មអកងងយ៉ាងនេះ?" ។ អាតម ស្គាល់ជាក់ថាលោកអគ្គមហាសេនា ទើបឆ្លើយថា "យើ អើ! លោកនេះហើយឬដែលបានរៀបចំឲ្យខ្ញុំធ្វើមង្គលការជាមួយនឹងស្រីរបស់គាត្រប៊ី គឺជាសហាយនៃបិសាចបៃធ្រែ? ខ្ញុំនឹងលែងតាញ់បញ្ជោកលោកទៀតហើយ, លោកទាប់ខ្ញុំមិនបានទៀតទេ ប្រាប់ឲ្យដឹង" ។

លោកសេមះសេទឌិនម៉ូហាម្មេទ កាលបានឮអាតមនិយាយដូច្នោះ ទឹកស្មានថាជានិយាយចំអកឡកឡឺយលេងផ្តេសផ្តាស ទើបលោកតបថា "ចូរក្រឡាស់ត្រឡប់ក្បាលឡើងលើ ហើយឈរឲ្យត្រង់ស្រួលបួលទៅ កុំលេងយកក្បាលធ្វើជើង១ធ្វើក្បាលដូច្នេះមិនទំនងទេ" ។ អាតមឆ្លើយក្រោមថា "ទេលោក, បើថ្ងៃមិនទាន់រះទេ ខ្ញុំនឹងនៅតែធ្វើដូច្នេះឯង, (មានត)

# ប្រវត្តិពង្សាវតារជាតិ

## ពិធីនិក្ខមណាបុប្ផាទាន និង កម្មវិធីឈាបនកិច្ច

## ព្រះសពសម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយកគណៈមហានិកាយ

## ព្រះត្រៃលោកាធិរាជបរិយាត្រ ព្រឹទ្ធ ពង-កីង វៀចវៀង

---

### បឋមឧសកៈ វយៈទី ១

កុមារហ៊ិន ជាបុត្រលោកជំទប់លេខ១ នាមប្រាក់ មាតានាមផែន ជាតិខ្មែរ ស្រុកកំណើតនៅភូមិកំពង់ពោធិ៍ចារខាន់ ខេត្តព្រៃវែង រ ដោយប្រទេសកម្ពុជា សម័យនោះកើតវិបត្តិកក្តីប្រែ ជាទឹកមកហែង ហេតុនោះមាតាបិតារបស់លោកក៏ឃ្លាតចាកចំការខ្មែរមកនៅភូមិចាក់អង្គ្រ ស្រុកកំពង់សៀម ខេត្តកំពង់ចាម ហើយប្រសូតបុត្រ គឺកុមារហ៊ិន នាវេលាមជ្ឈិមយាមអធ្រាត្រត្រឹមស្វាត ថ្ងៃអាទិត្យ ៨ កើតខែបុស្ស ឆ្នាំកុរ បញ្ចស័ក នក្សត្រឫក្សពារជាប្រកតាំដែរ ត្រូវនឹងគ្រិស្តសករាជ ១៨៦៤ ក្រោយមក មាតាបិតានាំកុមារហ៊ិនមកនៅឃុំលេខ៦ ក្រុងភ្នំពេញ ធ្វើរបរជំនួញឬស្សី ជាសម្មាអាជីវៈ ដរាបដល់ស្រុកទេសសាន្តត្រាណ ទើបបានត្រឡប់ទៅនៅស្រុកកំណើតរបស់លោកវិញ រួចក៏នាំកុមារហ៊ិន ឲ្យទៅនៅវត្តសាំងសាម៉ៈ ដើម្បីឲ្យសិក្សាអក្សរសាស្ត្រខ្មែរ អំពីសំណាក់

លោកគ្រូព្រះមុនីវង្ស ទៅអធិការវត្តសាំងសាមី នាមព្រំ ក្នុងជន្មាយុ ១០ ឆ្នាំ សម័យនេះក្ដីមានជ័យ ក្នុងផែនដីព្រះបរម ៣ដូ ។

ទុតិយឧសភៈ រយៈ ទី ២

កុមារប្រាក់-ហ៊ុន សូត្ររៀនបឋមវិជ្ជាខេមរភាសា ចេះជិះមើល បាន សរសេរកើត ចេះចារទីងស៊ូត្រគ្នោត ចេះតែងសេចក្ដី ចេះលេខ នព្វន្តទាំង៤ ជាគ្រឹមានបរិក្ខ ហើយទៅក្នុងសញ្ញាសក្ខី ប្រែបរជាយកគញ្ញ គតវេទី ចេះជិះគោពេញប្រណាំបីគទ់មាតាបិតាដោយប្រពៃ លុះដល់ អាយុ ១៦ ឆ្នាំ ក៏លាមាតាបិតាមកបព្វជ្ជាជាសាមណេរដោយសទ្ធា ក្នុង សំណាក់ព្រះបព្វជ្ជាចារ្យ នាមព្រំ ក្នុងឆ្នាំជូតស័ក ត្រិស័ក្តសករាជ ១៨៧៦ សាមណេរប្រាក់-ហ៊ុនបួសឡើង មិនដែលល្មើសពាក់ខុសទីងពុទ្ធប្បញ្ញត្តិ ក្នុងសាមណេរភូមិសោះឡើយ ។ ជាអ្នកសង្រួមសមគួរតាមសាមណេរវិន័យ ហើយប្រតិបត្តិដោយល្អប្រពៃតាមខ្សែសេចក្ដីព្យាយាម៖ស្រាវ រៀនសូត្រធម្មវិន័យ ហើយប្រតិបត្តិដោយល្អក្នុងព្រះពុទ្ធសាសនា បាន ពីរវស្សា ជាទីពេញព្រះទ័យនៃព្រះឧបជ្ឈាយ៍ ក៏លាបានសិក្ខាបទមកជា យកកស បានរៀនចំណេះវិជ្ជាការហេតុគម្ពីរសិប្បិយការតើជាឆ្លាសជា ផ្សែសម្មាការ: បានឧបដ្ឋាកបំរើមាតាបិតាដោយគោរព ដោយសេចក្ដី ជ្រះថ្លាស្មោះត្រង់ចំពោះគុណជាទីបំផុត ។

តតិយឧសភា: រយៈទី ៣

ជីប្រាក់-ហ៊ិន អាយុ ២១ ឆ្នាំ មានចិត្តនឿយណាយក្នុងភេទ យកវាសប្រុះថ្លាក្នុងភេទបព្វជិត គិតប្រាថ្នាទីងតបស្នងសងគុណមាតាបិតា ទើបលាលោកអ្នកដែលមានគុណចាកបព្វជ្ជាឧបសម្បទា ក្នុងព័ទ្ធសីមាវត្ត សាំងសាមី ខែត្រព្រៃវែង ។

ព្រះមង្គលញ្ញាណ នាម នួយ ជាព្រះឧបជ្ឈាយ៍

ព្រះចន្ទសរេក នាម ព្រំ ជាកម្មវាចាចារ្យ

ព្រះឥន្ទត្ថេរ នាម សុខ ជាអនុសាវនាចារ្យ

ព្រមព្រៀងដោយគណសង្ឃ ២១ អង្គ ជាសង្ឃបក្ខ ឲ្យឧបសម្បទា ដល់ភិក្ខុប្រាក់-ហ៊ិន សម្រេចដោយចតុត្ថកម្មវាចាក្នុងថ្ងៃព្រហស្បតិ៍ ខែអាសាឍ ឆ្នាំមមែបញ្ចស័ក ព.ស. ២៤២៣ គ្រិស្តសករាជ ១៨៨៣ ព្រះឧបជ្ឈាយ៍ឲ្យនាមបញ្ញត្តិក្នុងភិក្ខុភាវៈជាបទុមត្ថេរ ។ ចាប់ដើមពីបាន ឧបសម្បទាថ្ងៃណាមក ភិក្ខុប្រាក់-ហ៊ិន ជាអ្នកប្រតិបត្តិក្នុងធម្មវិន័យ រីឃានរៀនសូត្រហួតផល់ ចេះចាំភិក្ខុបាតិមោក្ខស្ទាត់មាត់ខេ ចេះចាំ កាណាកប្បាលីយ៉ាងស្ទាត់ជំនាញ ចេះទេសនាសាស្ត្រាយសព្វគ្រប់ គម្ពីរ ចេះបទប៊ែបសកេត្យា: របៀបបុរាណ ។ បានចំរើនការនៅ គបបញ្ចកកម្មដ្ឋាន ដែលបានរៀនមកពីសំណាក់ព្រះឧបជ្ឈាយាចារ្យ ក្នុងវេលនៃភេទភូមិ ៥ វស្សា បានទទួលនាទីជាឧបសម្បទាចារ្យទី ២ នៃក្រុ

សុត្រខេន្ត ជាអ្នកស្រុករកមោក្ខធម៌ប្រព្រឹត្តតាមពុទ្ធដីកាទ័រហោស្នាំ នៅព្រហ្មវេណ៍អណ្ដែត នៃត្រៃព្រៃវែង លុះដល់ស្រុកទី ៨ កន្ឆ្នាំ រាលឯកស័ក ព.ស. ២៤៨១ ត្រូវសករាជ ១៨៩១ គ្រូសូត្រ ប៉ាក់-ហ៊ុន បានលាព្រះឧបជ្ឈាយាចារ្យមកសិក្សាព្រះបរិយត្តិធម៌ ។

ទី ១ អំពីសំណាក់លោកគ្រូព្រះបាឡាត់គនវង្សនាមទិម នៅអធិការវត្តកោះចិន ស្រុកពញាឮ នៃត្រកណ្ដាល បាន ១ ព្រះវស្សា លុះដល់ព្រះបាឡាត់គនវង្សមានកិច្ចមន្តទៅប្រទេសសៀម ទើបគ្រូសូត្រប៉ាក់-ហ៊ុន និមន្តមកគង់នៅវត្តសាកវ័នតេជោ ក្រុងភ្នំពេញ បានសិក្សាព្រះត្រៃបិដកពីសំណាក់ព្រះធម្មាចារ្យទាំង ៧ រូបនេះ គឺ:

ទី ២ ព្រះតេជព្រះគុណព្រះធម្មលិខិតព្រះនាមស៊ីវ

ទី ៣ ព្រះតេជព្រះគុណខេមញ្ញាសុធម្មមេធាចារ្យ នាម រ័ត្ន

ទី ៤ លោកគ្រូព្រះមហា កុប

ទី ៥ ព្រះអាចារ្យ កែវ

ទី ៦ ព្រះអាចារ្យ នង

ទី ៧ ព្រះតេជព្រះគុណខេមញ្ញាសុធម្មមេធាចារ្យ នាម អ៊ុង

បេះដូងសមគួរសំដែងធម៌បាន ទំនងជាក្ដីបង្រៀនគេកើត ទទួលទំនុកទុកចិត្តបានខ្លះ ដោយយកកម្លាំងព្យាយាមប្រតិបត្តិតាមដោយសមគួរដល់ប្រាជ្ញានៃខ្លួនដែលបេះដូង ។

## ចតុត្ថឧសករៈ រយៈ ទី ៤

លោកគ្រូអាចារ្យប្រាក់-ហ៊ិន អាយុ ៣១ ឆ្នាំវស្សា ១១ បានឡើងសមណស័ក្តិថានា ជាបាឡាត់ឃោសធម្មក្នុងថ្ងៃ ១ រោចអាសាឍ ឆ្នាំម្សាញ់បញ្ចស័ក ព. ស. ២៤៣៥ គ្រិស្តសករាជ ១៨៩១ ដល់អាយុ ៣៤ ឆ្នាំ វស្សា ១៤ ព. ស. ២៤៣៨ គ្រិស្តសករាជ ១៨៩៦ បានឡើងជាបាឡាត់ធម្មបតី បានបំពេញកិច្ចការសាសនា តាមដំណែងមុខក្រសួងជាត្រឹមត្រូវសុខចំរើនល្អ លុះដល់អាយុ ៣៦ ឆ្នាំ វស្សា ១៦ សម្តេចព្រះមហាសង្ឃរាជា ព្រះនាមទៀន ក្នុងព្រះគោដ្ឋ ទ្រង់ព្រះតម្រិះយល់ឃើញថាព្រះបាឡាត់ធម្មបតី (ហ៊ិន) មានសុវិជ្ជាវត្តបរិយាសម្មាប្រតិបត្តិតាមលេះដើងទីងប្រព្រឹត្តល្អក្នុងធម្មវិន័យ គួរគប្បីឲ្យឡើងជាព្រះរាជាគណៈបាន ទើបទ្រង់ថ្វាយព្រះពរសុំព្រះរាជានុញ្ញាតព្រះបាទសម្តេចព្រះនរោត្តមសុវណ្ណកោដ្ឋ ៗ ទ្រង់ប្រោសព្រះរាជានុញ្ញាតតាំងព្រះបាឡាត់ធម្មបតី ជាព្រះសុធម្មត្ថេរទើកជាគណៈសម្រាប់ក្រុងក្នុងថ្ងៃ ១ រោចអាសាឍ ឆ្នាំរកា ព. ស. ២៤៤០ គ្រិស្តសករាជ ១៨៩៨ ។

## បញ្ចមឧសករៈ រយៈ ទី ៥

ក្នុងជន្មាយុ ៤៨ ឆ្នាំ វស្សា ២៨ ក្នុងផែនដីព្រះករុណាព្រះបរមរាជា-ខុគោដ្ឋ សម្តេចព្រះមហាសង្ឃរាជាទីងព្រះបរមរាជាខុគោដ្ឋ ទ្រង់ប្រោសព្រះរាជតាំងព្រះសុធម្មត្ថេរ ហ៊ិន ជាចៅអធិការវត្តសាកលែកជា

ឃុំលេខ ៣ ក្រុងភ្នំពេញ ក្នុងថ្ងៃ ៧ ឆ្នាំកុរ ត្រីស័ក ព.ស. ២៤៥២ គ្រិស្តសករាជ ១៩១០ ព្រះសុធម្មត្ថេរ ហ៊ុន បានទទួលនាទីជាចៅអធិការវត្តនេះថ្ងៃណាមកក៏យកព្រះទ័យទុកដាក់ក្នុងកិច្ចធុរៈការសាសនា ព្យាបាលរក្សាសង្ឃឲ្យបានសេចក្តីសុខ ចំរើន បានទំនុកបំរុងភិក្ខុសាមណេរដែលនៅក្រោមឱវាទដោយកិច្ចសាកណីយធម៌ ៦ ប្រការ គឺ:

១ - មានកាយកម្មប្រកបដោយមេត្តា

២ - មានវចីកម្មប្រកបដោយមេត្តា

៣ - មានមនោកម្មប្រកបដោយមេត្តា

៤ - រំលែកចែកលាភដែលបានមកដោយធម៌

៥ - មានសីលបរិសុទ្ធជាទីស្រឡាញ់

៦ - មានទិដ្ឋិយល់ត្រូវតាមផ្លូវព្រះពុទ្ធសាសនា

បានកសាងដាក់ដីបំពេញទីធ្លាកម្មនេះឲ្យពេញស្មើល្អ ធ្វើកំពែងវត្តព័ទ្ធជុំវិញដោយឥដ្ឋនិងបេតុងអារម៉េ សាងបល្ល័ង្កព្រះបដិមាករធំក្នុងទីព្រះវិហារពេង១ បោសបចាស់ កសាងព្រះវិហារពេង១ បោសបថ្មីមួយខ្នង ហើយកសាងព្រះពុទ្ធរូបធំព្រះភក្ត្រ ៣ ម៉ែត្រ ទុកជាគោលបារីក្នុងព្រះវិហារវត្តសាកវ៉ែន សម្រាប់ជាទីធ្វើសក្ការៈគោរពបូជានៃពុទ្ធបរិស័ទជាសាធារណៈទូទៅ សាងកុដិ ១ ខ្នង សាងសាលាសម្រាប់ធ្វើជម្នាខមិនគាថាសពាន ២ ខ្នង កសាងព្រះស្តូបចេតិយក្នុងវត្តនេះ ១ ក្នុងវត្តសាំង.

សាម័ ១ ដំកល់ព្រះពុទ្ធរូបចតុះធាតុមាតាបិតា បានថែទាំរក្សាស្អិតស្អាង ព្រះពោធិព្រឹក្សប៉ៃដើមក្នុងវត្តនេះ បានកសាងគម្ពីរព្រះត្រៃបិដកស្ទើរតែចំនួន ៦៤ គម្ពីរ សាងព្រះពុទ្ធរូបសិតដោយលោហធាតុ ៤ ព្រះអង្គទំហំកែន ៧ តឹកសួនអង្គ ។

ជដ្ឋមធសកា: រយ: ទី ៦

ព្រះសុធម្មត្តេរ បានស័ក្តាបំពេញព្រះវិបស្សនាធុរៈអំពីសំណាក់ព្រះធម្មាចារ្យចាំន ៩ ព្រះអង្គ គឺ:

១ - ព្រះតេជព្រះគុណព្រះមគ្គញ្ញាណបាទ្ទចបជ្ជាយាចារ្យ
២ - ព្រះតេជព្រះគុណ ឯកញ៉ាំនាកធិបតី នាម ប្រាក់
៣ - លោកគ្រូម្ចាស់វៃព្រែក.ណៀង នាម ម៉ុំ
៤ - លោកគ្រូម្ចាស់គ្គកណ្ដាល នាម ព្រំ
៥ - ព្រះអាចារ្យ ប៉ាន់
៦ - ព្រះអាចារ្យ តាស
៧ - ឯកញ៉ាំកជសម្បត្តិ នាម ជួន
៨ - ព្រះគុណម្ចាស់ថ្មកែវ
៩ - ព្រះធម្មាចារ្យ នាម ជុក ខេត្តបាត់ដំបង

## សត្តមទសកៈ វយៈទី ៧

ដល់ជន្មាយុ ៦៨ ឆ្នាំ វស្សា ៤៨ ថ្ងៃ ។ ឆ្នាំជូតបញ្ចស័ក ព.ស. ២៤៧២ គ្រិស្តសករាជ ១៩៣០ ក្នុងផែនដីព្រះបរមខត្តិយកោដ្ឋបាន ឡើងជាព្រះពុទ្ធឃោសាចារ្យ ក៏ជាគណៈសម្រាប់ទោ បានប្រជុំពុទ្ធបរិស័ទ្យធ្វើបុណ្យបញ្ចុះខណ្ឌសីមាវត្តសាកវ័នគេហៅជាទឡ្ហារិក ក្នុង គ្រិស្តសករាជ ១៩៣២ ។

## អដ្ឋមទសកៈ វយៈទី ៨

ក្នុងជន្មាយុ ៧១ ឆ្នាំ វស្សា ៥១ ថ្ងៃ ។ ឆ្នាំរកាអដ្ឋស័ក ព.ស. ២៤៧៥ គ្រិស្តសករាជ ១៩៣៣ ព្រះករុណាបរមខត្តិយកោដ្ឋ ទ្រង់ ប្រោសព្រះរាជទានតាំងជាព្រះពោធិវ័ង្ស ក៏ជាគណៈសម្រាប់ឯកទ្រង់ រ័តន៍ នឹងជាអធិបតីព្រះរាជពិធីកាណយក្ស លុះដល់ជន្មាយុ ៧៥ ឆ្នាំ វស្សា ៥៥ បានឡើងស្ដីទីជាសង្ឃនាយកគណមហានិកាយ ព្រះរាជក្រឹត្យលេខ ៦ ចុះថ្ងៃ ១ ខែហ្វេព្រីយេរ ឆ្នាំ ១៩៣៨ ។ លុះដល់ជន្មាយុ ៧៧ ឆ្នាំ វស្សា ៥៧ ឡើងពេញទីជាព្រះសង្ឃនាយក ព្រះរាជក្រឹត្យ លេខ ២២ ចុះថ្ងៃ ១៧ ដេសាំប្រ៍ ឆ្នាំ ១៩៤០ ព្រះជន្មាយុ ៧៨ ឆ្នាំ វស្សា ៥៨ បានទទួលគ្រឿងមហាស្សរិយយស ទីជាវិសេសនៃក្រុងកម្ពុជា ព្រះរាជក្រឹត្យលេខ ២៣ ចុះថ្ងៃ ២៨ អុកតូប្រ៍ ឆ្នាំ ១៩៤១ ព្រះជន្មាយុ ៧៩ ឆ្នាំ វស្សា ៥៩ បានទទួលគ្រឿងមហាស្សរិយយសជាខ្ពស់ជាទី

អស្ចារ្យក្រៃពេកពិសេស តាមប្រកាសដេក្រេ ចុះថ្ងៃ ១៦ មករា ឆ្នាំ ១៩៦២ ព្រះសង្ឃនាយកគណមហានិកាយ បានធ្វើកឋិនទាននិងធាតុបង្សុកូលចំនួន ១៥ វត្ត ដើម្បីឧទ្ទិសផលជូនដល់លោកអ្នកដែលមានគុណមានមាតាបិតាជាដើម បានបំពេញកិច្ចការសាសនាក្នុងមុខក្រសួងដោយផ្ទាល់សុចរិតយុត្តិធម៌ប្រកបដោយសេចក្តីសុខសាមគ្គីចំរើនល្អ មានគុណបំណាច់ក្នុងក្រុងកម្ពុជាធិបតី លោកអធិបតីនៃការប្រតិបត្តិ បានសុំគ្រឿងមហិស្សរិយយសឧត្តមខ្ពង់ខ្ពស់ពីមហានគរកាណាព្យាបាល ប្រគេនទុកជាសំគាល់គុណបំណាច់ស្រាប់ ។

ឆាមធសក្ក: រយៈ ទី ៩

ព្រះជន្មាយុ ៨០ វស្សា ៦០ បានឡើងសមណសក្តិជាន់ខ្ពស់ ជាទីសម្តេចព្រះពោធិវង្សសង្ឃនាយកគណមហានិកាយ នៅថ្ងៃសុក្រ ៣ កើតខែពិសាខ ឆ្នាំខាលចត្វាស័ក ព.ស. ២៥០៥ ត្រូវនឹងថ្ងៃ ១៧ ខែអាព្រីល ឆ្នាំ ១៩៦២ ។

ក្នុងជន្មាយុ ៨១ វស្សា ៦១ បានឡើងសមណសក្តិជាន់ខ្ពស់បំផុតជាទីសម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយកគណមហានិកាយ នៅថ្ងៃសុក្រ ១ កើតខែអាសាឍ ឆ្នាំថោះបញ្ចស័ក ព.ស. ២៥០៦ ត្រូវនឹងថ្ងៃ ១៥ ខែកក្កដា ឆ្នាំ ១៩៦៣ ។

ក្នុងជន្មាយុ ៨៥ វស្សា ៦៥ សម្តេចបានទទួលគ្រឿងឥស្សរិយយសៈកម្មជាន់ខ្ពស់ ជាទីសេនាក្រមថ្នាក់ពិសេស តាមដីកាលេខ ២៣០-៤៤៨ ចុះថ្ងៃ១២ ខែយ៉ាំងវីយេ ឆ្នាំ ១៩៤៨ ពីក្រុងបារីស ។

អំពីស្នាព្រះហស្តជាកេរ្តិ៍ដំណែលរបស់សម្តេចពៅបំផុត

១- សម្តេចបានកសាងព្រះផ្ទះទាំងដ៏ល្អដែលជាកន្លែងទុកព្រាស-ជាគារដ្ឋានចាស់ ទុកជាគោលចារឹកវត្តសារីនកនេះតទៅ បម្រុងទុកប្រតិស្ឋានព្រះសារីរិកធាតុ, ព្រះពុទ្ធបដិមា, ព្រះត្រៃបិដក, គម្ពីរក្បួនច្បាប់ពុទ្ធសាសនា, អាក្រណ្ណផ្សេងៗ, សម្រាប់សិក្សាគន្ធធុរៈនិងវិបស្សនាធុរៈ ។

២- សម្តេចបានចុះព្រះនាមអនុញ្ញាតឲ្យព្រះគ្រូពោធិវង្សបរិយាត្រ ពេជ គីង ជាអ្នកដំណើរការកសាង ចាត់ការសាងសាលាបាលីរង និងបង្កើតនៅដូចមានសេចក្តីយល់ព្រមពីសម្តេចលេខ ៤០៧-៤០៩ ចុះថ្ងៃ ២១-២៣ ខែយូកុំង និងលេខ ៤២៨ ចុះថ្ងៃ ២ ស៊ុយយេត ឆ្នាំ ១៩៤៧ ស្រាប់ ។

អំពីបណ្តាំសម្តេច

១- បានដល់គោលលក្ខណៈពាក្យរបស់សម្តេចទាំង ១៧ ដែលកែដោយព្រះពុទ្ធផ្សាយរួចហើយក្នុងកម្ពុជសុរិយា ឆ្នាំទី ១៧ លេខ ១ ខែយ៉ាំងវីយេ ឆ្នាំ ១៩៤៥ ជាផ្សាយស្រាប់ ។

២ · មគ្គបួនផលបួនត្រឹម ទិសសាយសព្វតែងខ្វះខាត ជាធម៌ទុក
ឲ្យតាន រៀនឲ្យបានស្ពានបរលោក ។ បៀសបាតអកុសល ក្តីអំពល់
ពីទុក្ខសោក រូបកងតែងស្មោកគ្រោក គួរឲ្យរកព្រះអរហំ ។ គួរ-អំ
ជាត្រួយ បណ្តូលមួយមានសង្ខ ខន្តិដើមធម៌ កតញ្ញូតំជាតល់តាប ។

៣ — ព្រះនាមបញ្ចកខ្ម លក្ខណញ្ញាណកាន់ឲ្យខ្ជាប់ គួរពិះគួរ
រៀនត្រាប់ ត្រង់ណាគាប់កាន់តេជ្រា ។ បុគ្គលបុគ្គលា មានបញ្ញា
បញ្ញាច្បាស់ គួរចំរេចំពស្រះ ធ្មុះផ្រែះសោកអសោច ។ រូបកងយើង
សព្វថ្ងៃ តិតតាល័យខុបតែខ្ទោច អសុភសាកអសោច ផតញ្ញញ្ញោច
ញញើតឡើយ ។ គួរពិះរករកំង រកព្រះអរហំរៀនឲ្យហើយ កុំស្ងៀម
ស្ងាត់តន្ទើយ រៀនឲ្យហើយព្រះអរហំ ។ កាលណាខឹងរំលាង កល់រូប
កងដោយកំលកំង ទៅហើយបានព្រះអរហំ នាំធក់ធាង់រូបកយា ។
អ្នកណាបានធម៌ព្រះ ជឿជាក់ច្បាស់កាន់តេជ្រា ស្មើបានយានគេត្រា
នាំមាតាបិតាបាន ។ គេជះតែវមុនិ ព្រះជិនស្រីទ្រង់ប្រោសប្រាណ
នាំសត្វបួនទិព្វាន សត្វខ្វះខាតឯក្រោយគ្រាស់ ។ ព្រោះហេតុ
មោហៈធំ មករួបរុំព្រាត្បុះ អ្នកណាចង់ឲ្យជ្រះ គួរខំស្តាប់ព្រះធម៌ថ្ងៃ ។
កុំខំលេងទំពា សោភាស្រុកថ្នាំពិសពុល ដូចតែកូនខ្លាក់ពុំយល់ ដើរ
ដផ្លែលធ្លាក់រណ្តៅ ។ ពាលាពាលេខ្លាំង បានធម៌ហើយបោលទៅ
អ្នកប្រាជ្ញប្រែជាខ្មៅ ព្រោះកម្មៅពុំជឿបុណ្យ ។

៤ — សច្ចំពាក្យពិត រួបរស់ជីវិត ជាសុខក្សេមក្សាន្ត ជាច្រើន ជាតិច តិចនៃជាគ្មាន ពុំផលហួសហាន ពោលពាក្យមុសា ។ សច្ចំពាក្យត្រង់ ស្ងួរស្ងាប់មិនបង់ រៀបរេស្រដ៏ ឲ្យផន់សត្យា ឲ្យជា គប្បីយ សច្ចំក្រៃក្រ ក្រអួតក្រាប់បាន ។ សច្ចំឧត្តម សីលនេះ ជាធំ លើសសីលនានា ពីរយោម្តែប្រាំ- ពីរសីលសីលា សច្ចំជាបា មេសីលទាំងឡាយ ។ សច្ចំប្រៃជាន រកសុបុណ្យគ្មាន ប្រៀបផ្ទឹម ពុំបាន ឯសីលសច្ចំ ធំក្រៃកន្ទ្រឹន បំពុំនឹងបាបផង ប្រសើរឧត្តម ។

៥ — ខន្តីប្រៃជាន ប្រសើរលើសទាន ធំក្រៃកន្ទ្រឹន ជាមេ អស់ផល អស់កុសលផង កម្រប៉ិត្តបង បានសីលខន្តី ។

៦ — អកញ្ញូតា ខ្សោកណា ដឹងគុណគេខ្ញី ឃ្លានិតមិនជាប់ ក្តាំងក្រុបស្តាត ប៉ៃបុឲ្យបាលី ធម្មូលា ។ ជាដើមតល់ប្ញុស ព្រះធម៌ទាំងអស់ កតិបតុក- សិតិឃមាសុ- ធម្មគ្គា នាលោកុត្តរ ប្រាំបីម៉ឺនបួនពាន់ ។ នាលោកុត្តរ ប្រៃជានបារ ព្រះធម្មគ្គន កើត ពីដឹងគុណ គួរគិតគិតកាន់ ប្រៃជាពេញ នវិជ្ជត ។ រកសុបុណ្យ គ្មាន ចម្រើនមាន កតញ្ញូតា ដឹងគុណ តម្កើរ លន់លើសនានា ប្រៃជានបុញ្ញ ប្រៃជាខបុណ្យផង ។ កតញ្ញូតា នេះជាចំនង ធម៌បីគន្ធីន ផ្ទួព្រះនិព្វាន ។

២ · មគ្គបួនផលបួនត្រឹប ទិសសាយសព្វកែនវុន្ទាន ជាធម៌ខុន ឲ្យគាន រៀនឲ្យបានស្ពតបរលោក ។ ចៀសចាកអកុសល ក្តីអំពល់ ពីទុក្ខសោក រូបកាយកែងស្មោកគ្រោក គួរឲ្យរកព្រះអរហំ ។ គួរ-អំ ជាត្រៃយ បណ្តូលមួយមានបញ្ចុំ ទ្រទ្រង់ដើមធម៌ កតញ្ញូជាគល់គាប់ ។

៣ — ព្រះនាមបញ្ចក្ខន្ធ លក្ខណញាណកាន់ឲ្យខ្ជាប់ គួររកគួរ រៀនត្រាប់ តែងណាតាប់កាន់រក្សា ។ បុគ្គលបុគ្គលោ មានបញ្ញា បញ្ញាច្បាស់ គួរចាំរកចិត្តស្រះ ធ្វើតជម្រះសាកអសោច ។ រូបកាយយើង សព្វថ្ងៃ គិតគាល័យទុបកែខ្ពាប អសុភសាកអសោច ផតញ៉ញោច ញាញើតឡើយ ។ គួររិះរករាំង រកព្រះអរហំរៀនឲ្យហើយ កុំស្ទៀម ស្ងាត់តហើយ រៀនឲ្យហើយព្រះអរហំ ។ កាលណាខឹងរំលាង កល់រូប កាងដោយកល់កាំង ទៅហើយបានព្រះអរហំ នាំឆក់ជាងរូបកាយ ។ អ្នកណាបានធម៌ព្រះ ជឿជាក់ច្បាស់កាន់រក្សា ស្មើបានយានរកត្រា នាំមាតាបិតាបាន ។ គេជះកែវមុនី ព្រះជិនស្រីទ្រង់ប្រោសប្រាណ នាំសត្វរួចទុក្ខាន សត្វខ្វះខានឯក្រោយក្រាស់ ។ ព្រោះហេតុ មោហៈធំ មករួបរុំពុំស្រឡះ អ្នកណាចង់ឲ្យជ្រះ គួរខំស្តាប់ព្រះធម៌ថ្ងៃ ។ កុំខំលេងចិត្ត លោភស្លុតថាពិសពុល ដូចកែកត្វាក់ពុំយល់ ដើរ ជជ្រែលធ្លាក់រណ្តៅ ។ ពាលាពាលខ្លាំង បានធម៌ហើយចោលទៅ អ្នកប្រាជ្ញប្រែជាខ្លៅ ព្រោះកម្មៅពុំជឿបុណ្យ ។

៤— សច្ចំពាក្យពិត រួចរស់ជីវិត ជាសុខក្សេមក្សាន្ត ជាច្រើន ជាតិប តិចរៃងជាគ្មាន ពុំផលហួសហ៊ាន ពោលពាក្យមុសា ។ សច្ចំពាក្យត្រង់ ស្ញូវស្ញាប់មិនបង់ វៀចវេរស្រដី ឡេចង់សត្យា ឡេជា គប្រិយ សច្ចំក្រៃក្រៃ ក្រអួតត្រាប់បាន ។ សច្ចំឧត្តម សីលនេះ ជាធំ លើសសីលនានា ពីរបេះម្ភៃប្រាំ- ពីរសីលសីលា សច្ចំជាបា រមេសីលទាំងឡាយ ។ សច្ចំប្រពាន រកអស់បុណ្យគ្មាន ប្រៀបផ្ទឹម ពុំបាន ឯសីលសច្ចំ ដ៏ក្រៃគគ្រឹន ប៉ិចប៉ាំងបាបផង ប្រសើរឧត្តម ។

៥— ខន្តីប្រពាន ប្រសើរលើសពាន ដ៏ក្រៃគគ្រឹន ជាមេ អស់ផល អស់កុសលផង កម្រពិត្តបង បានសីលខន្តី ។

៦— កតញ្ញូតា ខ្សែកណា ដឹងគុណគេខ្ទី ឃ្មានទីពមិនជាប់ ភ្ជាំងក្រូចស្នាគេ បែបបទបាលី ធម្មមូលា ។ ជាៈដើមគល់ឫស ព្រះធម៌ទាំងអស់ កន៍បត្តុក- សិតិឋហាស្ស- ធម្មគ្គា ទលោកុត្តរ ប្រាំបីម្ភុនបួនពាន់ ។ ទលោកុត្តរ ប្រពានបវរ ព្រះធម្មក្ខន្ធ កើត ពីដឹងគុណ គួរគន់គិតការ ប្រពានបញ្ញាំ ទវិជ្ជតិ ។ រកអស់បុណ្យ គ្មាន ខម្រមួគមាន កតញ្ញូតា ដឹងគុណៈតដ្ដើស លន់លើសនានា ប្រពានបុញ្ញា ប្រពានបុណ្យផង ។ កតញ្ញូតា នេះជាចំនង ធម៌ចិគទ្ធង ជួរព្រះនិព្វាន ។

៧ – សុខា សង្ឃស្ស សាមគ្គី ការព្រមព្រៀងគ្នា នៃគណៈសង្ឃ ជាហេតុនាំមក នូវសេចក្តីសុខ ។

# អំពីអាយុបរិយោសានកាល

សម្តេចចាប់ប្រឈួនខ្លួនតាំងពីថ្ងៃ ១ ៗ ១១ ១១ ឆ្នាំកុរនព្វស័ក ព.ស. ២៤៩០ ត្រូវនឹងថ្ងៃ ៩ វិច្ឆិកា ឆ្នាំ ១៩៤៧ ។

ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រមទាំងសម្តេចព្រះវររាជជននីនាថ សម្តេចព្រះវររាជបិតា ទ្រង់បានជ្រាបហេតុករណ៍នោះហើយ ស្តេចមកថ្វាយបង្គំគាល់ដល់ទីកុដិផ្ទាល់ព្រះអង្គ ដោយគតញ្ញូកតវេទិតាធម៌ពេញទី ។ ខណៈនោះសម្តេចជាម្ចាស់ចក្រាប់ហៅព្រះគ្រូពោធិវង្សបរិយាត្រ កជ - គីង និងព្រះបាឡាត់សង្ឃវង្ស ឌុម - ហេង ឲ្យគ្រាប់ព្រះអង្គលោកចេញមកពីខាងក្នុងបន្ទប់ ជួបព្រះភក្ត្រទាំងបីព្រះអង្គ សម្តេចមានថេរដីកាថា "សូមថ្វាយព្រះពរ! អាត្មាភាពបានជួបព្រះភក្ត្រទាំងបីព្រះអង្គបំណាច់អស់ចិត្តហើយ បើស្លាប់ក៏ស្លាប់ចុះ!" ទាំងបីព្រះអង្គ ទ្រង់ចាត់ការឲ្យអញ្ជើញលោកគ្រូពេទ្យយ៉ាងបណាន់ៗ មកព្យាបាលព្រះរោគសម្តេច ព្រមទាំងព្រះរាជាគណៈ ឋានានុក្រម គណៈសិស្សានុសិស្សទាំងបព្វជិតទាំងគ្រហស្ថ ជួបជុំមូលមិត្តព្រមព្រៀងគ្នាគោរពប្រណិប័តន៍ថែទាំរក្សា ទាំងថ្ងៃទាំងយប់ឥតស្រាកស្រាន្ត រៀង

កបដកបមកដល់ថ្ងៃព្រហស្បតិ៍ ៨ កើត ខែកត្តិក ឆ្នាំកុរនព្វស័ក ព.ស. ២៤៩០ ត្រូវនឹងថ្ងៃ ២០ ខែវិច្ឆិកា ឆ្នាំ ១៩៤៧ នៅវេលាពាក់កណ្ដាលអធ្រាត្រម៉ោង ១២ ពូជ៍ត្រាៈនោះឯង មរណសន្ត្រាសបះតែរុកភនទទ្រានឧបួលមត សម្ដេចទប់ទល់ពុំបានក៏ទទួលអនិច្ចធម្មនិមន្តទៅកាន់សុគតិហោលយើងគ្រប់គ្នា ។

ធ្វើនៅត្រីសាកខែ ថ្ងៃ ១ ៗ ៣ ១២ ឆ្នាំកុរនព្វស័ក ព.ស. ២៤៩០

ត្រូវនឹងថ្ងៃ ៧ មីនា ឆ្នាំ ១៩៤៨

អ្នករៀបរៀង

ព្រះគ្រូពោធិវង្សបរិយាព្រំ

ភជ - កាំង

(នៅមានពិធីទក្ខិណានុប្បទាន និង កម្មវិធីឈាបនកិច្ច

ព្រះសពសម្ដេចតទៅទៀត)

យុវចរិយាកថា

# ព្រះគ្រូបញ្ញាលិខិត កៅ-ស៊ុម

គ្រូបង្រៀនសាលាបាលីជាន់ខ្ពស់រៀបរៀង

(តមកនិងចប់)

---

ខ្លះទ្រទ្រង់នៅថា: នៅខាំងគេនេះត្រូវខេចផ្កាសាថា: "អានោ ម៉ែយអានោ!" ញ៉ែះដឹងតែកេតែធ្វើការនោះអ៊ីមិនកើត ៗ ថៃស្ពៃណាស់ ផេរស្ពៃថា: អាថៃអើយអាថៃ! ស្ពៃម៉ែងឯងអីម៉្លេះ!" ធ្វើការនោះមិនកើត ស្លាប់ដំណាំជាដុះអស់ នៅព្រួយខ្លួនប៉ុណ្ណា, បើថៃជាភ្នានថៃស្ពៃវិញ ត្រឡប់ជាត្រជាក់ នេះត្រជាក់ថា: "មុចកឹ្មានថៃសោះ ឡក់ទៅឯណា ទៅអេះ! ក៏បានជាអាត្រជាក់ដល់ម៉្លេះ!" ញាក់ជើងញាក់ដៃស្ទើរតែចាប់កាន់របស់នេះនោះមិនកើត ហាលស្រែស៊ីមិនឆ្អែត យ៉ាងនេះក៏មាន ៗ

សេចក្តីក្រោធខឹងបែបនេះ ព្រះសម្មាសម្ពុទ្ធទ្រង់ពោលទុកជាអនេក-ស្ថាន តែជាគួប្រាប់ឲ្យបាន ត្រង់ពាក្យបោរាណ ចាស់លោកពោលទុកថា: "ខឹងអប្រាជ្ញា ពោលស្តីលេងថា ប្រាជ្ញឥតមាយោគ" ជាគួយ៉ាង ១

មួយ៉ាងទៀត សេចក្តីក្រោធខឹងនេះ បើក្រោធខឹងរាយដំ ប្រែជាក់កាចសំឡាប់ពានលើលោកអ្នកមានគុណ មានមាតាបិតាជាដើមនោះៗ ខឹងមានទោសជាទម្ងន់ក៏ទទួលបន្ទុកនេះផង ខឹងបរលោក

ផង កុំថាឡើយដល់ទៅកាប់ចំណាក់ សូម្បីតែក្រោមទង់បដិបត្តិ ចំពោះពាក្យខ្ញុំទាន់ប្រៀនប្រដៅ របស់មាតាបិតា បើឲ្យធ្វើការងារទាំងពួង ហាមប្រែចំការជាដើមក្តី ឬក៏បោះទៅឲ្យរៀនសូត្រនៅណាមួយក្តី គួរទៅតាំងនោះមិនចង់ទៅធ្វើការងារនោះៗ រៀនសូត្រនៅទីនោះៗ កើតសេចក្តីក្រោធខឹង ព្រោះតែសេចក្តីខ្ជិលច្រអូស មិនចង់ទៅធ្វើមិនចង់ទៅរៀនសូត្រក៏មាន យុវជនប្រព្រឹត្តរឹងបែបនេះ លោកពោលណាមិយមលោក ហៅថា: "រឹងទាគប្រហោជន៍" ជាគួយ៉ាង ១

ពួកជនខ្លះខឹងពេលកាលបាបសាចដល់ព្រេងសំណាងរបស់ខ្លួនថា: "ធ្វើអ្វីមិនបេះបាន, មិនបេះកើតទឹងគេ រៀនវិជ្ជាអ្វីមិនបេះដឹងដូចគេ នៅតែស្លាប់ក្រោមបង្គាប់គេ ខ្ញុំគេតាំងសំពុក" បើគំនិតបែបនេះ ឈ្មោះថា ខឹងខុសទំនង ជាមនុស្សដេតដាក់ពិន់ផ្លូកទៅលើព្រេងសំណាងៗ នេះ មិនស្មើគឹងសេចក្តីព្យាយាមបិត្តខ្មាស់ ការដែលព្យាយាមបិត្តមួលគំនិតគ្នា ខំប្រឹងប្រែងធ្វើការងារខឹងរៀនវិជ្ជាគប់ទំពូកនោះៗ ទើបធ្វើងរូបបានសេចក្តីចុះលំបាកក្នុងលោកនេះបាន ភាសិតបុរាណថា "កំជិលរៀនប្រៀន ខ្ជិលសូត្រខ្ជិលរៀន បានអ្វីនឹងបេះ បេះពាក់រៀន មានពាក្យ" ជាគួយ៉ាង ១

ពួកជនខ្លះខឹងឆ្កៅក្រមាល់ដល់ក្រុមញាតិសន្តាន ឬកូនប្រពន្ធរបស់ខ្លួនបរៀងធ្វើអ្វីដល់គេមិនកើត គឺត្រឡប់ជាប្រទុស្តដល់របស់ដែលឥតវិញ្ញាណ ស្លុះទាក់យធ្នាំងអម្បែង, បំបែកចានទឹក, ក្អមទឹក,

ក៏យកវត្ថុទាំងនោះប្រើប្រាស់ ពុំនោះសោត ស្ទុះទៅផ្ញើសំពត់សារ អាវស្បៃយកមកដុតចោលក៏មាន ទង្វើនេះលោកហៅថា: "មនុស្សកព្រោល ៤ ជ្រុង" ទង្វើក្រឡែមប៉ូវកព្រោលគត់ជាប់នោះ ផលថ្លាក់ពាប់ទៅ-ការ សំពត់ស្លៀកហោកបកចេញពីខ្លួន ដើរខ្លួនទទេទៅក៏មានខ្លះដែរ ។

អាការកិរិយាទង្វើបែបនេះ គួរយើងជនកុំប្រព្រឹត្តធ្វើឲ្យសោះឡើយ ត្រូវបៀសវាងឲ្យផុតស្រឡះចេញពីខ្លួន ដើម្បីការពារពាក្យតិះដៀលអំពីសំណាក់ជនដទៃ ទើបកើតសេចក្ដីសុខសួស្ដីគ្រប់យ៉ាងទៅបាន ។

ពួកជនខ្លះក្រោធទឹងការនៅលើមនុស្សអ្នកមានសីលធម៌ ដែលឥតទោសមិនប្រទូស្ត ហើយត្រឡប់បានទោសធ្លាក់មកត្រូវខ្លួនវិញក៏មាន, ទឹងទៅលើមនុស្សដែលខ្លួនបានធ្វើប្រយោជន៍ដល់គេ ហើយគេមិនបានឲ្យប្រយោជន៍មកដល់ខ្លួនវិញក៏មាន ។

ក្នុងទីនេះ សូមពាញយកគាថា ១ កន្លែងមកជាគ្រឿងសាធកថា

យោ អប្បទុដ្ឋស្ស នរស្ស ទុស្សតិ
សុទ្ធស្ស បោសស្ស អនង្គណស្ស
តមេវ ពាលំ បច្ចេតិ បាបំ
សុខុមោ រជោ បដិវាតំវ ខិត្តោ ។

សេចក្តីថា អ្នកណាប្រទុស្តដល់គេ ដែលគេមិនប្រទុស្តតមក
វិញជាបុរសអ្នកមានសន្តានចិត្តដ៏បរិសុទ្ធ ឥតមានកិលេសជាគ្រឿង
លលិចឡើយ, អំពើបាបរមែងឲ្យផលដល់អ្នកនោះស្រស់ៗ ដូចជាធូលី
ដ៏ល្អិតដែលបុគ្គលបាចសាចផ្ទុះទៅកាន់ទីច្រាសខ្យល់ (រមែងត្រឡប់មក
កាន់ខ្លួនវិញមិនខាន) ។

ព្រះពុទ្ធដីកានេះហើយ ដែលទ្រង់សំដែងសេចក្តីឲ្យឃើញច្បាស់
ចំពោះបុគ្គលដែលក្រោធខឹងទាន់ទៅលើអ្នកមានគុណ គឺសីលធម៌ជាដើម
នឹងឲ្យផលត្រឡប់មកដល់ខ្លួនទាន់ហន់វិញមិនខាន ។

គួរស្គាល់ឲ្យច្បាស់អំពីកិរិយារបស់មនុស្សដែលក្រោធខឹងនោះៗមាន
បញ្ចេញអាការបន្តិចបន្តួចម្តងៗ ត្រញាក់ ខាំមាត់ សង្កៀតធ្មេញ ញញ
អណ្តាត យាដៃជើង ជំឡើងភ្នែកក្រលួន មាត់ឡូឡា ទះតប់ទ្រូងជាដើម
ទើបស្ទុះទៅប្រហារអ្នកដទៃ នេះជាវិទ្ធអំណាចរបស់វា ដូចគ្នានឹងសត្វ
ឆ្កែ ជម្លាសត្វឆ្កែកាលបើឃើញគ្នាហើយ ពុំដែលមានសេចក្តីសោមនស្ស
រីករាយចំពោះគ្នាទេ តែងមានកំហឹងបញ្ចេញធ្មេញ បន្លឺជាសម្លាំង
វិទ្ធអំណាចរបស់វា ទើបស្ទុះទៅប្រខាំគ្នា នេះជាកំហឹងរបស់សត្វឆ្កែ,
ចុះណាលោកតែងពាក្យប្រដៅកូនចៅប្រុសស្រីឲ្យចាំរកពាក្យប្រដៅថា :
“អន្ទុយខ្ពស់ជាងឈើ ឃើញគ្នាមកពុំដែលអរ” តើបានដល់អ្វី ?
លោកប្រាប់ថា បានដល់ឆ្កែ ជាតួយ៉ាង ។

អាការទោសៈ ឬកោធៈនេះ គួរយុវជនខំប្រឹងទប់ទល់ឬលះបោល ឲ្យបាន ព្រោះថា ទោសៈដែលកើតឡើងក្នុងអារម្មណ៍ណាមួយហើយ នឹងផ្ទុំគួរនោះ ឲ្យក្តៅចិត្តពេលកាលជាសពាសៈទៅក្នុងអារម្មណ៍នោះៗ ដូចគ្នានឹងភ្លើងឆេះព្រៃ បើមានព្រៃនៅត្រឹមណា ភ្លើងក៏ឆេះរាលដាល ពាសពេញត្រឹមនោះទាល់តែអស់ព្រៃ ទើបអស់ភ្លើង ។

ធម៌ដែលត្រូវលត់ទោសៈឬកោធៈឲ្យរលត់នោះ គោរពយកធម៌ ខន្តីសេចក្តីអត់ទ្រាំក្តៅត្រជាក់ជាដើម ដែលលោកហៅថា "ខន្តិពលំ ពលានិកំ" មកជាអាវុធពលជួយលត់កុំឲ្យភ្លើងគឺទោសៈឆេះឡើងរួច ឬក៏យកមេត្តា ករុណាធម៌ ជាទឹកស្រោចដាក់លើអណ្តាតភ្លើងគឺទោសៈ កោធៈនោះៗ ឲ្យរលត់បាត់សូន្យឈឹងទៅ ។ តអំពីសេចក្តីនៃធម៌នេះ សូមស្តាប់ពាក្យកាព្យជាបទកាកគតិ ប្រៀបដោយរឿងសត្វកេងកង ។

## រឿងប្រៀបសត្វកេងកង

ទុសត្វកេងកង នាំគ្នាហើរចេញ ទៅក្រៅព្រៃពព្ធក សំរាកដើមព្រៃ មានមែក សាខា ដុះស្ទាក់ស្ទួន ព្រោះផ្លែផ្កា ។ ដើមព្រៃនោះណា ធំជាងរុក្ខ ទាំងប្រហោងធំ នៅត្រង់ចន្លោះ សមជាទ្រនំ កេងកងនៅទំ ពាំងញី ឈ្មោលកា ។ មិនយូរប៉ុន្មាន កេងកងញីបាន ក្តិក្រលេខា មានតិចរាស់ ខែ ម្នាក់ឯងក្រៅ ក្តីបញ្ចុកម្ហូប ស្វែងរកចំណី ។ បញ្ចេញប្រពន្ធ កំពុងកកក្តៅ មិនដឹង រឿងក្តី បញ្ជាក់ក្រុមខាង ប្រឡំចំណី ស្វែងរកមាន

ស្រី ញីដៃទៀត ។ កេងកងញីដឹង ប្រឡោតបិត្តទាំង ដូចអ្នកកន្ទ្រៀត ឃើញមុខប្ដីក្ដៅ មួម៉ៅរេរស្មៀត កេះរៀងប្របៀត ឲ្យបានទាស់គ្នា ។ ពិស្សូរទៅថា បងឯងទៅណា ហួសពេលវេលា ស្វែងរកចំណី ប្រហែលមានគ្នា បានជាយូរយារ ដល់ពេលយប់នេះ ។ កេងកង ឈ្លោលធ្វើយ ឱប្អូនបងអើយ រឿងនេះពុកស្មេះ បងវង្វេងផ្លូវ យប់ជ្រៅ ដល់ម៉ោះ បងទំតត្រិះ គេបរវៃព្រស្លាប់ ។ កេងកងញីក្រោធ ដាលចិត្ត ប្រឡោត ស្ទុះទៅប្រតាប់ រុកខឹងក មួលបីតតល់ស្លាប ជ្រុះកេមដុនដាប ទាល់តែរៀងខ្លួន ។ កើតទុក្ខពេះលែង ពោលទឹកខ្ទេង ដែលនៅម៉ាម្នួន ហើរពោលទ្រើន ទៅនៅយោយខ្លួន កេស៊ីពឹងតួខ គង់ព្រៃទុតិម ។ ឯសត្វកេងកង ស្លាបខ្មៅសផង ចំពុះកោទធំ កើតឈ្មោះប្រែកក បែកចិត្តជំណាំ កើតទុក្ខក្រៀមក្រំ ចាំងឈ្លោលចាំងញី ។ លែងះឃើញ មុខគ្នា ទាល់ចាស់ជរា វង្វេងកែវ ស៊ូស្លាប់រៀងខ្លួន លំបាកពេញទី សូន្យអស់ឥន្ទ្រិយ ជីវិតដល់ស្លាប់ ។ ឯរឿងកេងកង ដែលខ្ញុំតែងបង ជាច្បាប់សម្រាប់ ខ្ញុំនាងប្រុសស្រី ទុកជាប្រដាប់ ប្រាជ្ញាគាតោប គាត់តាមគន្លង ។ ដូចយើងប្រុសស្រី កើតក្នុងលោកិយ ទាំងខុសទំនង តាំងចិត្តប្រកាន់ លែងធប់រកយង ក្លួបក្រោធបំណង សម្លាប់គ្នា ។ ខ្វះទាំងលែងលះ ដាច់ចិត្តស្រឡះ ពីបុត្តភរិយា ពោលទៅរោគ លំបាកកំព្រា គ្រប់ពេលវេលា គ្មានសុខឡើយណា ។ ខ្វះទាំងខឹង

កូន មិនតាមដំបូ- ន្មានខ្លួនស្តីថា ឲ្យបានបែបបទ មិនដូចប្រាថ្នា
ក៏យឥតមេត្តា បណ្តេញចេញទៅ ។ ខ្លះខំទំនេក្រ ទ្រព្យគេក្តីណាល្អ
គ្មានពីម៉ែឪ មិនមានដូចគេ ចង់ពៀរសត្រូវ ដល់ម៉ែដល់ឪ លែង
ធ្វើបុណ្យឲ្យ ។ លែងជារបង្សុកូល រកស៊ីប្រមូល ទ្រព្យចូលលែង
ខ្សោយ ទិញស្រាធំកស៊ី លែងគិតមុខក្រោយ អស់ទ្រព្យកប់រោយ
មិនគិតកតញ្ញូ ។ ខ្លះខឹងទិនប្តី បះតែមានស្រី មិនដែលទំនេរ
ក្តៅចិត្តម្តៅ ស្ទុះទៅកគេ ខ្ញាំខ្ញុំដើងខ្វេ ទាញកន្ត្រាក់ប្តី ។ ជេរ
ម្តាយជៀលពូជ ប្តីខ្លួនខិលខូច មិនឡើងកសី អួតផងទាំងពួន ជាគា-
ឲ្យកណ្តី នាំឲ្យអប្រិយ ដល់ប្តីនិងខ្លួន ។ ខំស្ទង់គេទ្រព្យ ច្រើន
បង់អក័ព្ទ មិនដូចចិនយួន បានព្រឹកខ្លះល្ងាច រកថែមប្រមួន មិន
លម្មសមគួរ ដូចខ្លួនប្រាថ្នា ។ និពសព្រាត់ព្រាស ក្រទាល់ដល់បាស់
លំបាកណាស់ណា ញាតិផងគេស្អប់ លែងរាប់ជាគ្នា ខ្លួនហោកកំព្រា
ឥតមានទីពឹង ។ ខ្លះខឹងឪពុក ម្តាយផ្តាំទុក ច្រើនរឹងទទឹង ពុំ
ស្តាប់បង្គាប់ យកជាខ្លួនខ្ពង់ ចបេសមុខរឹង យកឈ្នះតែឯង ។ ហៅ
ខ្ទុកំណាច ខិលខូចឥតខ្លាច ឥតមានកោតក្រែង មាតាបិតា ត្រូវ
តែលះលែង ពន់ទាំសាថែង កុំកប់ជាកូន ។ មាតាបិតា មិនត្រូវ
មេត្តា ហោលកឲ្យស្លូន សាប់ញាតិសន្តាន ព្រៀងលានបងប្អូន
កុំចង់បានកូន បែបនេះទៀតឡើយ ។ ខ្លះខឹងព្រះសង្ឃ បួសរៀន

ហ៊ាន ពុំមានគោរពឡើយ នៅតែក្នុងវត្ត ប្រតិបត្តិកៀកកើយ មិនធ្វើ ឥន្ទ្រីយ ក្នុងព្រះសាសនា ។ គេស្អប់មើលងាយ គេមិនរីករាយ គ្មានចិត្តជ្រះថ្លា ព្រោះគេមិនកាន់ ពុទ្ធសាសនា តាមតែគេថា សង្ឃគោក្របី ។ គេថាបួសល្ងង់ គោក្បាលធ្វើសង្ឃ គ្មានបះដងអ្វី ស៊ីដេកស៊ីដេក គ្មានធ្វើការអ្វី អញគ្មានមេត្រី អញគ្មានខ្វីកោត ។ ខឹងជេរផ្ដាសា ថាសង្ឃអីក៏ នៅតែខឹងក្រោធ មិនស្មើនឹងអញ អញមិនបញ្ចោត ទ្រព្យគេកប់កោង គោកលួចគេស៊ី ។ បាយជនអ្នកស្រុក គេដាក់បាត្រទុក ឲ្យកលជួ គ្មានខ្មាសគ្មានអៀន បានតែដេកស៊ី បញ្ចោតពេញទី លួចស៊ីពីឯង ។ ដេរចិតស្បង់ ពួកអាត្រមង់ ស្លៀកពាក់វែងៗ ដើរលេងហ៊ុយហា ងកមានគោកត្រែង អញមិនស្រប់ស្រែង ខ្លាចអាត្រអើល ។ ជនណាប្រគាទ ជេរជៀលមារយាទ ព្រះសង្ឃជាគោល ពុទ្ធសាសនា ពោលពាក្យតម្រោល ជននោះធ្លាក់ខ្លោល ទៅកបាយភូមិ ។ ព្រះសង្ឃប្រសើរ ពោះប្រតិបត្តិស៊ើរ គ្មានពិសបន្ទំ គ្មានជេរអ្នកណា រកាទូម លោភជនបន្ទំ គឺពិសកំណាច ។ ទ្រង់មានមេត្តា ព្រះទ័យករុណា សព្វសត្វរូបកាយ មិនខឹងតបត មិនអួតអំណាច សង្រឹមធ្វាច ឲ្យគេខ្លាចលោភ ។ នៃពួកកូនក្មេង កុលកុំលេង កុំនាំបន្ទោរ លើពន្ធរ័យា ឬស្មុះឆ្ញោត ក្បាលនឹងត្រឡោក លោភអត់យកក្ដី ។ ព្រះសង្ឃគ្រូបង់ គុណបុនធាំនក្ស

មិនគួរគប្បី ធ្វើបាបដូច្នោះ គង់ធ្លាក់អវិចី ខានរឿងស្រដី ដូចជាង កែវមណី ។ គាត់ជាជាងថ្លៃ កាន់កែវក្នុងដៃ ប្រឡាក់ពេញទី ឈាម រុំជុំកែវ ក្រហមមណី គាត់ដាក់ត្រង់ទី មុខព្រះថេរៈ ។ ហើយចូល ទៅក្នុង កាប់សាច់តុងៗ រួចលែងធុរៈ ចេញមកខាងក្រៅ បាត់កែវ គាត់ មុខព្រះថេរៈ កើតក្តីក្រោធខឹង ។ កែវដែលដាក់នោះ សត្វ ក្រៀលមកឆ្ពោះ លេបចូលទៅវិញ ទៅនៅក្នុងពោះ បាត់កែវសូន្យ ឈឹង ជាងខឹងក្រញឹង ទ្រមឹងការកាត់ ។ ចាប់ចោទលោកថា លួច កែវសាក្នា លាក់ទុកបំបាត់ ប្រកាន់មិនលែង កំហែងមុឺងម៉ាត់ ញីរញ៉ើម ប្រមាត់ ស្ទុះលោកទៅតាម ។ ចាប់ក្បាលលោកបាន សង្កត់រុញ ច្រាន ដោយខឹងឈើឃ្នាប លៀនក្ដួកហូរឈាម ស្រក់ដល់នោប សត្វក្រៀលលោតចាប ស្របយកឈាមផឹក ។ ជាងកែវខឹងវាយ ស្លាប់អន្តរាយ សត្វក្រៀលប្រម៉ឹក ចូលចិត្តផឹកឈាម ដូចគេផឹកទឹក គាត់វាយសន្លឹក សត្វក្រៀលដល់ស្លាប់ ។ ទើបលោកប្រាប់ថា អ្នក ជាងចាប់វា វះពោះឲ្យឆាប់ ឃើញកែវមណី ក្នុងពោះវាស្រាប់ បើកុំ វាឆាប់ ការក្តាមិនប្រាប់ ។ ជាងគាត់វះពោះ ឃើញកែវក្នុងពោះ ភ័យស្ទុះមកក្រាប សូមលន់តួទោស ខុសមិនគួរគាប់ ខមាលោក ជាប់ ទទួលបង្អាប់ ។ នេះហើយទឹងខុស ទឹងដែលកំហុស កើត ចិត្តប្រកាន់ មិនពិចារណា ឲ្យឃើញជាក់ស្ពាត់ កើតទុក្ខសំទាន់

ឲ្យផលទាន់ក្រោយ ៗ កើតទោសក្នុងលោក គេមិនអធ្យាគ ធ្វើតាម
បណ្តោយ គេដាក់គេប្រើ ព្រោះឯងធ្វើព្រោយ ឲ្យផលឯងក្រោយ ដូច
ឯងធ្វើគេ ៗ ទោសទៅបរលោក យមបាលចាប់បោក គ្មានយល់មុខទេ
ព្រោះកម្មខ្លួនធ្វើ រឹងរឹតឡើងទ្វេ លើសជាងធ្វើគេ ផល់ប្រាំមួយផង ៗ
ហៃជនប្រុសស្រី ធូរទំយាគខ្វី កុំធ្វើឲ្យធ្ងន់ ធូរទំសង្កាត់ គោគេ
រៀមច្បង ចាស់ទុំសង្ស័យផង ពេញជាប្រសើរ ៗ ខ្លះរឹតរឹងគោ
ផងយផល់កេទ គោគាបមិនដើរ យកពម្បៀងរុំ ឈ្មួលក្រើនឯណ្ណើរ
ឲ្យធ្ងន់ស្មើរ ដំតែទីស្លាប់ ៗ មិនទីទីប៉ុណ្ណោះ គេរៀងដូចចុះ
យកទៅសម្លាប់ យកសាច់គាំងស៊ី ស្បែកគាលទុកផ្ជាប់ លក់ឲ្យបិនកប់
យកប្រាក់មកចាយ ៗ គោខ្លះមិនទៅ ចេញពីក្រោលទៅ ព្រោះ
មួសទាំយាយ ម្ចាស់មិនធ្វើក្លក ដុតឲ្យសប្បាយ ដេរក្រោមដីមស្វាយ
កាយមួសទាំពេញ ៗ ម្ចាស់ទីងប្រឡោត កន្ត្រាក់ជាន់ត្នោត សំពង
បណ្តេញ ឲ្យគោចូលក្រោល គោគោលចូលចេញ ទីងរិតប្រដេញ
វាយគោផល់ស្លាប់ ៗ ជាកម្មខុសត្រកម៉ក លេងទីងក្រក់ គ្មានគិតផល់
ច្បាប់ មិនដឹងខុសខុស ព្រោះគ្មានសណ្តាប់ មិនបេះគួរគាប់ ធ្វើក្ដក់ឲ្យ
គោ ៗ លុះផល់ស្លាប់ទៅ ចុះនរកជ្រៅ រងទុក្ខយំកេទ ត្រូវភ្លើងឆុះឆេះ
ពេញខ្លួនសន្ធៅ ព្រោះគម្ពក់គោ ឲ្យផលដល់ខ្លួន ៗ ខ្លះទីងទីងខ្ញុំ
វាយដំហើយគុំ លើសជាងចំនួន ប្រាក់ដើមខ្លួនលោះ មិនត្រូវតាមច្បួន

ប្រាក់ដែលលោះខ្លួន យកមកធ្វើខ្ញុំ ។ ខ្ញុំឲ្យបែកបាន បែកកែវដើរពាន
តក់ទុកជំនុំ ដម្លៃប៉ុន្មាន គិតស៊ីគ្រលុំ ប្រាក់ដើមមិនធុំ ថែមប្រាក់បានថ្មី ។
លើសជាងប្រាក់ដើម រកផលដង្ហើម មិនរួចខ្ញុំស្រី ប្រាក់ដើមលែងធុំ
ប្រាក់ថ្មីទៅថ្លៃ ពួកខ្ញុំប្រុសស្រី ស៊ីជំមិនបាន ។ អំពើនេះហើយ នាំពួក
គេនឹងអើយ ឯងកុំចង់បាន ក្រែងបាបមកជួន ពានលើខ្លួនប្រាណ
កើតទុក្ខរំពាន ទីងធ្លាក់នរក ៖ ព្រះណោះស្ទះសាយ គេជេរដល់ម្តាយ
គេក្តីឈ្មោះអាក្រក់ គ្រៃលះរៀវបាច ស្មៀប៉ុនសក់ សុទ្ធតែលាមក
ឯងកុំធ្វើឡើយ ។ ខ្លះទីងទីងវៃ ស៊ីពោតបែៗ កុំធ្វើកោះគើយ
ដាក់ថ្នាំបំពុល វៃគ្រាំផឹងឡើយ ស៊ីផ្អែតរួបហើយ ស្លាប់ក្នុងចំការ ។
ជួនលបចាំកាប់ រឺវៃ ១ ខ្ទាច់ ទីងវៃដាក់ផ្លូវ ស្ទុះទៅចំព្រៃ ច្រើន
ទុខប្រហារ ហោលក្នុងចំការ ឲ្យតាគក់ស៊ី ។ វៃទៅក្នុងស្រុក ដើរ
មកចំមុខ ដេញកាប់រត់ ដាច់ជើងដាច់ដៃ ហោលពាសពេញទី គ្មាន
សល់ហ្វាលញ៉ា ព្រសព្វក្នុងស្រុក ។ ទីងនេះឯងណា វៃក្នុងលោ
ខេពតា ផ្ទួនចំមុខ អ្នកណាកាប់វៃ លោកនេះឲ្យស្រុខ ឲ្យបានតែទុក្ខ
អន្តែនយួរផ្កាយ ។ ហៃយុវជន ត្រូវអត់ធន់ តាមយើងអធិប្បាយ កុំ
សម្លាប់សត្វ រិបគ្គិរូបកាយ ទុំខន្ធផ្ទន់ដើរឃ្លាយ វៃក្នុងខ្លាក់ច្រើនជាតិ ។
ព្រះទ្រង់ទេសនា ឲ្យមានមេត្តា កុំឲ្យអាឃាត បង់ពៀរវេរា ត្រូវឲ្យរៀរ
ឃ្លាត កុំឲ្យប្រមាថ ដល់សត្វនានា ។ ខ្លះទីងពួកក្រម គេមិនប្រជុំ

ឲ្យចូលសមគ្គា គេរៀងបៀតបៀន ធ្វើឲ្យឃ្លាតឃ្លា ឲ្យបែកបាក់គ្នា ពួក ក្រុមជាតិខ្លួន ។ ពីនេះទៅមុខ បូរាណាចាំទុក ធ្វើឲ្យចាំមួន កុំខឹង ខឹងគេ ឥតគិតគំនូរ គេហៅគ្រប់គ្នា ឲ្យទោសជាប់ ។ យើងនាំ រឿងសត្វ ៥ពួកមកដាក់ បែងទុកជាច្បាប់ ពីព្រេងនាយមក កុំយក គម្រាប់ ព្រោះតែបង្អាប់ នាំត្រែត្រកូលវង្ស ។ ឯងមើលសព្វ ហើយ កុំធ្វើគោះគើយ ឬកកាត្រទន់ លះខឹងឲ្យបាន កុំឲ្យរលង់ កណ្តាលរឿងនេះ ដូចសត្វ៥ពួក ។

## រឿងសត្វ ៥ ពួក

សេចក្តីដំណោលថា: ក្នុងបឋមកប្ប មានសត្វ ៥ ពួក គឺ សត្វ ហង្ស ១ ពួក, ក្រួច ១ ពួក, សេក ១ ពួក, ក្អែក ១ ពួក, និងសត្វ មៀម ១ ពួក សត្វទាំងនេះ វេះតែមានសេចក្តីឈ្លោះប្រកែកគេរៀង ប្រទូស្តរាយបៀតបៀនគ្នាទៅវិញទៅមក ពុំដែលបានសេចក្តីសុខឡើយ ពុំមានសត្វបក្សីណាមួយ អាចជួយឃាត់ឃាំងកំចាត់ការពាររក្សាគ្នាឲ្យ បានសេចក្តីសុខសប្បាយនោះសោះ ។

សម័យនោះ ពួកសត្វក្រុងទាំងអស់ក៏ប្រមូលគ្នាហើយទៅប្រជុំលើថ្ម មនោសិលា ប្រឹក្សាការជ្រើសរើសរកសត្វណាមួយ ដែលល្មមគួរនឹង តាំងអភិសេកឲ្យធ្វើជាស្តេច ដើម្បីរក្សាសេចក្តីសុខទុក្ខគ្រប់រូប ទើប សួរគ្នាទៅវិញទៅមកថា ខណៈណាគួរនឹងធ្វើជាស្តេចបាន? ។

គ្រានោះ មានសត្វខ្លែង ១ ឆ្លើយឡើងថា: សត្វចៀមនេះជាសត្វអង់អាចក្លៃក្រៃលែង មានកម្លាំងក៏ច្រើន គួរនឹងតាំងឲ្យធ្វើជាស្តេចត្រួតត្រាលើយើងរាល់គ្នាបាន, ពួកសត្វទាំងនោះ ក៏ទទួលព្រមតាមពាក្យសត្វខ្លែងថា: "សាធុៗ" ព្រមគ្នាឡើង ស្រាប់តែសត្វជ្រូកធំ ១ ចង់សោយរាជ្យដោយខ្លួនឯង ឆ្លើយជំទាស់ឡើងថា "សត្វចៀមនេះ ជាកោសិយគោត្ត ជាតិជាសត្វ ថោកទាបអប្រិយ" បើក្រុមញាតិយល់ឃើញថាគួរហើយ ខ្ញុំក៏មិនអាចនឹងហាមជាដូចម្តេចឡើយ តែបើកឱកាសឲ្យខ្ញុំនិយាយ ខ្ញុំនឹងជំរាបដល់ក្រុមញាតិឥឡូវនេះឯង សត្វទាំងនោះក៏បើកឱកាសឲ្យ ទើបសត្វជ្រូកពោលថា "អើ! ពួកជាសន្តានទាំងអស់! សត្វចៀមនេះមានមុះភក្ត្រកំណាស់ ពុំគាប់ចិត្តសោះ មុខដូចជាគេខឹងទៅហើយ នឹងតាំងឲ្យធ្វើជាស្តេចម្តេចបាន!' សត្វទាំងអស់ក៏យល់ដូចជាសត្វជ្រូកថាមកនោះដែរ សត្វចៀមក៏អាក់ខានបានធ្វើជាស្តេចទៅ ។

ក្នុងជំនុំនោះ មានសត្វក្អែក ១ ចាស់ទុំជាងគេឆ្លើយឡើងថា: សត្វជ្រូកនេះ ជាសត្វមាំមួនជាងគេ មានកម្លាំងក៏ច្រើន គួរសមនឹងតាំងឲ្យធ្វើជាស្តេចត្រួតត្រាលើរូបយើងរាល់គ្នាបាន សត្វទាំងនោះក៏ទទួលព្រមតាមពាក្យសត្វក្អែកនោះថា "សាធុ" មែនហើយៗ ។ ឯសត្វចៀមកំពុងគំនុំនឹងសត្វជ្រូកចង្រៃ ក៏ឆ្លើយជំទាស់ឡើងថា: "ខ្ញុំបានឮគេដំណាលថា: សត្វជ្រូកនេះជា បណ្តាគោត្ត ទាបអាក្រក់" តែថាបើ

ពួកញាតិទាំងអស់យល់ឃើញថា គួរសមហើយ ខ្ញុំក៏មិនមានទំនងហាម ជាដូចម្ដេច! ពួកសត្វទាំងនោះក៏បើកឱកាសឲ្យសត្វមៀមនិយាយ សត្វមៀមបានឱកាសហើយនិយាយបន្តថា: "ទេ! សូមឲ្យញាតិទាំងអស់ សត្វក្អែកនេះ មានសេចក្ដីក្រោធណាស់ ចិត្តក៏អាក្រក់ វែងវៀតវៀន គេជានិច្ច នឹងតាំងឲ្យធ្វើជាស្ដេចដូចម្ដេចកើត!" ។ ឯសត្វក្អែកបានឮពាក្យសត្វមៀមនោះហើយ ក៏ប្រឡូតក្រោធខ្លាំងមហិមាក្រទ្រក្រទា ពោលថា: "ម្នាលគ្នាយើង! អញវិនាសខ្លួនខានពុំបានធ្វើជាស្ដេចនេះ ព្រោះតែអាមៀមមុខអាក្រក់ដូចជាខ្មោចនេះឯង វាធ្វើឲ្យអន្តរាយ" ។ ចំណែកខាងមៀមវិញ ក៏ប្រឡូតខឹងតបទៅថា: "ម្នាលគ្នាយើង! អញវិនាសខ្លួនខានពុំបានធ្វើជាស្ដេចនេះ ព្រោះតែអាក្អែកបណ្ដាលតាឡកណ្ដើតប្រែយចិត្តអាក្រក់នេះឯង វាធ្វើឲ្យអន្តរាយ" ។

សត្វទាំងពីរនោះ កើតជម្លោះឈ្លោះប្រកែកជេរប្រមាថត្រកូលគ្នាទៅវិញទៅមក ហើយសុំទៅតតាំងប្រយុទ្ធនាពុំឈ្នះពុំចាញ់ ទើបស្រុះហើយបែកប្រេះគ្នាទៅអំពីទីប្រជុំនោះ ចងគំនុំគុំគួនរករឿងចងពៀរគ្នាអស់ ១ កប្ប ដរាបមកដល់កាលឥឡូវនេះឯង ។

គ្រានោះ សត្វបក្សីទាំងអស់ប្រជុំគ្នារើសសត្វគ្រុឌឲ្យធ្វើជាស្ដេច ព្រោះសត្វគ្រុឌមានកម្លាំងខ្លាំងជាកំពូលលើសសត្វបក្សីនានា អាចត្រួតត្រាការពាររក្សាសេចក្ដីសុខទុក្ខបាន, សត្វសេកឆ្លើយឡើងថា: "ក្រុង

គ្រុឌពុំគួរនឹងតាំងឲ្យធ្វើជាស្តេចតែម្តងទេ ខ្ញុំយល់ឃើញថា គួរនឹងតាំងសត្វហង្សឲ្យធ្វើជាស្តេចវិញ ព្រោះហង្សត្រូវជាពង្សត្រកូលខ្ពស់ មានរូបឆោមលោមពណ៌ក៏ល្អ មានប្រាជ្ញាឆ្លាតវាងវៃ សំដីក៏ពីរោះ ហើយចេះកាន់ធម៌ប្រកបដោយសេចក្តីមេត្តាករុណាច្រើន" ពួកសត្វទាំងនោះមានគ្រុឌជាដើម ក៏ទទួលព្រមថា "សាធុ" ហើយក៏ឲ្យសត្វហង្សសោយរាជ្យជាម្ចាស់លើសត្វបក្សាទាំងឡាយ ជាទឡ្ហីករក្នុងពេលនោះឯង ។

ចប់លក្ខណៈជាគ្រឿងកំណត់មនុស្សអ្នកក្រោធតែប៉ុណ្ណោះ

សុខិតា ហោន្តុ និច្ចា

---